ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
National Council for Sustainable Development

ក្រសួងបរិស្ថាន
Ministry of Environment

# សិក្ខាសាលា
# ត្រួតពិនិត្យលទ្ធផលការងារអភិវឌ្ឍន៍ដោយចីរភាព
# ឆ្នាំ២០២០ និងទិសដៅការងារឆ្នាំ២០២១

# Annual Workshop
# to Review NCSD 2020 Progress
# and Develop Work Plan for 2021




ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០
29 September 2020

# មាតិកា
# Table of Content


របៀបវារៈ 1
Agenda

## ប្រធានបទវងទី១៖ សមិទ្ធិផលរបស់អគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. ឆ្នាំ២០២០ និងទិសដៅអនុវត្តឆ្នាំ២០២១
## Agenda Item 1: NCSD Achievement in 2020 Progress and Develop Work Plan for 2021

សមិទ្ធិផលឆ្នាំ២០២០៖ 5
- វឌ្ឍនភាពកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ និងថវិកា
- វឌ្ឍនភាពនៃការអនុវត្តគោលដៅអភិវឌ្ឍន៍ដោយចីរភាពសម្រាប់វិស័យ បរិស្ថាននិងការអភិវឌ្ឍដោយចីរភាព

NCSD Achievements in 2020:
- Progress of Cooperation with development partners and Budget
- Progress in Implementing the Sustainable Development Goals for the field of Environment and Sustainable Development

ទិសដៅអនុវត្តឆ្នាំ២០២១ 16
Priorities for 2021

## ប្រធានបទវងទី២៖ ការអភិរក្សជីវៈចម្រុះ និងជីវៈសុវត្ថិភាព
## Agenda Item 2: Biodiversity Conservation and Biosafety

វឌ្ឍនភាពនៃការរៀបចំគោលនយោបាយពាក់ព័ន្ធនឹងជីវៈចម្រុះ 19
Biodiversity policy development

វឌ្ឍនភាពនៃការអភិរក្សក្រៅដែនធម្មជាតិ ការសិក្សាស្រាវជ្រាវ និងយន្តការគ្រប់គ្រងព័ត៌មានជីវៈចម្រុះ 31
Ex-situ Conservation, Research and Biodiversity Information Management Mechanism

## ប្រធានបទវងទី៣៖ ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ
## Agenda Item 3: Climate Change Response

វឌ្ឍនភាពនៃផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា 41
Progress of the Cambodia Climate Change Strategic Plan (CCCSP) Implementation

វឌ្ឍនភាពនៃការរួមចំណែករបស់ជាតិដើម្បីអនុវត្តអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអា កាសធាតុ 50
Nationally Determined Contribution (NDC) Update Process

## ប្រធានបទវងទី៤៖ ការអភិវឌ្ឍសេដ្ឋកិច្ចបៃតង និងវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា
## Agenda Item 4: Green Economy, and Science and Technology

សមិទ្ធិផលនៃកម្មវិធីទីក្រុងនិរន្តរភាព 66
Key Achievements of Sustainable Cities

ការវាយតម្លៃសក្តានុពលសេដ្ឋកិច្ចនៃថាមពលពន្លឺព្រះអាទិត្យនៅកម្ពុជា 72
Full Economic appraisal of Potentials of Solar Energy in Cambodia

វឌ្ឍនភាពនៃការរៀបចំគោលនយោបាយស្តីពី ការប្រើប្រាស់ និងផលិតកម្មដោយនិរន្តរភាព 76
Progress made of Policy Formulation on Sustainable Consumption and Production

វឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការក្នុងការប្រើប្រាស់ថាមពលនុយក្លេអ៊ែរសម្រាប់បម្រើក្នុងគោលបំណងសន្តិភាព 95
Cooperation on in the Use of Atomic Energy for Peaceful Purposes

-ក្រមសីលធម៌ និងកម្មវិធីសិក្សាស្រាវជ្រាវថ្នាក់ជាតិ 109
-សហការ និងសម្របសម្រួលការអនុវត្តគម្រោង សិក្សាស្រាវជ្រាវ៖
១)យុទ្ធសាស្ត្រជាតិក្នុងការ គ្រប់គ្រងបរិស្ថាននិងកំណត់តម្លៃសំណល់ និង
២)គំរូអភិវឌ្ឍន៍សហគមន៍ប្រកបដោយចីរភាព
- Research Ethics and National Research Agenda for Science and Technology
- Cooperate and Coordinate the implementation of Research Study Project:
1. National Pricing Strategy for Waste and Environmental Management
2. Sustainable Community Development Model

**របាយការណ៍សមិទ្ធផលសម្រេចបាន ក.ជ.អ.ច ប្រចាំឆ្នាំ២០២០ និងទិសដៅបន្តឆ្នាំ២០២១** 121
NCSD Achievements Report in 2020 and Priorities for 2021

# អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
# សិក្ខាសាលាត្រួតពិនិត្យលទ្ធផលការងារអភិវឌ្ឍន៍ដោយចីរភាពឆ្នាំ២០២០ និងទិសដៅការងារឆ្នាំ២០២១

សាលប្រជុំម៉ុក ម៉ារ៉េត ទីស្តីការក្រសួងបរិស្ថាន ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០

## របៀបវារៈ

| ម៉ោង | ប្រធានបទ | វាគ្មិន | អ្នកសម្របសម្រួល |
|---|---|---|---|
| ៧:៣០-៨:៣០ | **ចុះឈ្មោះ** | | |
| ៨:៣០-៩:០០ | គោរពភ្លេងជាតិនៃព្រះរាជាណាចក្រកម្ពុជា | | **កញ្ញា អៀន បញ្ញាវីត** អនុប្រធានការិយាល័យនៃនាយកដ្ឋានសេដ្ឋកិច្ចបៃតង |
| | ប្រកាសកម្មវិធី | | |
| | សុន្ទរកថាស្វាគមន៍ | **ឯកឧត្តម វ៉ាន់ មុនីនាថ** អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. | |
| | សុន្ទរកថាបើកសិក្ខាសាលា | **ឯកឧត្តម សាយ សំអាល់** ប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងជារដ្ឋមន្ត្រីក្រសួងបរិស្ថាន | |
| | ថតរូបអនុស្សាវរីយ៍ | គណៈអធិបតី និងអ្នកចូលរួមទាំងអស់គ្នា | |
| ៩:០០-៩:១៥ | **សម្រាកពិសាអាហារសម្រន់** | | |
| **ប្រធានបទរងទី១៖ សមិទ្ធិផលរបស់អគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. ឆ្នាំ២០២០ និងទិសដៅអនុវត្តឆ្នាំ២០២១** | | | |
| ៩:១៥-៩:៤៥ | សមិទ្ធិផលឆ្នាំ២០២០<br>- វឌ្ឍនភាពកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ និងថវិកា<br>- វឌ្ឍនភាពនៃការអនុវត្តគោលដៅអភិវឌ្ឍន៍ដោយចីរភាពសម្រាប់វិស័យបរិស្ថាននិងការអភិវឌ្ឍដោយចីរភាព | ឯកឧត្តមអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. | ឯកឧត្តមរដ្ឋលេខាធិការ |
| | ទិសដៅអនុវត្តឆ្នាំ២០២១ | | |
| **ប្រធានបទរងទី២៖ ការអភិរក្សជីវៈចម្រុះ និងជីវៈសុវត្ថិភាព** | | | |
| ៩:៤៥-១០:៣០ | វឌ្ឍនភាពនៃការរៀបចំគោលនយោបាយពាក់ព័ន្ធនឹងជីវៈចម្រុះ | **លោកស្រី កែន បូព្រាង** ប្រធាននាយកដ្ឋានជីវៈចម្រុះ | ឯកឧត្តមរដ្ឋលេខាធិការ និងឯកឧត្តមអគ្គលេខាធិការ ក.ជ.អ.ច. |
| | វឌ្ឍនភាពនៃការអភិរក្សក្រៅដែនធម្មជាតិ ការសិក្សាស្រាវជ្រាវ និងយន្តការគ្រប់គ្រងព័ត៌មានជីវៈចម្រុះ | **លោក ចន្ទី សុមេត្តា** អនុប្រធានការិយាល័យនាយកដ្ឋានជីវៈចម្រុះ | |
| | សំណួរ ចម្លើយ | | |
| ១០:៣០-១០:៤៥ | **សម្រាកពិសាអាហារសម្រន់** | | |

| ម៉ោង | ប្រធានបទ | វាគ្មិន | អ្នកសម្របសម្រួល |
|---|---|---|---|
| **ប្រធានបទរងទី៣៖ ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ** | | | |
| ១០:៤៥-១១:៣០ | វឌ្ឍនភាពនៃផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា | **លោកបណ្ឌិត ហាក់ ម៉ៅ**<br>ប្រធាននាយកដ្ឋានប្រែប្រួលអាកាសធាតុ | ឯកឧត្តមរដ្ឋលេខាធិការ និងឯកឧត្តមអគ្គលេខាធិការ ក.ជ.អ.ច. |
| | វឌ្ឍនភាពនៃការរួមចំណែករបស់ជាតិដើម្បីអនុវត្តអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ | **លោកបណ្ឌិត ហេង ចាន់ធឿន**<br>អនុប្រធាននាយកដ្ឋានប្រែប្រួលអាកាសធាតុ | |
| | សំណួរ ចម្លើយ | | |
| **ប្រធានបទរងទី៤៖ ការអភិវឌ្ឍសេដ្ឋកិច្ចបៃតង និងវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា** | | | |
| ១១:៣០-១២:១៥ | សមិទ្ធិផលនៃកម្មវិធីទីក្រុងនិរន្តរភាព | **លោក ណុប សុខៃ**<br>អនុប្រធាននាយកដ្ឋានសេដ្ឋកិច្ចបៃតង | ឯកឧត្តមរដ្ឋលេខាធិការ និងឯកឧត្តមអគ្គលេខាធិការ ក.ជ.អ.ច. |
| | ការវាយតម្លៃសក្តានុពលសេដ្ឋកិច្ចនៃថាមពលពន្លឺព្រះអាទិត្យនៅកម្ពុជា | **លោក ម៉ិល សុភា**<br>អនុប្រធានការិយាល័យនៃនាយកដ្ឋានសេដ្ឋកិច្ចបៃតង | |
| | វឌ្ឍនភាពនៃការរៀបចំគោលនយោបាយស្តីពីការប្រើប្រាស់ និងផលិតកម្មដោយនិរន្តរភាព | **លោក តាំង ម៉េងអៀង**<br>ប្រធាននាយកដ្ឋានសេដ្ឋកិច្ចបៃតង | |
| | វឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការក្នុងការប្រើប្រាស់ថាមពលនុយក្លេអ៊ែរសម្រាប់បម្រើក្នុងគោលបំណងសន្តិភាព | **លោក អ៊ួង ប៊ុនណាល់**<br>អនុប្រធាននាយកដ្ឋានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា | |
| | -ក្រមសីលធម៌ និងកម្មវិធីសិក្សាស្រាវជ្រាវថ្នាក់ជាតិ<br>-សហការ និងសម្របសម្រួលការអនុវត្តគម្រោងសិក្សាស្រាវជ្រាវ៖ ១)យុទ្ធសាស្ត្រជាតិក្នុងការគ្រប់គ្រងបរិស្ថាននិងកំណត់តម្លៃសំណល់ និង២)គំរូអភិវឌ្ឍន៍សហគមន៍ប្រកបដោយចីរភាព | **លោក សុខ សីលា**<br>ប្រធានការិយាល័យនៃនាយកដ្ឋានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា | |
| | សំណួរ ចម្លើយ | | |
| ១២:១៥-១២:៣០ | បូកសរុបលទ្ធផល និងសុន្ទរកថាបិទសិក្ខាសាលា | ឯកឧត្តមរដ្ឋលេខាធិការក្រសួងបរិស្ថាន | |

*សម្គាល់៖ របៀបវារៈសិក្ខាសាលាអាចត្រូវកែសម្រួលតាមការចាំបាច់*

**General Secretariat of the National Council for Sustainable Development**

# Annual Workshop
# to Review NCSD 2020 Progress and Develop Work Plan for 2021

**Mok Mareth Meeting Hall, Ministry of Environment, 29 September 2020**

## AGENDA

| Time | Theme | Speaker | Moderator |
|---|---|---|---|
| 7:30-8:30 | Registration | | GSSD/NCSD Admin |
| 8:30-9:00 | National Anthem | **All** | **Ms. Oeurn Pangnavit** Vice Chief Office of Department of Green Economy |
| | Welcome Remarks | **H.E. Vann Monyneath,** Secretary General, General Secretariat of NCSD | |
| | Opening Remarks | **H.E. Say Samal,** Minister of Environment | |
| | Group Photo | **All** | |
| 9:00-9:15 | Coffee Break | | |
| **Agenda Item 1: NCSD Achievement in 2020 Progress and Develop Work Plan for 2021** | | | |
| 9:15-9:45 | NCSD Achievements in 2020<br>- Progress of Cooperation with development partners and Budget<br>- Progress in Implementing the Sustainable Development Goals for the field of Environment and Sustainable Development | Secretary General of NCSD | Secretary of State of MoE |
| | Priorities for 2021 | | |
| **Agenda Item 2: Biodiversity Conservation and Biosafety** | | | |
| 9:45-10:30 | Biodiversity policy development | **Ms. Ken Bopreang,** Director, DBD | **Secretary of State of Moe and Secretary General of NCSD** |
| | Ex-situ Conservation, Research and Biodiversity Information Management Mechanism | **Mr. Chanthy Someta,** Vice Chief Office, DBD | |
| | Question and answer | | |
| 10:30-10:45 | Coffee Break | | |

| Time | Theme | Speaker | Moderator |
|---|---|---|---|
| **Agenda Item 3: Climate Change Response** | | | |
| 10:45-11:30 | Progress of the Cambodia Climate Change Strategic Plan (CCCSP) Implementation | **Dr. Hak Mao**, Director, DCC | **Secretary of State of MoE and Secretary General** |
| | Nationally Determined Contribution (NDC) Update Process | **Dr. Heng Chanthoeun**, Deputy Director, DCC | |
| | Question and Answer | | |
| **Agenda Item 4: Green Economy, and Science and Technology** | | | |
| 11:30-12:15 | Key Achievements of Sustainable Cities | **Mr. Nop Sokhai** Deputy Director, Department of Green Economy | **Secretary of State of MoE and Secretary General of NCSD** |
| | Full Economic appraisal of Potentials of Solar Energy in Cambodia | **Mr. Mel Sophea,** Vice-Chief, Department of Green Economy | |
| | Progress made of Policy Formulation on Sustainable Consumption and Production | **Mr. Taing Meng Eang** Director, Department of Green Economy | |
| | Cooperation on in the Use of Atomic Energy for Peaceful Purposes | **Mr. UONG Bunal** Deputy Director of Science and Technology Department | |
| | - Research Ethics and National Research Agenda for Science and Technology<br>- Cooperate and Coordinate the implementation of Research Study Project: 1. National Pricing Strategy for Waste and Environmental Management<br>2. Sustainable Community Development Model | **Mr. Sok Seyla** Chief of Coordination Policy Office | |
| | Question and Answer | | |
| 12:15-12:30 | Workshop Summary and Closing Remarks | **Secretary of State of MoE** | |

*Note: GSSD-NCSD reserves the right to change the agenda as needed.*

**សិក្ខាសាលាត្រួតពិនិត្យលទ្ធផល**
**ការងារអភិវឌ្ឍន៍ដោយចីរភាពឆ្នាំ២០២០ និងទិសដៅការងារឆ្នាំ២០២១**

# សមិទ្ធិផលការងារឆ្នាំ២០២០ និងទិសដៅការងារឆ្នាំ២០២១

**ឯកឧត្តម វ៉ាន់ មុនីនាថ**
**អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន ក.ជ.អ.ច**

រាជធានីភ្នំពេញ ថ្ងៃអង្គារ ១២កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ត្រូវនឹងថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០

## ការងារអភិវឌ្ឍន៍ដោយចីរភាពឆ្នាំ២០២០ និងទិសដៅការងារឆ្នាំ២០២១

### ១. សមិទ្ធិផលការងារឆ្នាំ ២០២០

- សមិទ្ធិផលរួម
- វឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍
- វឌ្ឍនភាពនៃការអនុវត្តគោលដៅអភិវឌ្ឍន៍ដោយចីរភាពសម្រាប់វិស័យបរិស្ថាន និងការអភិវឌ្ឍនដោយចីរភាព

### ២. ទិសដៅការងារឆ្នាំ ២០២១

2

## ការងារអភិវឌ្ឍន៍ដោយចីរភាពឆ្នាំ២០២០ និងទិសដៅការងារឆ្នាំ២០២១




## ១. សមិទ្ធិផលការងារ

3

## ១. សមិទ្ធិផលការងារឆ្នាំ ២០២០

### សមិទ្ធិផលរួម

... លិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ និងយុទ្ធសាស្ត្រក្នុងវិស័យបរិស្ថាន និងការអភិវឌ្ឍដោយចីរភាព ដោយផ្អែកលើស្ថានភាពជាក់ស្តែង រួមជាមួយទិន្នន័យ និងព័ត៌មានវិទ្យាសាស្ត្រ ដើម្បីលើកកម្ពស់ការអភិវឌ្ឍដោយចីរភាព សំដៅរក្សាបាននូវតុល្យភាពរវាងសេដ្ឋកិច្ច បរិស្ថាន សង្គម និងវប្បធម៌

4

# ១. សមិទ្ធិផលការងារឆ្នាំ ២០២០

## សមិទ្ធិផលរួម

- បានរៀបចំគោលនយោបាយ ស្តីពីការបង់ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី និងផែនទីបង្ហាញផ្លូវសម្រាប់ការងារជីវសុវត្ថិភាព និងសេចក្តីព្រាងក្របខណ្ឌការងារជាតិ ស្តីពីការប្រើប្រាស់ និងការបែងចែកផលប្រយោជន៍ពីការប្រើប្រាស់ធនធានពន្ធុដោយស្មើភាព និងសមធម៌
- បានរៀបចំសេចក្តីព្រាងអនុក្រឹត្យ ស្តីពីវិធាន និងនីតិវិធីចូលរួមក្នុងយន្តការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់
- បានបញ្ចប់សេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពឆ្នាំ ២០២០-២០៣ សម្រាប់ក្រុងកែប ព្រះសីហនុ បាត់ដំបង សៀមរាប កំពង់ចាម សួង និងក្រុងបាវិត

5

# ១. សមិទ្ធិផលការងារឆ្នាំ ២០២០

## សមិទ្ធិផលរួម

- បានរៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រ និងសកម្មភាពសេដ្ឋកិច្ចចក្រា និងយន្តការវាយតម្លៃការសិក្សា ស្រាវជ្រាវនិងចងក្រងទិន្នន័យ ស្តីពីបច្ចេកវិទ្យាសមស្របសម្រាប់ការអនុវត្តនៅកម្ពុជា
- បានបញ្ចប់សេចក្តីព្រាងក្រមសីលធម៌នៃការសិក្សាស្រាវជ្រាវក្នុងកំរិតបច្ចេកទេស និងបានរៀបចំផែនទីបង្ហាញផ្លូវផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
- បានរៀនចំសេចក្តីព្រាងគោលការណ៍ណែនាំ និងបច្ចេកទេស ស្តីពីអគារបៃតង ការិយាល័យបៃតង និងព្រឹត្តិការណ៍បៃតង

6

# ១. សមិទ្ធិផលការងារឆ្នាំ ២០២០

## សមិទ្ធិផលរួម

- បានរៀបចំរបាយការណ៍សមិទ្ធិផលនៃការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពសម្រាប់ វិស័យបរិស្ថាន និងការអភិវឌ្ឍដោយចីរភាព
- បានអនុម័តរបាយការណ៍បច្ចុប្បន្នភាពពីរឆ្នាំម្តង និងដាក់ជូនទៅលេខាធិការដ្ឋានក្របខណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ
- បានធ្វើប្រតិភូកម្មមុខងារជូនដល់រដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈការផ្តល់បច្ចេកទេស និងបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍនៅថ្នាក់ក្រោមជាតិ

7

# ១. សមិទ្ធិផលការងារឆ្នាំ ២០២០

## សមិទ្ធិផលរួម

- បានសិក្សាវាយតម្លៃសេដ្ឋកិច្ចលើសក្តានុពលថាមពលពន្លឺព្រះអាទិត្យនៅកម្ពុជា ការអភិវឌ្ឍបៃតងនៅកម្ពុជា និងផលប៉ះពាល់សេដ្ឋកិច្ច សង្គម និងបរិស្ថាន នៃការអភិវឌ្ឍឧស្សាហកម្មបៃតងនៅកម្ពុជា
- បានរៀបចំប្លង់ និងផែនការមេនៅក្នុងមជ្ឈមណ្ឌលស្រាវជ្រាវនិងអភិរក្សកេសរកូល សុខអាន ភ្នំគូលែន និង
- បានបញ្ចប់សេចក្តីព្រាងស្តីពីសៀវភៅមគ្គុទេសន៍គ្រឿងទេសនៅកម្ពុជា

8

## ១. សមិទ្ធិផលការងារឆ្នាំ ២០២០

### ឧត្តមភាពនៃកិច្ចសហប្រតិបត្តិការជាមួយដៃគូរអភិវឌ្ឍន៍ការប្រែប្រួលអាកាសធាតុ

- អនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC)
- មូលនិធិអាកាសធាតុបៃតង (GCF)
- យន្តការអភិវឌ្ឍន៍ស្អាតនៃ UNFCCC
- មូលនិធិបន្សាំ(Adaptation Fund)
- ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ (IPCC)
- មជ្ឈមណ្ឌលនិងបណ្តាញបច្ចេកវិទ្យាអាកាសធាតុ (CTCN)

9

## ១. សមិទ្ធិផលការងារឆ្នាំ ២០២០

### ឧត្តមភាពនៃកិច្ចសហប្រតិបត្តិការជាមួយដៃគូរអភិវឌ្ឍន៍ការប្រែប្រួលអាកាសធាតុ

- សកម្មភាពកាត់បន្ថយឧស្ម័នសម្រាបថ្នាក់ជាតិ (NAMA)
- ក្រុមការងារអាស៊ានស្តីពីការប្រែប្រួលអាកាសធាតុ (AWGCC)
- យន្តការឥណទានកាបូនរួមគ្នា (JCM)

10

# ១. សមិទ្ធិផលការងារឆ្នាំ ២០២០

## វឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការជាមួយដៃគូរអភិវឌ្ឍន៍

### ការងារជីវៈចម្រុះ

- Global Taxonomy Initiatives
- UN Convention on Biodiversity (UNCBD)
- Nagoya Protocol on Access and Benefit-sharing (ABS)
- Intergovernmental Platform on Biodiversity and Ecosystem Services (IPBES)
- Cartagena Protocol on Biosafety

11

# ១. សមិទ្ធិផលការងារឆ្នាំ ២០២០

## វឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការជាមួយដៃគូរអភិវឌ្ឍន៍

### ការងារជីវៈចម្រុះ

- AWGNCB
- Governing Board of ASEAN Center Biodiversity (ACB)
- Ramsar Convention
- ASEAN Protected Areas Partnership (APAP)
- IUCN Mangrove for Future Programme

12

# ១. សមិទ្ធិផលការងារឆ្នាំ ២០២០

## វឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការជាមួយដៃគូរអភិវឌ្ឍន៍ ការងារសេដ្ឋកិច្ចបៃតង

- UNDP
- GIZ
- GGGI
- SWITCH ASIA (SCP)...

13

# ១. សមិទ្ធិផលការងារឆ្នាំ ២០២០

## វឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការជាមួយដៃគូរអភិវឌ្ឍន៍ ការងារវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា

- UNIDO
- GGGI...

14

# ១. សមិទ្ធិផលការងារឆ្នាំ ២០២០

## វឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការជាមួយដៃគូរអភិវឌ្ឍន៍ ពហុវិស័យ

- SDG
- UNEP
- GEF
- UNESCAPE
- CLMTV, CLMV, CLV, ACMECS
- PEMSEA
- ASEAN
- Mekong Cooperation Framework…

15

# ១. សមិទ្ធិផលការងារឆ្នាំ ២០២០

## វឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការជាមួយដៃគូរអភិវឌ្ឍន៍ គម្រោង/ កម្មវិធី៖ កំពុងអនុវត្ត

- ពង្រឹងការអភិរក្សជីវៈចម្រុះនិងព្រៃស្តុកការបូននៃតំបន់ការពារធម្មជាតិកម្ពុជា តាមរយៈកិច្ចសហការគ្រប់គ្រង និងអនុវត្តបង្ហាញពីការអភិរក្សតំបន់ទេសភាពខាងកើតទន្លេមេគង្គ
- ការរៀបចំបង្កើតក្របខណ្ឌការងារសម្រាប់អនុវត្តអនុវត្តពិធីសារណាហ្គូយ៉ា ស្តីពីការប្រើប្រាស់ និងបែងចែកផលប្រយោជន៍ពីធនធានពន្ធុ
- កាបញ្ជ្រាបការគ្រប់គ្រងធនធានធម្មជាតិទៅក្នុងផលិតភាពធម្មជាតិ និងព្រៃទេសភាព នៅតំបន់ខាងជើង នៃប្រទេសកម្ពុជា

16

# ១. សមិទ្ធិផលការងារឆ្នាំ ២០២០

## ចន្លោនភាពនៃកិច្ចសហប្រតិបត្តិការជាមួយដៃគូរអភិវឌ្ឍន៍

### គម្រោង/ កម្មវិធី៖ កំពុងអនុវត្ត

- កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា ដំណាក់កាលទី៣
- ការកសាងភាពធន់នឹងអាកាសធាតុនៃប្រព័ន្ធទីក្រុងតាមរយៈការបន្សុំាដោយផ្អែកលើប្រព័ន្ធអេកូឡូស៊ីនៅតំបន់អាស៊ីប៉ាស៊ីហ្វិក Ecosystem Based Adaptation (EbA)»
- ព្រៃឡង់បៃតង

17

# ១. សមិទ្ធិផលការងារឆ្នាំ ២០២០

## ចន្លោនភាពនៃកិច្ចសហប្រតិបត្តិការជាមួយដៃគូរអភិវឌ្ឍន៍

### គម្រោង/ កម្មវិធី៖ កំពុងអនុវត្ត

- ការរៀបចំរបាយការណ៍ជាតិលើកទី៣ ក្រោមអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្ដីពីការប្រែប្រួលអាកាសធាតុ
- គម្រោងត្រៀមមូលនិធីអាកាសធាតុបៃតង
- ការកាត់បន្ថយភាពងាយរងគ្រោះនៃជីវភាពរបស់ប្រជាជនកម្ពុជានៅជនបទ តាមរយៈការពង្រឹងផែនការប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិ និងការអនុវត្តសកម្មភាពអាទិភាព

18

## ១. សមិទ្ធិផលការងារឆ្នាំ ២០២០

### វឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការជាមួយដៃគូរអភិវឌ្ឍន៍

**គម្រោង/ កម្មវិធី៖ កំពុងអនុវត្ត**

- ការផ្ទេរបច្ចេកវិទ្យាមេត្រីភាពបរិស្ថាន
- គម្រោងការពង្រឹងសមត្ថភាពដើម្បីបង្កើនតម្លាភាពក្នុងការអនុវត្ត និងតាមដានការរួមចំណែកបស់ថ្នាក់ជាតិដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុក្នុងវិស័យកសិកម្ម និងការប្រើប្រាស់ដី (NDC implementation)
- ជំរុញបរិយាកាសអំណោយផលសម្រាប់ការអភិវឌ្ឍដោយចីរភាព
- និរន្តភាពតំបន់ទេសភាព និងទេសចរណ៍ធម្មជាតិកម្ពុជា

19

## ១. សមិទ្ធិផលការងារឆ្នាំ ២០២០

### វឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការជាមួយដៃគូរអភិវឌ្ឍន៍

**គម្រោង/ កម្មវិធី៖ កំពុងអនុវត្ត**

- ការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ នៃកម្មវិធីយុទ្ធសាស្រ្តសម្រាប់ភាពធន់នឹងអាកាសធាតុ
- គម្រោងស្រាវជ្រាវរៀបចំយុទ្ធសាស្រ្តជាតិក្នុងការគ្រប់គ្រងបរិស្ថាន និងកំណត់តម្លៃសំណល់
- គម្រោងស្រាវជ្រាវការកំណត់គំរូអភិវឌ្ឍន៍សហគមន៍ ប្រកបដោយចីរភាព

20

# ១. សមិទ្ធិផលការងារឆ្នាំ ២០២០

## វឌ្ឍនភាពនៃការអនុវត្តគោលដៅអភិវឌ្ឍន៍ដោយចីរភាព



**គោលដៅ ចំណុចដៅ សូចនាករ CSDGs៖**

- ១៨ គោលដៅ (១៧ គោលដៅសាកល និង ១ គោលដៅជាតិ)
- ៨៨ ចំណុចដៅ (៨៤ ពីសាកលក្នុងចំណោម១៦៩ និងបន្ថែម៤ ចំណុចដៅរបស់ជាតិ)
- ១៤៨ សូចនាករ ដែលរួមមាន (៥៣ សូចនាករសាកល/ ២៣ សូចនាការ ដែលបែងចែកពីសូចនាករដើម/ ៧៣ កែសម្រួល និងសូចនាករថ្មី)

21

# ១. សមិទ្ធិផលការងារឆ្នាំ ២០២០

## វឌ្ឍនភាពនៃការអនុវត្តគោលដៅអភិវឌ្ឍន៍ដោយចីរភាព

**គោលដៅពាក់ព័ន្ធវិស័យបរិស្ថាន និងការអភិវឌ្ឍន៍ដោយចីរភាព**

- **គោលដៅទី២៖** បញ្ចប់ភាពអត់ឃ្លាន សម្រេចឲ្យបានសន្តិសុខស្បៀង ធ្វើឲ្យប្រសើរឡើង ស្ថានភាពអាហារូបត្ថម្ភ និងលើកកម្ពស់កសិកម្មប្រកបដោយចីរភាព
- **គោលដៅទី៦៖** ធានាឲ្យមានទឹកនិងអនាម័យ និងការគ្រប់គ្រងទឹកនិងអនាម័យប្រកប ដោយចីរភាព សម្រាប់ប្រជាជនគ្រប់រូប
- **គោលដៅទី១១៖** ធ្វើឲ្យទីក្រុង និងកន្លែងតាំងទីលំនៅថ្មីសម្រាប់ប្រជាជន មានលក្ខណៈ បរិយាប័ន្ន សុវត្ថិភាព ធន់នឹងបម្រែបម្រួលអាកាសធាតុនិងចីរភាព

22

# ១. សមិទ្ធិផលការងារឆ្នាំ ២០២០

## ឧត្តមភាពនៃការអនុវត្តគោលដៅអភិវឌ្ឍន៍ដោយចីរភាព

### គោលដៅពាក់ព័ន្ធវិស័យបរិស្ថាន និងការអភិវឌ្ឍន៍ដោយចីរភាព

- **គោលដៅទី១២៖** ធានាឲ្យមានចីរភាពក្នុងទម្រង់នៃការប្រើប្រាស់និងផលិតកម្ម
- **គោលដៅទី១៣៖** ចាត់វិធានការជាបន្ទាន់ ដើម្បីប្រយុទ្ធប្រឆាំងនឹងបម្រែបម្រួលអាកាសធាតុ និងផលប៉ះពាល់របស់វា
- **គោលដៅទី១៤៖** អភិរក្សនិងប្រើប្រាស់ប្រកបដោយចីរភាពនូវ មហាសមុទ្រ សមុទ្រ និងធនធានសមុទ្រ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព

23

# ១. សមិទ្ធិផលការងារឆ្នាំ ២០២០

## ឧត្តមភាពនៃការអនុវត្តគោលដៅអភិវឌ្ឍន៍ដោយចីរភាព

### គោលដៅពាក់ព័ន្ធវិស័យបរិស្ថាន និងការអភិវឌ្ឍន៍ដោយចីរភាព

- **គោលដៅទី១៥៖** ការពារ ស្តារ និងជំរុញការប្រើប្រាស់ប្រកបដោយចីរភាពនូវប្រព័ន្ធអេកូឡូស៊ីនៅលើដែនគោក គ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព ប្រយុទ្ធប្រឆាំងនឹងឱនភាពដី បញ្ឈប់និងបង្វែរទិសនៃការសឹករេចរឹលគុណភាពដី និងបញ្ឈប់កុំឲ្យបាត់បង់ជីជាតិដីនិងជីវចម្រុះ

24

# ១. សមិទ្ធិផលការងារឆ្នាំ ២០២០

## វឌ្ឍនភាពនៃការអនុវត្តគោលដៅអភិវឌ្ឍន៍ដោយចីរភាព




25

# ១. សមិទ្ធិផលការងារឆ្នាំ ២០២០

## វឌ្ឍនភាពនៃការអនុវត្តគោលដៅអភិវឌ្ឍន៍ដោយចីរភាព

### ទិសដៅបន្ត

- រាជរដ្ឋាភិបាលកម្ពុជាមានឆន្ទៈខ្ពស់ក្នុងការសម្រេចរបៀបវារៈ២០៣០ និងប្រកាន់ខ្ជាប់នូវគោលការណ៍រួម ពុំមានទុកអ្នកណាម្នាក់ចោល ដែលដឹកនាំដោយសហប្រជាជាតិ
- បន្ត និងតម្រូវឱ្យមានការចូលរួមពីគ្រប់ភាគី ទាំងវិស័យឯកជន អង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋ
- បញ្ជ្រាបក្នុងប្រព័ន្ធគោលនយោបាយ និងផែនការនៅគ្រប់កម្រិត ជាពិសេសថ្នាក់ក្រោមជាតិ
- ត្រូវការធនធានបន្ថែមលើថវិកាជាតិ ជាពិសេសពីវិស័យឯកជនដើម្បីសម្រេចគោលដៅ

26

## ការងារអភិវឌ្ឍន៍ដោយចីរភាពឆ្នាំ២០២០ និងទិសដៅការងារឆ្នាំ២០២១




# ២. ទិសដៅការងារ

27

## ២. ទិសដៅការងារឆ្នាំ ២០២០

- បន្តជំរុញការដាក់បញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងគោលនយោបាយ និងការវិភាជន៍ថវិកាគ្រប់លំដាប់ថ្នាក់ និងបន្តកៀរគជនធាននិងបច្ចេកវិទ្យាសមស្រប
- បន្តសហការជាមួយមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី តេជោ៖ កិច្ចសហប្រតិបត្តិការ អាទិភាពការងាររួមគ្នា និងគម្រោងគាំទ្រដាក់ស្តែង
- មជ្ឈមណ្ឌលគោល នយោបាយ យុទ្ធសាស្ត្រ និងនវានុវត្តន៍
- បន្តរៀបចំគោលនយោបាយស្តីពីការបង់ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី និងផែនទីបង្ហាញផ្លូវសម្រាប់ ការងារជីវសុវត្ថិភាព និងសេចក្តីព្រាងក្របខណ្ឌការងារជាតិស្តីពីការប្រើប្រាស់ និងការបែងចែកផល ប្រយោជន៍ពីការប្រើប្រាស់ធនធានពន្ធុដោយស្មើភាព និងសមធម៌

28

**សិក្ខាសាលា**
**ត្រួតពិនិត្យលទ្ធផលការងារអភិវឌ្ឍន៍ដោយចីរភាពឆ្នាំ២០២០ និងទិសដៅការងារឆ្នាំ២០២១**

រាជធានីភ្នំពេញ ថ្ងៃអង្គារ ១២កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ត្រូវនឹងថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០

# វឌ្ឍនភាពនៃការរៀបចំគោលនយោបាយពាក់ព័ន្ធនឹងជីវៈចម្រុះ

រៀបចំដោយ៖ លោកស្រី កែន បូព្រាង ប្រធាននាយកដ្ឋានជីវៈចម្រុះ



## មាតិកា



លទ្ធផលសម្រេចបាន និងផែនការបន្ត



បញ្ហាប្រឈម



សំណើដំណោះស្រាយ

2

## ក. លទ្ធផលសម្រេចបាន និងផែនការបន្ត

**លទ្ធផលសម្រេចបាន**

១. យុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីជីវៈចម្រុះ
២. របាយការណ៍ជាតិលើកទី៦
៣. សេចក្តីព្រាងក្រមបរិស្ថាន និងធនធានធម្មជាតិ (គន្ថីទី៣)
៤. សេចក្តីព្រាងការរៀបចំគោលគំនិត និងក្របខណ្ឌការងារស្តីពី PES
៥. សេចក្តីព្រាងក្របខណ្ឌការងារថ្នាក់ជាតិស្តីពី ABS
៦. ការសិក្សាលើលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការអនុវត្តការងារជីវសុវត្ថិភាព




3

## ក. លទ្ធផលសម្រេចបាន និងផែនការបន្ត

៧. សេចក្តីជូនដំណឹង (សជណ)
ក. GMO/LMO
ខ. សួនភូគព្ភសាស្ត្រ (Geopark)
គ. កេសរកូល



4

# ក. លទ្ធផលសម្រេចបាន និងផែនការបន្ត

៨. អនុស្សារណៈយោគយល់គ្នា (MoU) ចំនួន ៥៖

ក. សារមន្ទីរប្រវត្តិសាស្ត្រធម្មជាតិប្រទេសបារាំងលើការអភិរក្សក្រៅដែនធម្មជាតិនៅកម្ពុជា

ខ. អង្គការផ្តោតលើសត្វព្រៃកម្ពុជាលើការកសាងសមត្ថភាពលើការគ្រប់គ្រង និងអភិរក្សធនធានជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី

គ. Korea National Arboretum ប្រទេសកូរ៉េ លើការអភិរក្សជីវៈចម្រុះ ប្រព័ន្ធអេកូឡូស៊ី និងការគ្រប់គ្រងតំបន់ការពារធម្មជាតិនៅកម្ពុជា

5

# ក. លទ្ធផលសម្រេចបាន និងផែនការបន្ត

ឃ. សួនរុក្ខឧទ្យាន Kew ប្រទេសអង់គ្លេស លើការបង្កើត និងដំណើរការការអភិរក្សក្រៅដែនធម្មជាតិនៅកម្ពុជា

ង. IUCN លើកិច្ចសហប្រតិបត្តិការពាក់ព័ន្ធនឹងទឹក ស្បៀង ថាមពល អាកាសធាតុ និងជីវៈចម្រុះ




6

# ក. លទ្ធផលសម្រេចបាន និងផែនការបន្ត

**ផែនការបន្ត**

ក. ពិនិត្យឡើងវិញ និងធ្វើឱ្យបន្ទុគ្នានៃខ្លឹមសារក្រមបរិស្ថាន និងធនធានធម្មជាតិពាក់ព័ន្ធនឹងជីវៈចម្រុះ ប្រព័ន្ធអេកូឡូស៊ី និងជីវសុវត្ថិភាពជាមួយនឹងផ្នែកផ្សេងៗទៀត

ខ. រៀបចំបញ្ចប់សេចក្តីព្រាងការរៀបចំគោលគំនិត និងក្របខ័ណ្ឌការងារស្តីពី PES និងយន្តការអនុវត្តសាកល្បង

គ. រៀបចំបញ្ចប់សេចក្តីព្រាងក្របខ័ណ្ឌការងារជាតិស្តីពី ABS និងនីតិវិធីអនុវត្ត

ឃ. បន្តអនុវត្តខ្លឹមសារ សជណ ស្តីពី (១)LMO/GMO (២)សារមន្ទីរប្រវត្តិសាស្ត្រធម្មជាតិ និង (៣)GEO Park

ង. រៀបចំបញ្ចប់សេចក្តីព្រាង MOU ជាមួយ (១) Kew ប្រទេសអង់គ្លេស (២) IUCN

ច. បញ្ជ្រាបនិងផ្សព្វផ្សាយ NBSAP ទៅក្នុងវិស័យពាក់ព័ន្ធ

7

# ខ. បញ្ហាប្រឈម

ក. ចំណេះដឹងនិងជំនាញនៅមានកម្រិតលើការរៀបចំគោលនយោបាយ ក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

ខ. កង្វះមន្ត្រីជំនាញផ្នែកច្បាប់ គោលនយោបាយ និងកិច្ចចរចារពាក់ព័ន្ធ

គ. ការយល់ដឹងរបស់ស្ថាប័នពាក់ព័ន្ធនិងសាធារណជននៅមានកម្រិតលើការងារ ABS, PES, GMO/LMO …

ឃ. ការចូលរួមរបស់វិស័យឯកជននៅមានកម្រិតលើការងារ ABS, PES, GMO/LMO …

ង. ការងារ ABS, PES, GMO/LMO …ជាទស្សនទានថ្មី សម្រាប់ការងារអភិរក្សជីវៈចម្រុះ

ឃ. ថវិកាជាតិមានកំណត់សម្រាប់អនុវត្តការងារពាក់ព័ន្ធនឹងអាណត្តិរបស់នាយកដ្ឋានដូចជា ការរៀបចំគោលនយោបាយ ក្របខ័ណ្ឌច្បាប់ យុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្ត ។ល។

8

# ខ. បញ្ហាប្រឈម

**បញ្ហាពាក់ព័ន្ធ**

ក. ការរាលដាលនៃជំងឺកូវីត ១៩ (កម្រិតការចំណាយ ការចុះអនុវត្តការងារ និងសេដ្ឋកិច្ច)

ខ. មានការចំណាយពេលវេលាច្រើនក្នុងការប្រាស្រ័យទាក់ទងជាមួយស្ថាប័ននិងអ្នកពាក់ព័ន្ធ









# គ. សំណើដំណោះស្រាយ

ក. បណ្តុះបណ្តាលធនធានមនុស្សបន្ថែម (កំណត់និងរៀបចំវគ្គបណ្តុះបណ្តាលលើជំនាញខ្វះខាត)

ខ. ស្វែងរកប្រភពមូលនិធិ និងកៀរគរធនធានហិរញ្ញវត្ថុសម្រាប់អនុវត្តការងារនាយកដ្ឋាន

គ. បញ្ជ្រាបនិងជំរុញលើកទឹកចិត្តដល់ការអនុវត្ត ស.ជណ (PES, GMO/LMO)

ឃ. បន្តអនុវត្តការងារពាក់ព័ន្ធនឹងអាណត្តិរបស់នាយកដ្ឋានដូចជា ការរៀបចំគោលនយោបាយ ក្របខ័ណ្ឌច្បាប់ យុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្ត ។ល។



# សូមអរគុណ!

# ANNUAL WORKSHOP TO REVIEW NCSD 2020 PROGRESS AND 2021 PLAN

Phnom Penh, 29 September 2020

Mok Mareth Hall, Ministry of Environment, Phnom Penh

## Biodiversity Policy Development

**Presented by: Ms KEN Bopreang, Director of Department of Biodiversity/GSSD**



## Content



Achievements and Way Forwards



Issues and Challenges



Proposed Solotions

2

## A. Achievements and Way Forwards

### Achievements

1. NBSAP-2016;
2. The 6th National Report to the UN-CBD;
3. Draft Environment and Natural Resource Code ( Book 3 );
4. Draft PES Conceptual Design and Framework;
5 Draft ABS National Framework;
6. Proposed segments for Biosafety-related laws and regulations;




3

## A. Achievements and Way Forwards

7. Notifications ( សជណ )
   a. GMO/LMO
   b. Geopark
   c. Orchid



4

## A. Achievements and Way Forwards

8. MoUs ( 5 )

a. MoU on Collaboration for Establishment and Operation of Ex-situ Conservation in Cambodia between The Museum national d'histore naturalle and GSSD

b. MoU on Capacity Building for Biodiversity and Ecosystem Conservation between Fauna in Focus and GSSD

c. MoU on Cooperation on Biodiversity and Ecosystem Conservation and Protected Areas Management in Cambodia between Korea National Arboretum and GSSD

5

## A. Achievements and Way Forwards

d. MoU on Collaboration for Establishment and Operation of Ex-situ Conservation in Cambodia between the Board of Trustees of the Royal Botanic Gardens, Kew, UK and GSSD

e. MoU on Cooperation on Water, Food, Energy, Climate Change and Biodiversity between IUCN and GSSD




6

## A. Achievements and Way Forwards

### Way forwards

a. Review the segments of biodiversity, ecosystems and biosafety in Environment and Natural Resource Codes and make sure they are consistent with other segments in other chapters;

b. Finalize National PES Framework;

c. Finalize National ABS Framework;

d. Carry out the work based on the contents in Notification (សជណ) on (1) LMO/GMO, (2) Natural historical museum and (3) GeoPark

e. Finalize MOUs with (1) Kew of UK, and (2) IUCN;

f. Mainstream and disseminate NBSAP into relevant sectors



## B. Issues and Challenges

### Human Resources

a. Technical capacity of the officials is limited to develop policies and provisions;

b. Limited number of legal, policy experts and negotiations;

c. Limited understanding of relevant institutions and the public on ABS, PES, LMO/GMO…

d. Limited involvement of the private sector in ABS, PES, GMO/GMO…;

e. ABS, PES, GMO/LMO … are new concepts for biodiversity conservation;

f. Limited funds for application of the DBD mandate such as policy development, framework, strategies and legal instrument etc.

## B. Issues and Challenges

### Related issues

a. Covid-19 outbreak (limiting the expenditure, work mission and economy); and

b. It is time-consuming to communicate with relevant stakeholders to carry out the work







9

## C. Proposed Solutions

a. Carry out more capacity building (Tailor and carry out training sessions on the needed skills/expertise);

b. Resource mobilization to carry out Department work;

c. Mainstream and encourage application of Notification (សជណ) (on PES, GMO/LMO); and

d. Carry out work related to the mandate of the department such as development of policy, framework, strategy and legal instrument, etc.

10


Thank you!
https://ncsd.moe.gov.kh
General Secretariat of
National Council for Sustainable Development

**សិក្ខាសាលា**

**ត្រួតពិនិត្យលទ្ធផលការងារអភិវឌ្ឍន៍ដោយចីរភាពឆ្នាំ២០២០ និងទិសដៅការងារឆ្នាំ២០២១**

រាជធានីភ្នំពេញ ថ្ងៃអង្គារ ១២កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ត្រូវនឹងថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០

# ការអភិរក្សក្រៅដែនធម្មជាតិ ការសិក្សាស្រាវជ្រាវ និងយន្តការគ្រប់គ្រងព័ត៌មានជីវៈចម្រុះ

រៀបចំដោយ៖ លោក ចន្ធី សុមេត្តា អនុប្រធានការិយាល័យ



## មាតិកា

**១. លទ្ធផលសម្រេចបាន និងផែនការបន្ត របស់៖**

- ការអភិរក្សក្រៅដែនធម្មជាតិ
- ការសិក្សាស្រាវជ្រាវ
- យន្តការគ្រប់គ្រងព័ត៌មានជីវៈចម្រុះ

**២. បញ្ហាប្រឈម**

**៣. សំណើដំណោះស្រាយ**



2

## ១. លទ្ធផលសម្រេចបាន



### ការអភិរក្សក្រៅដែនធម្មជាតិ

1. បានរៀបចំ និងថែទាំសំណាកសត្វ និងរុក្ខជាតិ ដែលកំពុងតាំងបង្ហាញ នៅក្រសួងបរិស្ថាន
2. បានប្រមូលសំណាកកេសរកូលព្រៃ បានចំនួន១៧០ប្រភេទ ប៉ប្រេក និងស្លែ បាន១៣ប្រភេទ ។ មជ្ឈមណ្ឌលប្រមូលបានប្រមូលសំណាកសរុបប្រមាណ ២០០០ដើម
3. ដាក់ស្លាកព័ត៌មាន (Label) ក្នុងសួនកេសរកូលព្រៃ និងថ្នាលបណ្ដុះ បានចំនួន១៣០០ ស្លាក
4. បានបង្កើតក្រុមការងារបច្ចេកទេសរៀបចំប្លង់មេរបស់មជ្ឈមណ្ឌល និង បានប្រជុំក្រុមការងារបច្ចេកទេសលើកទី២ និងប្រជុំបច្ចេកទេសចំនួន ៤លើក

3

## ១. លទ្ធផលសម្រេចបាន (ត)

5. បានរៀបចំវេទិកាកេសរកូលជាតិលើកទី១ មានអ្នកចូលរួមជាតំណាងក្រសួង ស្ថាប័ន ស្ថានទូត អង្គការដៃគូ វិស័យឯកជន អ្នកជំនាញជាតិ និងអន្តរជាតិ សាធារណជន សិស្ស និស្សិត និងអ្នកពាក់ព័ន្ធប្រមាណ៥០០នាក់
6. បានចុះសិក្សាតំបន់ដើម្បីរៀបចំផែនទីរួម ដើម្បីរៀបចំផែនការមេរបស់មជ្ឈមណ្ឌល ចំនួន ២លើក និងត្រួតពិនិត្យដំណើរការសាងសង់ចំនួន ៥លើក
7. បានរៀបចំហេដ្ឋារចនាសម្ព័ន្ធមជ្ឈមណ្ឌល រួមមាន សួនកេសរកូលបង្ហាត់ និងសួនមេអំបៅ ហាងកាហ្វេ សហការដើម្បីដាំកូនឈើធ្វើជារបងជុំវិញមជ្ឈមណ្ឌល សម្របសម្រួល ដើម្បីតម្លើង Solar Panel និងឈូសឆាយចំណតរថយន្តលើកទី១






4

## ១. លទ្ធផលសម្រេចបាន (ត)

### ការសិក្សាស្រាវជ្រាវ

1. ការងាររៀបចំចងក្រងសៀវភៅមគ្គុទេសក៍គ្រឿងទេសនៅកម្ពុជា
2. ប្រមូលព័ត៌មាន និងទិន្នន័យសម្រាប់ធ្វើបញ្ជីឈ្មោះសត្វព្រៃ និងរុក្ខជាតិនៅក្នុងតំបន់ការពារធម្មជាតិ ក្នុងភូមិសាស្ត្រខេត្តមណ្ឌលគិរី
3. ការងាររៀបចំបញ្ជីប្រភេទកេសកូល និងបោះពុម្ពសៀវភៅមគ្គុទេសន៍កេសរកូល ភាគ១
4. សហការជាមួយនាយកដ្ឋានអភិរក្សតំបន់ការពារធម្មជាតិដីគោកខាងកើតទន្លេមេគង្គ និងអង្គការ WWF បានធ្វើការសិក្សាពីទ្រទំរបស់សត្វត្រយងចង្កឹកស ដែលជាប្រភេទសត្វស្លាបជិតផុតពូជបំផុតជាសកល (Critically Endangered) នៅក្នុងតំបន់ការពារធម្មជាតិទាំងប្រាំក្នុងខេត្តមណ្ឌលគិរី



5

## ១. លទ្ធផលសម្រេចបាន (ត)



### យន្តការគ្រប់គ្រងព័ត៌មានជីវៈចម្រុះ

1. ថែរក្សា និងចែករំលែកទិន្នន័យស្តីពីជីវៈចម្រុះ
2. ប្រមូល និងចងក្រងទិន្នន័យស្តីពីជីវៈចម្រុះពីអង្គការដៃគូ និងមន្ទីរបរិស្ថាន
3. សម្របសម្រួលរៀបចំបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យជីវៈចម្រុះថ្នាក់ជាតិ
4. ផ្លាស់ប្តូរអាសយដ្ឋានគេហទំព័រពី http://www.chm.gdancp-moe.org/ ទៅក្រោម domain របស់ក្រសួងបរិស្ថាន http://chm-ncsd.moe.gov.kh/
5. សម្របសម្រួលរៀបចំ និងផ្សព្វផ្សាយព័ត៌មានស្តីពីវេទិកាកេសរកូលជាតិ លើកទី១ និងយុទ្ធនាការនៃទិវាជីវៈចម្រុះអន្តរជាតិឆ្នាំ២០២០
6. រៀបចំយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទងសម្រាប់តំបន់ការពារធម្មជាតិ
7. ផ្សព្វផ្សាយព័ត៌មានការងារ របាយការណ៍ជាតិ និងឯកសារពាក់ព័ន្ធចំនួន៣២លើក
8. ផ្សព្វផ្សាយព័ត៌មានពីគេហទំព័រCHM ដល់សាធារណជន និងអ្នកពាក់ព័ន្ធបានចំនួន៥លើក
9. សម្របសម្រួលរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងទិន្នន័យរបស់GBIF

*អាសយដ្ឋានគេហទំព័រយន្តការសម្របសម្រួលនិងផ្លាស់ប្តូរព័ត៌មាន ៖ http://chm-ncsd.moe.gov.kh/* 6

# ១. ផែនការបន្ត

## ផែនការបន្ត

1. បោះពុម្ព និងផ្សព្វផ្សាយពីសៀវភៅមគ្គុទេសក៍គ្រឿងទេសនៅកម្ពុជា
2. បោះពុម្ពបញ្ជីឈ្មោះសត្វព្រៃ និងរុក្ខជាតិនៅក្នុងតំបន់ការពារធម្មជាតិ ក្នុងភូមិសាស្ត្រខេត្តមណ្ឌលគិរី
3. រៀបចំបញ្ជីប្រភេទកេសរកូល និងបោះពុម្ពសៀវភៅមគ្គុទេសន៍កេសរកូល ភាគ២
4. បន្តសិក្សា និងរៀបចំប្លង់មេរបស់មជ្ឈមណ្ឌលស្រាវជ្រាវ និងអភិរក្សកេសរកូល សុខ អាន ភ្នំគូលែន និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗរបស់មជ្ឈមណ្ឌល
5. បន្តប្រមូល និងរៀបចំសំណាកសត្វ និងរុក្ខជាតិ ដើម្បីរក្សាទុក និងត្រៀមរៀបចំបង្កើតសារៈមន្ទីរប្រវត្តិសាស្ត្រធម្មជាតិភ្នំពេញ និងផ្សព្វផ្សាយដល់សាធារណជន
6. បន្តរៀបចំកែសម្រួលលើទម្រង់-រចនាសម្ព័ន្ធ និងខ្លឹមសារ គេហទំព័រCHM ព្រមទាំងបញ្ចូលព័ត៌មាន និងទិន្នន័យថ្មីៗសម្រាប់ ធ្វើការផ្សព្វផ្សាយដល់សាធារណជនទូទៅ
7. បន្តការសិក្សាស្រាវជ្រាវប្រភេទសត្វ និងរុក្ខជាតិ និងប្រមូលទិន្នន័យជីវៈចម្រុះពាក់ព័ន្ធដើម្បី ចងក្រងជាប្រព័ន្ធទិន្នន័យជីវៈចម្រុះថ្នាក់ជាតិ
8. សិក្សាលទ្ធភាពពីសក្តានុពលក្នុងការរៀបចំបង្កើតសួនភូគព្ភសាស្ត្រនៅកម្ពុជា។




7

# ២. បញ្ហាប្រឈម

- ទិន្នន័យជីវៈចម្រុះត្រូវបានរក្សាទុកដោយក្រសួង ស្ថាប័ន អង្គការ អ្នកសិក្សាស្រាវជ្រាវ ។ល។ និងមិនមានទម្រង់ប្រមូល និងរក្សាទុកទិន្នន័យស្តង់ដារ
- មិនមានធនធានមនុស្សគ្រប់គ្រាន់លើផ្នែកទិន្នន័យជីវៈចម្រុះ (Database) សិក្សាស្រាវជ្រាវលើប្រភេទសត្វនិងរុក្ខជាតិ កំណត់អត្តសញ្ញាណប្រភេទ ជាលិការវប្បកម្ម ។ល។
- ថវិកាក្នុងការចុះសិក្សាស្រាវជ្រាវនៅមានកម្រិត
- ការចូលរួមរបស់វិស័យឯកជនលើការអភិរក្សជីវៈចម្រុះ និងគាំទ្រដល់ដំណើរការមជ្ឈមណ្ឌល
- ការអប់រំផ្សព្វផ្សាយជាមួយសាធារណជននៅមានកម្រិត

8

# ៣. សំណើដំណោះស្រាយ

- រៀបចំទម្រង់ប្រមូលទិន្នន័យជីវៈចម្រុះស្តង់ដារ សម្រាប់ប្រើប្រាស់ក្នុងក្រសួងស្ថាប័ន និងអង្គការពាក់ព័ន្ធ
- រៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យជីវៈចម្រុះជាតិ ធ្វើបច្ចុប្បន្នភាពទិន្នន័យនិងព័ត៌មាន និងផ្សព្វផ្សាយពីគេហទំព័រ http://chm-ncsd.moe.gov.kh/ ដល់សាធារណជនឱ្យបានទូលំទូលាយ
- ស្នើសុំមន្ត្រីជំនាញព័ត៌មានវិទ្យា និងគ្រប់គ្រងទិន្នន័យ សិក្សាស្រាវជ្រាវ កំណត់អត្តសញ្ញាណប្រភេទ ជាលិកាវប្បកម្ម
- សហការ និងកៀរគរថវិកាពីដៃគូពាក់ព័ន្ធ ក្រៅពីថវិកាជាតិ
- ជំរុញ និងលើកទឹកចិត្តឱ្យមានការចូលរួមពីវិស័យឯកជន លើការអភិរក្សជីវៈចម្រុះ និងសហការអភិវឌ្ឍន៍ ដើម្បីគាំទ្រដល់ដំណើរការមជ្ឈមណ្ឌល
- អប់រំផ្សព្វផ្សាយជាមួយសាធារណជនឱ្យបានទូលំទំលាយតាមរយៈកិច្ចប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងមធ្យោបាយផ្សេងៗទៀត

9



**ANNUAL WORKSHOP TO REVIEW NCSD 2020 PROGRESS AND 2021 PLAN**

Phnom Penh, 29 September 2020

Mok Mareth Hall, Ministry of Environment, Phnom Penh

# Ex-situ Conservation, Research and Biodiversity Information Management Mechanism

**Presented by: Mr. Chanthy Someta, Department of Biodiversity/GSSD**



## Contents

1. **Achievements and ways forwards**
   - *Ex-situ* conservation
   - Research
   - CHM
2. **Issues and challenges**
3. **Proposed solutions**



2

## 1. Achievements



### *Ex-situ* conservation

1. Managed and displayed fauna and flora specimens at the corridor of MoE as well as in Department of Biodiversity;
2. Collected 140 wild orchid species; 13 fern and moss species. The center managed to collect about 2000 plants
3. Labelled wild orchid species in orchid center (1300 labels);
4. Established a technical working group for designing the center master plans and the two TWG meetings were conducted and 4 technical meetings held.

3

## 1. Achievements (Cont.)

5. Conducted the First National Orchid Forum attended by 500 representatives of ministries, embassies, NGOs, private sector, national and international consultants, the public, students and stakeholders;
6. Conducted 2 field studies in the orchid center to develop the master map, Sok An Phnom Kulen Orchid Research and Conservation Center and 5 field missions to see the center construction processes; and
7. Developed Orchid Center infrastructure, including orchid hybrid and butterfly parks, café, planted young trees along the borders to the center, installed solar panels and prepared areas for vehicle parks






4

## 1. Achievements (Cont.)

### Research

1. Prepared and developed spice guide in Cambodia;
2. Collected information and data for the development of flora and fauna inventory in Pas in Mondulkiri province;
3. Listed orchid species and prepared and developed Orchid Guide, Part 1;
4. Conducted survey on the habitat of critically endangered White-shouldered Ibis in Pas in Mondulkiri in cooperation with Department of Terrestrial Protected Areas Conservation of Eastern Mekong and WWF



5

## 1. Achievements (Cont.)



### CHM

1. Maintained and shared biodiversity-related data;
2. Gathered and compiled biodiversity data from partner organizations and provincial Departments of Environment;
3. Coordinated the development of National Biodiversity Information Management System;
4. Replaced website of http://www.chm.gdancp-moe.org/ with a domain of MoE http://chm-ncsd.moe.gov.kh/
5. Facilitated and disseminated the information on the First National Orchid Forum and International Day for Biological Diversity 2020
6. Developed a communication strategy for PAs;
7. Shared work-related information, the national report and relevant documents in 32 occasions;
8. Shared CHM with the public and stakeholders in 5 occasions;
9. Facilitated the capacity building on Data Management of GBIF

អាសយដ្ឋានគេហទំព័រយន្តការសម្របសម្រួលនិងផ្លាស់ប្តូរព័ត៌មាន៖ http://chm-ncsd.moe.gov.kh/ 6

# 1. Next Plan

## Next Plan

1. Publish the guide book on spices in Cambodia
2. Publish the list of wild plants and animals species in PAs in Mondulkiri
3. Compile the list of orchid species and publish the guide book on orchid Volume 2
4. Design the Master Plan for Sok An Phnom Koulen Research and Conservation Centre and build the necessary infrastructures for operation
5. Continue to collect and make plants and animals specimen to conserve for research, preparation for the establishment of Phnom Penh Natural Historical Museum and display for public awareness
6. Continue to update the interface and content of CHM and entry new data/information for public access
7. Continue to conduct plants and animals species research and collect biodiversity data to store as the national biodiversity data
8. Feasibility study on the potentials in establishing the Geopark in Cambodia.




7

# 2. Issues and challenges

- Biodiversity-related data is managed and operated by individual ministry, organization, researcher and so on and is not collected and operated based on a standardized format;
- Limited human resources on database, study on flora and fauna species, identification of species, tissue culture etc.
- Limited budgets for field surveys;
- Limited involvement of private sector in biodiversity conservation and supporting the Orchid center; and
- Limited dissemination of biodiversity- and ecosystem-related information to the public

8

## 3. Proposed Solutions

- Develop a standardized system to collect biodiversity information by the ministries and relevant organizations;
- Develop and operate the biodiversity management system, feed it with updated information and data and disseminate http://chm-ncsd.moe.gov.kh/ to the public as widely as possible;
- Propose to have an expert officials on IT and data management, research, species identification, tissue culture etc.
- Mobilize the funds from the partners to supplement the national budgets for work implementation;
- Promote and encourage involvement from the private sector in biodiversity conservation and work with the partners to support the operations and management of the center; and
- Disseminate the information to the public as widely as possible via meetings, workshops, and other means

9



**សិក្ខាសាលា**

**ត្រួតពិនិត្យលទ្ធផលការងារអភិវឌ្ឍន៍ដោយចីរភាពឆ្នាំ២០២០ និងទិសដៅការងារឆ្នាំ២០២១**

រាជធានីភ្នំពេញ ថ្ងៃអង្គារ ១២កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ត្រូវនឹងថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០

# ប្រធានបទ៖ វឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា

**រៀបចំដោយ៖** លោកបណ្ឌិត **ហាក់ ម៉ៅ** ប្រធាននាយកដ្ឋានប្រែប្រួលអាកាសធាតុ
នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព( GSSD )



# មាតិកា

១ ) អំពីផែនការ
២ ) ទិសដៅជាយុទ្ធសាស្ត្រ
៣ ) សកម្មភាព
៤ ) សូចនាករ ( Readiness Indicator )
៥ ) សូចនាករ ( Impact Indicator )
៦ ) បញ្ហាប្រឈមនិងចក្ខុវិស័យអនាគត

## ១)ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា

• បានរៀបចំឡើងក្នុងឆ្នាំ២០១៣ (២០១៤ដល់ឆ្នាំ២០២៣)

• **<u>ចក្ខុវិស័យ៖</u>**

កម្ពុជាអភិវឌ្ឍឆ្ពោះទៅរកសង្គមមួយដែលបៃតង បញ្ចេញកាបូនតិច ធន់នឹងការប្រែប្រួលអាកាសធាតុ សមធម៌ ចីរភាពនិងពឹងផ្អែកលើចំណេះដឹងជាគោល។

## ១)ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា

• **<u>គោលបំណង៖</u>**

- កាត់បន្ថយភាពងាយរងគ្រោះដែលបណ្តាលមកពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុជូនដល់របស់ប្រជាជន ជាពិសេសក្រុមអ្នកងាយរងគ្រោះ

- បង្វែរទៅរកមាគ៌ាអភិវឌ្ឍន៍បៃតង តាមរយៈការលើកកម្ពស់ការអភិវឌ្ឍបញ្ចេញកាបូនតិច និងបច្ចេកវិទ្យាពាក់ព័ន្ធ

- លើកម្ពស់ការយល់ដឹង និងការចូលរួមរបស់សាធារណជន ក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ

## ២)ទិសដៅជាយុទ្ធសាស្ត្រ




មានបរិយាយលំអិតនៅក្នុងទិសដៅយុទ្ធសាស្ត្រទាំង៨របស់ផែនការ។

## ៣)សកម្មភាព៖រយៈពេលខ្លី (២០១៣–២០១៤)

| សកម្មភាព | ការពិនិត្យតាមដាននៅពាក់កណ្តាលវដ្តផែនការ | បច្ចុប្បន្នភាព |
|---|---|---|
| ១.ចាត់ចែងស្ថាប័ន និងហិរញ្ញវត្ថុ | ១.នាយកដ្ឋានប្រែប្រួលអាកាសធាតុត្រូវបានរៀបចំរចនាសម្ព័ន្ធអោយមានលក្ខណ:ពេញលេញដែលមានបែងចែកទៅតាមការិយាល័យដោយប្រើប្រាស់នូវថវិកាជាតិ | |
| ២.កសាងផែនការសកម្មភាព | ២.ក្រសួងចំនួន១៤បានរៀបចំនិងអនុវត្តផែនការសកម្មភាពដាច់ដោយឡែកសំរាប់ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ (២០១៤–២០១៨) | ២.មានក្រសួងចំនួន៣ដែលកំពុងបន្តរៀបចំផែនការសកម្មភាព (២០២០–២០២៣និងក្រសួងផ្សេងទៀតនឹងធ្វើការដាក់បញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងផែនការតាមវិស័យ |

## ៣)សកម្មភាព៖រយៈពេលមធ្យម(២០១៤–២០១៨)

| សកម្មភាព | ការពិនិត្យតាមដាននៅពាក់កណ្តាលវដ្ត ផែនការ | បច្ចុប្បន្នភាព |
|---|---|---|
| ១.រៀបចំយន្តការទទួលបានមូលនិធិ បន្សាំនិងមូលនិធិអាកាសធាតុបៃតង | យន្តការត្រូវបានរៀបចំ | បាននិងកំពុងរៀបចំកម្មវិធីជាតិសំរាប់មូលនិធិអាកាសធាតុបៃតង ដោយមានក្រសួងបរិស្ថានជា NDA និង NCDD ត្រូវបានទទួលស្គាល់ជា Direct Access Entity |
| ២.ការស្រាវជ្រាវ និងការគ្រប់គ្រងចំណេះដឹងការអភិវឌ្ឍ សមត្ថភាព | បង្កើតភាពជាដៃគូជាមួយសាកលវិទ្យាល័យក្នុងស្រុកសំរាប់ពង្រឹងការស្រាវជ្រាវ<br>រៀបចំឱ្យមានវគ្គបណ្តុះបណ្តាលក្នុងស្រុកនិងមានបញ្ជូននូវមន្ត្រីជំនាញទៅចូលរួមវគ្គបណ្តុះ បណ្តាលនៅក្រៅប្រទេស | ការយល់ដឹងរបស់មន្ត្រីជំនាញមានការកើនឡើងទាំងនៅក្នុងនាយកដ្ឋានប្រែប្រួលអាកាសធាតុក៏ដូចជានៅតាមក្រសួង ស្ថាប័នពាក់ព័ន្ធ។ |

## ៣)សកម្មភាព៖រយៈពេលមធ្យម(២០១៤–២០១៨)

| សកម្មភាព | ការពិនិត្យតាមដាននៅពាក់កណ្តាលវដ្ត ផែនការ | បច្ចុប្បន្នភាព |
|---|---|---|
| ៣.ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុនៅតាមកម្រិតថ្នាក់ វិស័យនានា<br>៤.ការចាប់ផ្តើមគម្រោងឬកម្មវិធីនានាក្នុងវិស័យអាទិភាព | គម្រោងនានាសំរាប់ផ្នែកបន្សាំត្រូវបានដាក់ឱ្យអនុវត្តមានដូចជាៈគម្រោង SRL, SPCR, GCF, EBA ជាដើម។ | គម្រោងនានាដូចជាគម្រោងSRL, SPCR, GCF, EBA ត្រូវបានដាក់ឱ្យដំណើរការនិងកំពុងដំណើរការ។មានគម្រោងមួយចំនួនកំពុងស្ថិតក្នុងការវាយតម្លៃបញ្ចប់។ |
| ៥.ការប្រតិបត្តិប្រព័ន្ធត្រួតពិនិត្យនិងវាយតម្លៃ និងគ្រប់គ្រងទិន្នន័យ។ | រៀបចំអោយមាននូវបន្ទប់ទិន្នន័យក្នុងគេហទំព័ររបស់ ក.ជ.អ.ច.។ | ទិន្នន័យវាយតម្លៃភាពងាយរងគ្រោះត្រូវបានចេញផ្សាយជាសាធារណៈក្នុងគេហទំព័ររបស់ក.ជ.អ.ច.។ |

## ៣)សកម្មភាព៖រយៈពេលវែង (២០១៩–២០២៣)

| សកម្មភាព | ការពិនិត្យតាមដានទៅពាក់កណ្តាលវដ្តផែនការ | បច្ចុប្បន្នភាព |
|---|---|---|
| ១.ការពង្រីកសកម្មភាពជោគជ័យដែលបានសម្រេចកន្លងមក<br>២.បន្តបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងកម្មវិធីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ<br>៣.បង្កើនការប្រើប្រាស់មូលនិធិគាំទ្រ | មិនមាន | កំពុងបន្តពង្រីកសកម្មភាពដែលជោគជ័យតាមរយៈការកសាងសមត្ថភាពនៅតាមវិស័យនិងថ្នាក់ក្រោមជាតិក្នុងការរៀបចំសំណើរថវិកាទៅកាន់មូលនិធិគាំទ្រដូចជាមូលនិធិអាកាសធាតុបៃតងជាដើមដើម្បីគាំទ្រការអនុវត្តនូវផែនការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិ |

## ៤)សូចនាករក្នុងក្របខ័ណ្ឌតាមដាននិងវាយតម្លៃការប្រែប្រួលអាកាសធាតុ (Readiness Indicators)

| សូចនាករ | បរិយាយ | ទិន្នន័យដើមគ្រា | បច្ចុប្បន្នភាព |
|---|---|---|---|
| ១ | ស្ថានភាពនៃគោលនយោបាយនិងយុទ្ធសាស្ត្រអាកាសធាតុ | បានចូលជាសមាជិករបស់អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុនិងបានរៀបចំនិងដាក់បញ្ជូននូវរបាយការណ៍នានាដូចជា៖ First National Communication, NAPA, INDC | បន្តខិតខំបំពេញតួនាទីបេក្ខភាពជាសមាជិករបស់ក្របខ័ណ្ឌដោយបានដាក់បញ្ជូននូវរបាយការណ៍៖ Second National Communication និង BURs, ការធ្វើបច្ចុប្បន្នភាព NDC និង Third National Communication |

## ៤)សូចនាករក្នុងក្របខ័ណ្ឌតាមដាននិងវាយតម្លៃការប្រែប្រួលអាកាសធាតុ (Readiness Indicators)

| សូចនាករ | បរិយាយ | ទិន្នន័យដើមគ្រា | បច្ចុប្បន្នភាព |
|---|---|---|---|
| ២ | ស្ថានភាពនៃការដាក់បញ្ចូលកត្តាអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៍ | មិនទាន់មានយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុដាក់បញ្ចូលទៅក្នុងផែនការជាតិ | មានបរិយាយក្នុងផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ(២០១៩–២០២៣) យុទ្ធសាស្ត្រចតុកោណនិងផែនការសកម្មភាពឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុតាមវិស័យដែលធ្វើឡើងដោយក្រសួងចំនួន១៤(CCAP2014–2018)។ បច្ចុប្បន្នមានក្រសួងចំនួន៣ដែលកំពុងបន្តរៀបចំនូវCCAPរបស់ខ្លួន ក្រសួងដៃគូផ្សេងៗក្រៅពីក្រសួងទាំងបីខាងលើកំពុងធ្វើការដាក់បញ្ចូលការប្រែបប្រួលអាកាសធាតុទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ |

## ៤)សូចនាករក្នុងក្របខ័ណ្ឌតាមដាននិងវាយតម្លៃការប្រែប្រួលអាកាសធាតុ (Readiness Indicators)

| សូចនាករ | បរិយាយ | ទិន្នន័យដើមគ្រា | បច្ចុប្បន្នភាព |
|---|---|---|---|
| ៣ | ស្ថានភាពនៃការសម្របសម្រួល | ១.ចូលរួមជាមួយអង្គការសហប្រជាជាតិដើម្បីចូលរួមជាមួយពិភពលោកក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ក៏ដូចជាការចូលរួមក្នុងតំបន់។ | ១.បន្តចូលរួមជាមួយអង្គការសហប្រជាជាតិនិងការចូលរួមក្នុងតំបន់(ដូចជា អាស៊ាន និងអាស៊ីប៉ាស៊ីហ្វិក) ក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។ |
| | | ២.ស្វែករកដៃគូនិងមូលនិធិនានាក្នុងការដាក់ចេញនូវផែនការនិងការអនុវត្តសកម្មភាពដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។ | ២.បន្តស្វែងរកដៃគូនិងមូលនិធិនានាដែលបច្ចុប្បន្នមានមូលនិធិអាកាសធាតុបៃតង មូលនិធិវិនិយោគបៃតង មូលនិធិ ដៃគូម្ចាស់ជំនួយ និងប្រទេសដៃគូនានា។ |
| | | ៣.គាំទ្រដល់ដៃគូពាក់ព័ន្ធ អង្គការសង្គមស៊ីវិល ការសិក្សាស្រាវជ្រាវ ការពង្រឹងសមត្ថភាព ដែលចូលរួមឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។ | ៣.បន្តការគាំទ្រក្នុងភាពជាដៃគូជូនដល់ស្ថាប័ននានាក្នុងប្រទេសដែលកំពុងអនុវត្តនូវកិច្ចការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។ |

## ៤)សូចនាករក្នុងក្របខ័ណ្ឌតាមដាននិងវាយតម្លៃការប្រែប្រួលអាកាសធាតុ (Readiness Indicators)

| សូចនាករ | បរិយាយ | ទិន្នន័យដើមគ្រា | បច្ចុប្បន្នភាព |
|---|---|---|---|
| ៤ | ស្ថានភាពព័ត៌មានអាកាសធាតុ | បាននិងកំពុងរៀបចំនូវព័ត៌មានស្តីពីអាកាសធាតុដែលបញ្ចូលនូវការប្រកាសអាសន្នទុកជាមុនដែលមានដាក់បង្ហាញនៅក្នុងគេហទំព័ររបស់ក្រសួងធនធានទឹកនិងឧតុនិយម | ព័ត៌មានអាកាសធាតុនិងការប្រកាសអាសន្នទុកជាមុនគឺមានចេញផ្សាយជាទៀងទាត់នៅក្នុងគេហទំព័ររបស់ក្រសួង |
| ៥ | ស្ថានភាពការដាក់បញ្ចូលអាកាសធាតុទៅក្នុងហិរញ្ញប្បទាន | មិនមាន | របាយការណ៍ពិនិត្យទៅលើចំណាយសាធារណៈសំរាប់អាកាសធាតុ (CPER) ដែលចេញផ្សាយក្នុងឆ្នាំ ២០១៦ ២០១៧ និង២០១៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |

## ៥)សូចនាករក្នុងក្របខ័ណ្ឌតាមដាននិងវាយតម្លៃការប្រែប្រួលអាកាសធាតុ (Impact Indicators)

| សូចនាករ | បរិយាយ | ទិន្នន័យដើមគ្រា | បច្ចុប្បន្នភាព |
|---|---|---|---|
| ១ | ភាគរយនៃឃុំដែលងាយរងគ្រោះទៅនឹងការប្រែប្រួលអាកាសធាតុ | មិនមាន | ទិន្នន័យសំរាប់ឆ្នាំ២០១៦ ២០១៧ និង២០១៨ គឺមានចេញផ្សាយនៅក្នុងគេហទំព័ររបស់ក.ជ.អ.ច។ ទិន្នន័យសំរាប់ឆ្នាំបន្ទាប់គឺកំពុងធ្វើការសហការជាមួយ គ.ជ.អ.ប.ក្នុងការរៀបចំទិន្នន័យ។ |
| ២ | ចំនួនគ្រួសារដែលរងផលប៉ះពាល់ដោយសារទឹកជំនន់ ខ្យល់ព្យុះនិងគ្រោះរាំងស្ងួត | មិនមាន | ទិន្នន័យសំរាប់ឆ្នាំ២០១៦ ២០១៧ និង២០១៨ គឺមានចេញផ្សាយនៅក្នុងគេហទំព័ររបស់ ក.ជ.អ.ច. ។ទិន្នន័យសំរាប់ឆ្នាំបន្ទាប់គឺកំពុងធ្វើការសហការជាមួយ គ.ជ.អ.ប.ក្នុងការរៀបចំទិន្នន័យ។ |
| ៣ | ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ | មិនមាន | ទិន្នន័យសំរាប់ឆ្នាំ២០១៦ ២០១៧ ២០១៨ គឺមានចេញផ្សាយនៅក្នុងគេហទំព័ររបស់ ក.ជ.អ.ច។ ទិន្នន័យសំរាប់ឆ្នាំបន្ទាប់គឺកំពុងចាប់ផ្តើមធ្វើការរៀបចំ។ |

# ៦)បញ្ហាប្រឈម

- ការរៀបចំផែនការនិងការអនុវត្តផែនការគឺពឹងផ្អែកទាំងស្រុងទៅលើដៃគូម្ចាស់ជំនួយដូច្នេះការរក្សានូវនិរន្តរភាពក្នុងការធ្វើផែនការនិងអនុវត្តនូវផែនការនិងសកម្មភាពគឺនៅមានកម្រិត
- មិនទាន់មានឧបករណ៍ដែលជាជំនួយក្នុងការវាយតម្លៃ
- ការតាមដាននិងវាយតម្លៃនូវវឌ្ឍនភាពរបស់ផែនការគឺនៅមានកម្រិតដោយសារមានការយល់ឃើញខុសៗគ្នាចំពោះក្របខ័ណ្ឌពិនិត្យ តាមដាន និងវាយតម្លៃ
- ដោយសារការៀបចំផែនការនិងការអនុវត្តសកម្មភាពគឺពឹងផ្អែកទៅលើម្ចាស់ជំនួយដែលប្រើប្រាស់នូវក្របខ័ណ្ឌពិនិត្យ តាមដាន និងវាយតម្លៃដែលមានលក្ខណៈខុសៗគ្នាទៅតាមវិស័យដូច្នេះការវាយតម្លៃទាំងនោះមិនបានឆ្លើយតបទាំងស្រុងមកកាន់ក្របខ័ណ្ឌវាយតំលៃរបស់ផែនការនេះឡើយ

# ៦)ចក្ខុវិស័យ

- ធ្វើការបង្កើតនូវយន្តការហិរញ្ញវត្ថុដើម្បីធានានូវនិរន្តរភាពក្នុងការធ្វើផែនការក៍ដូចជាការអនុវត្តសកម្មភាព

- បង្កើតនូវឧបករណ៍សំរាប់ក្របខ័ណ្ឌពិនិត្យ តាមដាន និងវាយតម្លៃដែលមាននិយមន័យ វិធីសាស្រ្តក្នុងការគណនា ខ្នាតពេលវេលាសំរាប់វាស់វែងដែលមានលក្ខណៈជាក់លាក់ និងមានតម្លាភាព

- ធ្វើការផ្សព្វផ្សាយអោយបានទូលំទូលាយជាងមុនអំពីផែនការជូនដល់គ្រប់ស្ថាប័នពាក់ព័ន្ធដើម្បីមានការយល់ឃើញជារួមចំពោះយុទ្ធសាស្រ្តនិងការអនុវត្តសកម្មភាព រួមទាំងក្របខ័ណ្ឌពិនិត្យ តាមដាន និងវាយតម្លៃ

- ស្នើសុំដៃគូពាក់ព័ន្ធធ្វើការសហការក្នុងការអនុវត្តគម្រោងនានាដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្ត្រដែលមានក្នុងផែនការនេះក៏ដូចជាឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ

- ត្រៀមរៀបចំឬធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុសម្រាប់បន្តអនុវត្តក្រោយឆ្នាំ២០២៣

- ជំរុញក្រសួង ស្ថាប័នពាក់ព័ន្ធបញ្ចូលការងារប្រែប្រួលអាកាសធាតុទៅក្នុងគោលនយោបាយនិងផែនការរបស់ខ្លួនដើម្បីធានានិរន្តរភាពការរៀបចំផែនការថវិកាអនុវត្តន៍។

# សូមអរគុណ

**សិក្ខាសាលា**

**ត្រួតពិនិត្យលទ្ធផលការងារអភិវឌ្ឍន៍ដោយចីរភាពឆ្នាំ២០២០ និងទិសដៅការងារឆ្នាំ២០២១**

រាជធានីភ្នំពេញ ថ្ងៃអង្គារ ១២កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ត្រូវនឹងថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០

**ប្រធានបទ៖ ដំណើរការរៀបចំរបាយការណ៍បច្ចុប្បន្នភាព ការចូលរួមចំណែករបស់ជាតិដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ** (NDC Update)

**រៀបចំដោយ៖** លោកបណ្ឌិត **ហេង ចាន់ធឿន** អនុប្រធាននាយកដ្ឋានប្រែប្រួលអាកាសធាតុ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (GSSD)



# មាតិកា

១. ដំណើរការរៀបចំរបាយការណ៍បច្ចុប្បន្នភាពនៃការចូលរួមចំណែករបស់ជាតិ ដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (NDC Update Process)

២. ក្របខ័ណ្ឌគតិយុត្តសំខាន់ៗ ដែលពាក់ព័ន្ធ

៣. លទ្ធផលសំខាន់ៗ

៤. បញ្ហាប្រឈម

៥. ការឆ្លើយតប/ដំណោះស្រាយ

៦. ផែនការក្របខ័ណ្ឌការងារ និងពេលវេលារៀបចំ NDC (2020-2021)

2

## ១. ដំណើរការរៀបចំរបាយការណ៍បច្ចុប្បន្នភាពនៃការចូលរួមចំណែករបស់ជាតិ ដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (NDC Update Process)

- រដ្ឋាភិបាលកម្ពុជា បានរៀបចំនិងដាក់ជូននូវរបាយការណ៍លើកទី១ NDC នៅឆ្នាំ២០១៥ ដើម្បីចូលរួមចំណែកអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុក្រោមកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីអាកាសធាតុ
- របាយការណ៍ NDC នេះ ផ្តោតលើការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ (GHG) និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ
- កម្ពុជារំពឹងទុកថា នឹងអាចកាត់បន្ថយការបញ្ចេញ GHG ត្រឹម ២៧% នៅឆ្នាំ២០៣០ ប្រៀបនឹងការព្យាករតាមទម្លាប់ធម្មតា
- យេនឌ័រ មិនត្រូវបានរំលេចពេញលេញនៅឡើយទេ




3

## វដ្តនៃដំណើរការរៀបចំរបាយការណ៍បច្ចុប្បន្នភាព NDC

- គ្រប់ភាគីទាំងអស់នៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ស្នើឱ្យរៀបចំនិងដាក់ជូននូវរបាយការណ៍ NDC របស់ខ្លួននៅឆ្នាំ២០២០ និងជារៀងរាល់៥ឆ្នាំបន្ទាប់
- ការត្រួតពិនិត្យពីវឌ្ឍនភាព នឹងត្រូវធ្វើឡើងនៅឆ្នាំ២០២៣



## បង្កើនមហិច្ឆតា តាមរយៈ ដំណើរការ NDC

- យោងតាមរបាយការណ៍ចុងក្រោយរបស់អ្នកវិទ្យាសាស្ត្រ បានសង្កត់ធ្ងន់ និងទាមទារអោយមានការបង្កើន**មហិច្ឆតា ដោយធ្វើសកម្មភាពឆ្លើយតបជាបន្ទាន់** ដើម្បីធានាថា កិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីអាកាសធាតុ ទទួលបានជោគជ័យ




## ដំណើរការរៀបចំរបាយការណ៍ NDC



## វិស័យអាទិភាព

- វិស័យ និងសកម្មភាពដែលមាននៅក្នុងរបាយការណ៍ NDC លើកទី១ ត្រូវយកមកពិចារណាឡើងវិញ ជាអាទិភាព សំរាប់ជាគំនិតក្នុងការរៀបចំបច្ចុប្បន្នភាពNDC ព្រោះវិស័យ និងសកម្មភាពទាំងនេះ ត្រូវបានអនុវត្ត ដោយមានសុគតភាពជាមួយការអនុវត្តផែនការសកម្មភាពការប្រែប្រួលអាកាសធាតុ
- វិស័យសំខាន់ៗ ដែលជាអាទិភាព មានដូចជា




## ២. ក្របខ័ណ្ឌគតិយុត្តសំខាន់ៗ ដែលពាក់ព័ន្ធ

- របាយការណ៍ NDC លើកទី១ (២០១៥)
- របាយការណ៍បច្ចុប្បន្នភាពពីរឆ្នាំម្តងលើកទី១របស់កម្ពុជា (BUR ២០២០, សារពើភណ្ឌ GHG,២០១៦)
- របាយការណ៍ជាតិលើកទី២ (SNC ២០១៥)
- ផែនការសកម្មភាពការប្រែប្រួលអាកាសធាតុ (CCAPs)
- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) ២០១៩-២០២៣
- ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ២០១៤-២០២៣
- ផែនការអភិវឌ្ឍន៍បៃតង ២០១៣-២០៣០
- យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤
- ផែនការសកម្មភាពជាតិសម្រាប់ការកាត់បន្ថយគ្រោះមហន្តរាយ (SNAP-DRR)
- ក្របខ័ណ្ឌហិរញ្ញវត្ថុអាកាសធាតុ (២០១៤)
- ក្របខ័ណ្ឌហិរញ្ញប្បទានផែនការជាតិបន្សាំ (២០១៧)
- យុទ្ធសាស្ត្របន្សាំការប្រែប្រួលអាកាសធាតុមេគង្គ និងផែនការសកម្មភាព (MASAP) (២០១៧)
- គោលនយោបាយជាតិប្រសិទ្ធភាពថាមពល
- ផែនការយុទ្ធសាស្ត្រតាមវិស័យ
- ផែនការសកម្មភាព និងយុទ្ធសាស្ត្រគ្រប់គ្រងកាកសំណល់ ២០១៨-២០៣០
- គោលដៅអភិវឌ្ឍន៍ដោយចីរភាពកម្ពុជា CSDGs ២០១៦-២០៣០ ។ល។

8


៣. លទ្ធផលសំខាន់ៗ
• បន្ទាប់ពីសិក្ខាសាលាចាប់ផ្ដើម DCC/CCCA បានរៀបចំកិច្ចប្រជុំចំនួន ២៥ កិច្ចប្រជុំ ជាមួយក្រសួងពាក់ពន្ធ
• មកដល់ពេលនេះ មានសកម្មភាពស្នើចំនួន ៦៩ ផ្នែកបន្សាំ និង ២៩សកម្មភាព ផ្នែកកាត់បន្ថយ ពីក្រសួងពាក់ពន្ធ័ចំនួន១៦
• យេនឌ័រ យុវជន និង វិស័យឯកជន ត្រូវបញ្ជ្រាបនៅក្នុងសកម្មភាពអាទិភាព
• សកម្មភាពអាទិភាពតាមវិស័យ និងសង្គតិភាពជាមួយផែនការជាតិ បន្សាំ(NAP) របាយការណ៍ជាតិលើកទី២(SNC) និងផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា(CCCSP) ផែនការសកម្មភាពការប្រែប្រួលអាកាសធាតុ (CCAP) និង របាយការណ៍បច្ចុប្បន្នភាពពីរឆ្នាំម្តង (BUR)
• សកម្មភាពអាទិភាពបានឆ្លើយតបនឹងគោលដៅអភិវឌ្ឍន៍ដោយចីរភាពកម្ពុជា យុទ្ធសាស្ត្រចតុកោណ ផែនការអភិវឌ្ឍន៍ជាតិ និងក្របខណ្ឌគតិយុត្តនានា
២៩សកម្មភាព ផ្នែកកាត់បន្ថយ
៦៩ សកម្មភាព ផ្នែកបន្សាំ
យុវជន វិស័យ ឯកជន យេនឌ័រ
របាយការណ៍ ការចូលរួមចំណែករបស់ជាតិ ដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ កម្ពុជា
ក្របខ័ណ្ឌតម្លាភាព, សេចក្តីជូនដំណឹងជាតិ, ហិរញ្ញវត្ថុ, បច្ចេកវិទ្យា, ធនធាន
9


បច្ចុប្បន្នភាពនៃការផ្តល់ធាតុចូលរបស់អន្តរក្រសួង
ធាតុចូលជាផ្លូវការ
MoH
Mo WRA M
MRD
MoE
MoE YS
NCD M
MP WT
MI STI
MoP
NCD Ds
MAFF
MME
MoIn f
ML MUP C
Mo WA
MoT
ផ្តល់ធាតុចូលនៅដំណាក់កាលអន្តរក្រសួង
CDC
MEF
• មានក្រសួងពាក់ពន្ធ័ចំនួន១៦ បានដាក់បញ្ចូលធាតុចូលជាផ្លូវការ មក ក.ជ.អ.ច NCSD
• នាយកដ្ឋានប្រែប្រួលអាកាសធាតុ/លេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដើរតួនាទីក្នុងការសម្របសម្រួល
10

## កិច្ចការសំខាន់ៗនៅដំណាក់ពិគ្រោះយោបល់ជាមួយអន្តរក្រសួង

- កិច្ចប្រជុំពិគ្រោះយោបល់ កិច្ចប្រជុំបច្ចេកទេសមួយចំនួននឹងត្រូវរៀបចំដើម្បីពិនិត្យ និងពិគ្រោះយោបល់ឡើងវិញនូវធាតុចូលបឋមរបស់អន្តរក្រសួង/ក្រសួងតាមវិស័យ និងដើម្បីរៀបចំ និងស្នើសុំសម្រេចសកម្មភាព/គោលដៅសម្រាប់NDC
- កិច្ចប្រជុំអន្តរក្រសួង/វិស័យ នឹងត្រូវបានរៀបចំតាមដំហានដូចខាងក្រោម៖




11

## សេចក្តីព្រាងរបាយការណ៍ NDCs

| មាតិកា | ប្រធានបទ |
|---|---|
- Hold an online meeting to discuss and show Cambodia view through providing input and comments from inter-ministries members on the roadmap between the National Council for Sustainable Development and the State Atomic Energy Corporation of Russia for the construction of a science and technology center on the territory of the Kingdom of Cambodia with the advisor of the Director General of the State Atomic Energy Corporation of Russian Federation and representatives of the Russian Embassy in Cambodia. In that, the Cambodian side proposed to change the word " draft roadmap " to " draft joint work plan " which is not legally binding and requested that no specific date be set for implementation and implementation according to the available resources.





9

## 2. Progress of cooperation in the use of nuclear energy for peaceful purposes

- Developed a joint communication plan for 2020 to raise public awareness of the benefits of using nuclear energy for peaceful purposes with representatives of the State Atomic Energy Corporation of the Russian Federation. In that plan, we also agreed with the Russian side to organize the Nuclear Science Day forum, which will be in collaboration with the Royal University of Phnom Penh, and the party will also invited experts in nuclear energy and climate change to participate as a speakers,
- Discussed the organization of a training workshop for local journalists to write articles related to nuclear science and energy,
- This year, as planned, the Russian side will also invite Cambodian journalists to attend the Atomic Conference in Sochi, Russian Federation.

10

## 2. Progress of cooperation in the use of nuclear energy for peaceful purposes

Meeting with leaders of the Ministry of Mines and Energy and provided with some recommendation:

1. Cambodia should consider establishing an institution in charge of managing the use of nuclear technology, which should be under the leadership of the head and senior officials of the Royal Government.

2. Cambodia should encourage private sector investment, especially in the use of this technology in the food, medical and agricultural industries.

11

## 2. Progress of cooperation in the use of nuclear energy for peaceful purposes

3. Relevant ministries and institutions should have their own working groups to coordinate, promote and disseminate the benefits of using

Nuclear technology in its field.

4. Cambodia should consider building a small science and technology center (about 600 kW) for future benefit.





12

## 3. Next Step

- Request in principle from His Excellency Chair of the National Council for Sustainable Development and Minister of Environment to cooperate and discuss with the Russian side in the consensus and the next steps of the agreement on the construction of a nuclear energy science and technology research center,
- Continue to cooperate with China National Nuclear Corporation (CNNC) in finalizing the Memorandum of Understanding on Human Resource Development in the Nuclear Industry.

13

# Thank You!

14

**សិក្ខាសាលា**

**ត្រួតពិនិត្យលទ្ធផលការងារអភិវឌ្ឍន៍ដោយចីរភាពឆ្នាំ២០២០ និងទិសដៅការងារឆ្នាំ២០២១**

រាជធានីភ្នំពេញ ថ្ងៃអង្គារ ១២កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ត្រូវនឹងថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០

# ប្រធានបទ៖ ក្រមសីលធម៌ស្រាវជ្រាវ និងកម្មវិធីស្រាវជ្រាវជាតិ

រៀបចំដោយ៖ នាយកដ្ឋានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា



## មាតិកា

១. ក្រមសីលធម៌ស្រាវជ្រាវ

២. កម្មវិធីស្រាវជ្រាវជាតិ

៣. កិច្ចសហប្រតិបត្តិការលើការសិក្សាស្រាវជ្រាវជាមួយមជ្ឈមណ្ឌលគោលនយោបាយយុទ្ធសាស្ត្រ និងនវានុវត្តន៍ (CSIP)

2

## ១. ក្រមសីលធម៌ស្រាវជ្រាវ




- ក្រមសីលធម៌ស្រាវជ្រាវដែលមានការទទួលស្គាល់និងអនុវត្តជារួមមួយ គឺពុំទាន់មាននៅកម្ពុជាទេ។
- ហេតុនេះ ប្រទេសកម្ពុជាគួរមានក្រមសីលធម៌ស្រាវជ្រាវ ដើម្បីតម្រង់ទិសការសិក្សាស្រាវជ្រាវ។
- នាយកដ្ឋានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យានៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព មានតួនាទីចងក្រងក្រមសីលធម៌ស្រាវជ្រាវ។

3

## ១. ក្រមសីលធម៌ស្រាវជ្រាវ




- **ការសិក្សាស្រាវជ្រាវ** គឺជាការសិក្សាអំពីបញ្ហាអ្វីមួយ ដើម្បីស្វែងយល់ពីឫសគល់នៃបញ្ហាឱ្យកាន់តែច្បាស់ជាងមុន និងដើម្បីស្វែងរកវិធីសម្រាប់កែលម្អ ឬដោះស្រាយបញ្ហានោះ។
- **ក្រមសីលធម៌ស្រាវជ្រាវ** គឺជាគោលការណ៍ណែនាំ ដើម្បីធានាឱ្យដំណើរការសិក្សាស្រាវជ្រាវប្រព្រឹត្តទៅដោយប្រកាន់ភ្ជាប់ក្រមសីលធម៌ និងកាត់បន្ថយហានិភ័យលើមនុស្ស សត្វ បរិស្ថាន និងសង្គម សំដៅរួមចំណែកដល់ការអភិវឌ្ឍដោយចីរភាពនៅកម្ពុជា។

4

## ២. កម្មវិធីស្រាវជ្រាវជាតិ




- **កម្មវិធីស្រាវជ្រាវជាតិ** ជាប្រធានបទអាទិភាពសម្រាប់ការសិក្សាស្រាវជ្រាវរបស់ប្រទេសមួយដែលមានការឯកភាពគ្នាជារួម ដើម្បីឱ្យការសិក្សាស្រាវជ្រាវទទួលបានលទ្ធផលគ្រប់ជ្រុងជ្រោយ ប្រកបដោយប្រសិទ្ធភាពខ្ពស់ រួមចំណែកដល់ការអភិវឌ្ឍប្រកបដោយចីរភាព ។

5

## ២. កម្មវិធីស្រាវជ្រាវជាតិ

ប្រធានបទនៃការសិក្សាស្រាវជ្រាវមួយចំនួនត្រូវបានចាត់ទុកជាអាទិភាពនៅប្រទេសកម្ពុជា រួមមាន៖

១. ការសិក្សាពីជម្រើសក្នុងការកែលម្អប្រព័ន្ធលូនៅរាជធានីភ្នំពេញ

២. ការសិក្សាពីជម្រើសក្នុងការកែលម្អប្រព័ន្ធភ្លើងបំភ្លឺផ្លូវនៅរាជធានីភ្នំពេញ ក្រុងសៀមរាប និងក្រុងព្រះសីហនុ ជាដើម

៣. យុទ្ធសាស្ត្រកសិ-ឧស្សាហកម្មនៅកម្ពុជា

៤. ការសិក្សាពីសក្តានុពលនៃការដាំដើមឈើប្រណិត (គ្រញូង) និងការកែច្នៃ



6

## ២. កម្មវិធីស្រាវជ្រាវជាតិ

៥. ការលើកកម្ពស់ការអភិរក្ស និងការប្រើប្រាស់បន្លែនិងផ្លែឈើក្នុងស្រុក និងពូជសត្វ

៦. ការសិក្សាពីផលប៉ះពាល់របស់សារពាង្គកាយ GMO ទៅលើសុវត្ថិភាពអាហារ និងសន្តិសុខស្បៀងនៅប្រទេសកម្ពុជា

៧. ការសិក្សាពីលទ្ធភាពក្នុងការប្រើប្រាស់ឧស្ម័នធម្មជាតិនៅក្នុងវិស័យឧស្សាហកម្ម និងគេហដ្ឋាន

៨. ការសិក្សាពីជម្រើសសេដ្ឋកិច្ចក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីចំហេះរបស់ម៉ាស៊ីនយានយន្ត




7

## ២. កម្មវិធីស្រាវជ្រាវជាតិ

៩. ការសិក្សាពីផលប៉ះពាល់របស់ការធ្វើកសិកម្មទៅលើបរិស្ថាន និងខ្សែចង្វាក់អាហារ

១០. ការសិក្សាពីយុទ្ធសាស្ត្រក្នុងការកែលម្អសុវត្ថិភាពអាហារនៅប្រទេសកម្ពុជា

១១. ការសិក្សាពីយានយន្តអគ្គិសនី



8

## ៣. កិច្ចសហប្រតិបត្តិការលើការសិក្សាស្រាវជ្រាវជាមួយមជ្ឈមណ្ឌលគោលនយោបាយយុទ្ធសាស្ត្រ និងនវានុវត្តន៍ (CSIP)

**គោលបំណង៖** ដើម្បីលើកកម្ពស់ការសិក្សាស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រពាក់ព័ន្ធនឹងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងការរស់នៅដោយចីរភាព។

១. ការគ្រប់គ្រងសំណល់

២. ការបំលែងសំណល់ទៅជាថាមពល

៣. ការកែច្នៃសំណល់

៤. ការប្រែប្រួលអាកាសធាតុ

៥. សេដ្ឋកិច្ចបៃតង

៦. ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

៧. ការប្រើប្រាស់ម៉ូដែលសេដ្ឋកិច្ចក្នុងការសិក្សាអំពីការប្រែប្រួលអាកាសធាតុ ការកែច្នៃសំណល់ និងបរិស្ថាន

៨. ការអភិវឌ្ឍសហគមន៍ដោយចីរភាព

៩. វិស័យដទៃទៀត

CSIP
មជ្ឈមណ្ឌលគោលនយោបាយយុទ្ធសាស្ត្រ និងនវានុវត្តន៍
CENTER FOR STRATEGY AND INNOVATION POLICY

9

## ៣. កិច្ចសហប្រតិបត្តិការលើការសិក្សាស្រាវជ្រាវជាមួយមជ្ឈមណ្ឌលគោលនយោបាយយុទ្ធសាស្ត្រ និងនវានុវត្តន៍ (CSIP)

១. គម្រោងស្រាវជ្រាវកំណត់គំរូអភិវឌ្ឍន៍សហគមន៍ប្រកបដោយចីរភាព



២. គម្រោងស្រាវជ្រាវរៀបចំយុទ្ធសាស្ត្រជាតិក្នុងការគ្រប់គ្រងបរិស្ថាន និងកំណត់តម្លៃសំណល់



10

# សូមអរគុណ

# ANNUAL WORKSHOP TO REVIEW NCSD 2020 PROGRESS AND 2021 PLAN

Phnom Penh, 29 November 2019

Mok Mareth Hall, Ministry of Environment, Phnom Penh

## Subject: Research Ethics and Research Agenda

**Presented by: Department of Science and Technology**



## Content

1. Research ethics
2. Research agenda
3. Research cooperation with the Center for Strategy and Innovation Policy ( CSIP)

2

## 1. Research Ethics




- A widely recognized and applicable research ethics is not available in Cambodia.
- NCSD and MOE intend to introduce the research ethics with underlying principles, processes and other key attributes to relevant stakeholders in order to ensure ethical research conduct.
- Department of Science and Technology of the General Secretariat of the NCSD is in charge of facilitating the preparation of research ethics.



## 1. Research Ethics




- **Research** involves original scientific investigation to gain knowledge, understanding and insight of a relevant subject matter, contributing to solutions.
- **Research ethics** provides guidelines for the ethical conduct of research in order to reduce potential impacts on human, animal, environment, and society as well as to promote the sustainable development in Cambodia.

## 2. Research Agenda


RESEARCH AGENDA

FOR SCIENCE AND TECHNOLOGY

NATIONAL COUNCIL FOR SUSTAINABLE DEVELOPMENT, MINISTRY OF ENVIRONMENT

DEPARTMENT OF SCIENCE AND TECHNOLOGY

- **Research Agenda** contains a country's prioritized themes of research agreed upon to ensure the conduct of research is efficiently implemented contributing to sustainable development.

5

## 2. Research Agenda

- Prioritized themes of research agenda:

1. Assessment of options for improving drainage in Phnom Penh
2. Assessment of options for improving street lighting (i.e. in Phnom Penh, Siem Reap, Preah Sihanouk, etc.)
3. Agro-industry strategy for Cambodia
4. Assessment of potential for tree plantation (including rosewood species) and processing



6

## 2. Research Agenda

5. Improving conservation and usage of local fruit/vegetable and animal varieties
6. Assessment of impacts of GMOs on food security/safety in Cambodia
7. Feasibility study on shifting toward natural gas for industry and household in Cambodia
8. Assessment of economic options for reducing greenhouse gas (GHG) emission from internal combustion engine vehicles




7

## 2. Research Agenda

9. Assessment of impacts of agricultural runoff on environment, food chain, etc.
10. Assessment of strategy for improving food safety in Cambodia
11. Assessment of electric vehicle



8

## 3. Research Cooperation with CSIP

**Purpose:** to develop and promote intellectual dialogues and cooperation between the Parties, especially in scientific research in the field of environmental protection, natural resource conservation and sustainable development.

a. waste management;
b. waste-to-energy;
c. waste recycling;
d. climate change;
e. green economy;
f. environmental impact assessment;
g. application of economic modeling and economic analysis in climate change, waste, recycling and environmental sector;
h. sustainable community development
i. Other related areas of interest.

CSIP
CENTER FOR STRATEGY AND INNOVATION POLICY

9

## 3. Research Cooperation with CSIP

Project 1: Sustainable Community Development Model



Project 2: National Pricing Strategy for Waste and Environmental Management



10

https://ncsd.moe.gov.kh
General Secretariat of
National Council for Sustainable Development

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
អគ្គលេខាធិការដ្ឋាន

# របាយការណ៍
# សមិទ្ធិផលសម្រេចបានប្រចាំឆ្នាំ២០២០
# និងទិសដៅបន្តឆ្នាំ២០២១

រាជធានីភ្នំពេញ ខែកញ្ញា ឆ្នាំ២០២០

# មាតិកា

១. សេចក្តីផ្តើម ............ 2
២ . ស្ថិតិមន្ត្រីក្នុងអគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. ............ 2
៣.សមិទ្ធិផលសម្រេចបាន ............ 4
អនុកម្មវិធីទី១៖ ការអភិវឌ្ឍសេដ្ឋកិច្ចបៃតង និងលើកកម្ពស់ការ អនុវត្តវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ... 4
អនុកម្មវិធីទី២៖ជំរុញការអនុវត្តឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ............ 9
អនុកម្មវិធី៣៖អភិរក្សជីវៈចម្រុះ និងជីវសុវត្ថិភាព............ 19
៤.វឌ្ឍនភាពនៃការអនុវត្តគម្រោងនៅក្រោមអគ្គលេខាធិការដ្ឋានក.ជ.អ.ច. ............ 24
៥. សកម្មភាពចូលរួម កិច្ចប្រជុំ សិក្ខាសាលា បណ្តុះបណ្តាលនៅក្នុង និងក្រៅប្រទេស ............ 31
៦. ការគ្រប់គ្រងហិរញ្ញវត្ថុ............ 32
៧. ការរៀនសូត្រនិងបទពិសោធន៍ដែលទទួលបាន ............ 32
៨. បញ្ហាប្រឈម............ 32
៩. ទិសដៅអនុវត្តបន្តឆ្នាំ២០២១ ............ 33
៩.១ នាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ............ 33
៩.២ នាយកដ្ឋានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ............ 33
៩.៣ នាយកដ្ឋានសេដ្ឋកិច្ចបៃតង ............ 34
៩.៤ នាយកដ្ឋានប្រែប្រួលអាកាសធាតុ ............ 36
៩.៥ នាយកដ្ឋានជីវៈចម្រុះ............ 37
១០.សន្និដ្ឋាន ............ 38

## ១. សេចក្តីផ្តើម

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (ក.ជ.អ.ច.) ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៤០៣ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព។ ក.ជ.អ.ច. បង្កើតឡើងក្នុងគោលបំណងដើម្បីលើកកម្ពស់ការអភិវឌ្ឍដោយចីរភាពសំដៅរក្សាបាននូវតុល្យភាពរវាងសេដ្ឋកិច្ច បរិស្ថាន សង្គម និងវប្បធម៌នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ អគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. ត្រូវបានបង្កើត ឡើងដោយអនុក្រឹត្យលេខ ៥៩ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព។ អគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. មានតួនាទីសម្របសម្រួលការងារប្រចាំថ្ងៃរបស់ ក.ជ.អ.ច. ដែលមាននាយកដ្ឋានចំណុះចំនួន៥ គឺនាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ នាយកដ្ឋានប្រែប្រួលអាកាសធាតុ នាយកដ្ឋានសេដ្ឋកិច្ចបៃតង នាយកដ្ឋានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា និងនាយកដ្ឋានជីវៈចម្រុះ។

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ជាស្ថាប័នអន្តរក្រសួងដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាប្រធានកិត្តិយស និងរដ្ឋមន្ត្រីក្រសួងបរិស្ថានជាប្រធាន។ ក.ជ.អ.ច. មានសមាជិកភាពមកពីក្រសួង ស្ថាប័នសំខាន់ៗ ព្រមទាំងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ទាំងអស់។ ក.ជ.អ.ច. មានក្រុមការងារបច្ចេកទេសចំនួន០៧ គឺការប្រែប្រួលអាកាសធាតុ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, ជីវៈចម្រុះ ទីក្រុងនិរន្តរភាព ថាមពលនិរន្តរភាព ផលិតកម្ម និងការប្រើប្រាស់ដោយចីរភាព និងថាមពលនុយក្លេអ៊ែរ។ ក្រុមការងារទាំងអស់កំពុងគាំទ្រដល់ការអនុវត្តអាណត្តិការងាររបស់ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដោយមានការសម្របសម្រួលពីអគ្គលេខាធិការដ្ឋាន ក.ជ.អ.ច.។

ក្នុងអាណត្តិទី៦ នៃរាជរដ្ឋាភិបាលកម្ពុជា ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព បានកែសម្រួលនូវសមាសភាពគណៈកម្មការប្រតិបត្ត នៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពតាមរយៈសេចក្តីសម្រេចលេខ៨៦សសរ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២០របស់រាជរដ្ឋាភិបាលកម្ពុជា និងកែសម្រួលអនុប្រធាន និងសមាជិកសមាជិកានៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពតាមរយៈសេចក្តីសម្រេចស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព លេខ៨៥សសរ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២០របស់រាជរដ្ឋាភិបាលកម្ពុជា។

នៅក្នុងឆ្នាំ២០១៩ អគ្គលេខាធិការដ្ឋានបានសម្រេចនូវសមិទ្ធិផលសំខាន់ៗដែលជាកិច្ចខិតខំប្រឹងប្រែងរបស់នាយកដ្ឋានចំណុះឱ្យអគ្គលេខាធិការដ្ឋាន ដោយមានការគាំទ្រ និងសហការពេញលេញពីក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាលកម្ពុជានិងដៃគូអភិវឌ្ឍន៍នានា។

## ២ . ស្ថិតិមន្ត្រីក្នុងអគ្គលេខាធិការដ្ឋាន ក.ជ.អ.ច.

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពមានថ្នាក់ដឹកនាំ និងមន្ត្រីបម្រើការងារសរុបចំនួន ៨៤នាក់ ប្រធាននាយកដ្ឋាន០៥នាក់ អនុប្រធាននាយកដ្ឋាន១៥ នាក់ ប្រធាន/អនុប្រធាន និងមន្ត្រីថ្នាក់ការិយាល័យ៦៣នាក់ មន្ត្រីជាប់កិច្ចសន្យាចំនួន៤នាក់ និងមន្ត្រីស្ម័គ្រចិត្តចំនួន ១នាក់។

ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. រួមមាន ១០នាក់ ដែលដឹកនាំដោយឯកឧត្តមអគ្គលេខាធិការ ០១រូប និងឯកឧត្តម លោកជំទាវអគ្គលេខាធិការរង ០៩រូប ដូចខាងក្រោម៖

- ឯកឧត្តម វ៉ាន់ មុនីនាថ អគ្គលេខាធិការ
- ឯកឧត្តម កែន សេរីរដ្ឋា អគ្គលេខាធិការរង
- ឯកឧត្តម ភាវ សុវុទ្ធី អគ្គលេខាធិការរង

- ឯកឧត្តម ឯ វុឌ្ឍី អគ្គលេខាធិការរង
- ឯកឧត្តម ជា ចន្ទន័ធូ អគ្គលេខាធិការរង
- ឯកឧត្តម ប្រាក់ ថាវរៈអមិដា អគ្គលេខាធិការរង
- ឯកឧត្តម យិន សំរ៉ាយ អគ្គលេខាធិការរង
- លោកជំទាវ ងិន លីណា អគ្គលេខាធិការរង
- ឯកឧត្តម ស៊ុំ ធី អគ្គលេខាធិការរង
- ឯកឧត្តម ម៉េង មុន្នីរក្ស អគ្គលេខាធិការរង

ប្រធាននាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. មានចំនួន០៥រូប រួមមានៈ

- លោក ម៉ា ច័ន្ទសុទ្ធា ប្រធាននាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ
- លោក តាំង ម៉េងអៀង ប្រធាននាយកដ្ឋានសេដ្ឋកិច្ចបៃតង
- លោកបណ្ឌិត ហាក់ ម៉ៅ ប្រធាននាយកដ្ឋានប្រែប្រួលអាកាសធាតុ
- លោក អ៊ូ ច័ន្ទធារិទ្ធ ប្រធាននាយកដ្ឋានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
- លោកស្រី កែន បូព្រាង ប្រធាននាយកដ្ឋានជីវៈចម្រុះ

តារាង ១៖ ចំនួនមន្ត្រីនៅក្នុងនាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋាន ក.ជ.អ.ច.

| នាយកដ្ឋាន | ប្រធាននាយកដ្ឋាន | អនុប្រធាននាយកដ្ឋាន | ការិយាល័យ មន្ត្រីសរុប | មន្ត្រីជាប់កិច្ចសន្យា | មន្ត្រីស្ម័គ្រចិត្ត |
|---|---|---|---|---|---|
| នាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ | ១ | ៣ | ១៣ | ៣ | ១ |
| នាយកដ្ឋានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា | ១ | ២ | ៨ | ០ | ០ |
| នាយកដ្ឋានជីវៈចម្រុះ | ១ | ២ | ១៣ | ១ | ០ |
| នាយកដ្ឋានប្រែប្រួលអាកាសធាតុ | ១ | ៣ | ១៤ | ០ | ០ |
| នាយកដ្ឋានសេដ្ឋកិច្ចបៃតង | ១ | ១ | ១៤ | ០ | ០ |
| **សរុប** | **៥** | **១១** | **៦៣** | **៤** | **១** |

ប្រភព៖ ស្ថិតិមន្ត្រីនាយកដ្ឋាននៃអគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. ខែកញ្ញា ឆ្នាំ២០២០

ទំព័រ ៣

## ៣.សមិទ្ធិផលសម្រេចបាន

### អនុកម្មវិធីទី១៖ ការអភិវឌ្ឍសេដ្ឋកិច្ចបៃតង និងលើកកម្ពស់ការអនុវត្តវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

**គោលបំណង៖** *គាំទ្រគោលដៅអភិវឌ្ឍន៍ដោយចីរភាព តាមរយៈការសិក្សាស្រាវជ្រាវ និងកសាងសមត្ថភាព ការជំរុញការរៀបចំ និងអនុវត្តគោលនយោបាយ យន្តការគតិយុត្ត និងឧបករណ៍ជំនួយដល់ការធ្វើសេចក្តីសម្រេចចិត្ត ការលើកកម្ពស់ប្រសិទ្ធភាពក្នុងការប្រើប្រាស់មូលធនធម្មជាតិ និងការកាត់បន្ថយការបំពុលបរិស្ថាន។*

**ចង្កោមសកម្មភាពទី១៖ សេវាគាំទ្រប្រតិបត្តិការរបស់អគ្គលេខាធិការដ្ឋាន ក.ជ.អ.ច.**

- បានគាំទ្រនិងសម្របសម្រួលការងាររដ្ឋបាលរបស់គ្រប់នាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋានឱ្យដំណើរការទៅដោយរលូន និងទទួលបានជោគជ័យ
- បានផ្គត់ផ្គង់សម្ភារៈការិយាល័យដល់គ្រប់នាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋានក.ជ.អ.ច. ដើម្បីប្រើប្រាស់សម្រាប់ប្រតិបត្តិការរបស់នាយកដ្ឋាននីមួយៗ ដោយរលូន និងជោគជ័យ
- បានគាំទ្រត្រួតពិនិត្យនិងសម្របសម្រួលលិខិតចេញ-ចូលរបស់អគ្គលេខាធិការដ្ឋានក.ជ.អ.ច. សរុបចំនួន ៥៨០ច្បាប់
- បានសម្របសម្រួល និងអនុវត្តន៍បានយ៉ាងល្អក្នុងបង្ការ និងទប់ស្កាត់នូវជំងឺរាតត្បាត Covid-19 ដោយរៀបចំដាក់នូវម៉ាស់ អាល់កុល និងជែលលាងដៃសម្លាប់មេរោគជាប្រចាំជូនដល់មន្ត្រី និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន
- បានពង្រឹងរបៀបរបបការងារប្រចាំថ្ងៃដោយគ្រប់គ្រងដោយស្រង់វត្តមានរបស់មន្ត្រី និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន ក.ជ.អ.ច.
- បានរៀបចំបញ្ជីតាមដានការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋក្នុងនាយកដ្ឋាននៃអគ្គលេខាធិការដ្ឋាន
- បានសម្របសម្រួល និងកែសម្រួលលិខិតបទដ្ឋានគតិយុត្តឱ្យស្របតាមគោលការណ៍ណែនាំដូចជាសំណើ លិខិតបញ្ជាបេសកកម្ម លិខិតសុំគោលការណ៍ លិខិតអញ្ជើញ សេចក្តីសម្រេច សេចក្តីជូនដំណឹង ប្រកាស របាយការណ៍ ដីកាបញ្ជូន លិខិតបង្គាប់ការ និងរបាយការណ៍បានចំនួន ៥១៩ច្បាប់
- ទទួលបានការអនុម័តជាគោលការណ៍លទ្ធកម្មឆ្នាំ២០២០ របស់អគ្គលេខាធិការដ្ឋាន ក.ជ.អ.ច.
- បានដកថវិការជួទេយ្យបុរេប្រទានជុំទី២ របស់អគ្គលេខាធិការដ្ឋានក.ជ.អ.ច. រតនាគារជាតិ ដោយបានអនុម័តដកត្រឹមតែ៣០%នៃមួយជុំបង្វិល។ លើសពីនេះក៏បានរៀបចំតារាងឧបសម្ព័ន្ធកែតម្រូវរជ្ជទេយ្យបុរេប្រទានដោយអនុលោមតាមសារាចរណែនាំ០០១ និង០០៣ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ចង្កោមសកម្មភាពទី២៖ ការងារគ្រប់គ្រង និងសម្របសម្រួលក្រុមប្រឹក្សាអភិវឌ្ឍន៍ដោយចីរភាព**

- បានសម្របសម្រួលបេសកកម្មក្នុងប្រទេសសរុបចំនួន ១៣៧លើកសម្រាប់ថ្នាក់ដឹកនាំ និងមន្ត្រីក្នុងអគ្គលេខាធិការដ្ឋាន



*រូបភាពទី 1 ៖ កិច្ចប្រជុំថ្នាក់ដឹកនាំរបស់អគ្គលេខាធិការដ្ឋាន*

ទំព័រ ៤

- បានទទួលលិខិតចូលមានចំនួនសរុប៥៨០លិខិត និងផ្ញើលិខិតចេញមានចំនួនសរុប ៤៧៤លិខិត
- រៀបចំកិច្ចប្រជុំថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន និងមន្ត្រីសរុបចំនួន ២៩ លើកដើម្បីត្រួតពិនិត្យលទ្ធផលការងារ
- ចូលរួមវគ្គបណ្តុះបណ្តាលកិច្ចប្រជុំ និងសន្និសីទអន្តរជាតិចំនួន ០៧លើក ដោយផ្ទាល់ និងតាមអនឡាញ
- បានសម្របសម្រួលក្នុងកិច្ចប្រជុំពិភាក្សាអំពីកិច្ចសហការរវាងអគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី **«តេជោ»** ដែលមានទីតាំងនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ
- បានសម្របសម្រួលរៀបចំ និងអនុម័តក្របខណ្ឌយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍដោយចីរភាពរបស់ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពនិងក្រសួងបរិស្ថានរយៈពេល ០៥ឆ្នាំ
- បានរៀបចំរបាយការណ៍វឌ្ឍនភាពក្នុងវិស័យការអភិវឌ្ឍដោយចីរភាព និងបរិស្ថាននៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម



*រូបភាពទី 2 ៖ កិច្ចប្រជុំក្រុមការងារស្តីពីគោលដៅអភិវឌ្ឍន៍ដោយចីរភាពវិស័យបរិស្ថាន*

- បានគាំទ្រ និងរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២១-២០២៣ និងទទួលបានការអនុម័តជាគោលការណ៍ដើម្បីដាក់ជូនក្រសួងបរិស្ថានពិនិត្យនិងសម្រេច
- បានសម្របសម្រួលរៀបចំតែង តាំងសមាសភាពនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពអាណត្តិទី ៦ និងបានដាក់ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីសុំគោលការណ៍អនុម័តពី**សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីព្រះរាជាណាចក្រកម្ពុជា**
- បានសម្របសម្រួលជាមួយនាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋាន ដើម្បីរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំខែ ត្រីមាស និងឆមាស និងបានដាក់ជូនក្រសួងបរិស្ថានទាន់ពេលវេលា។
- បានចូលរួមវិភាគទានក្នុងការអនុវត្តអនុសញ្ញាអន្តរជាតិ ពិធីសារអន្តរជាតិ រួចរាល់
- បានរៀបចំសិក្ខាសាលាបណ្តុះបណ្តាល ស្តីពីការអភិវឌ្ឍដោយចីរភាព ជូនដល់មន្ត្រីរាជការ ក្រោមអធិបតីភាព **ឯកឧត្តម យិន សំរាយ** អគ្គលេខាធិការរង ក.ជ.អ.ច. និង**លោកជំទាវ យូ សុភា** អភិបាលរងខេត្តសៀមរាប និងសមាជិក ចូលរួមមកពី ស.ស.យ.ក. មន្ទីរ វិស័យជុំវិញខេត្តសៀមរាប និងមន្ទីរបរិស្ថានខេត្តបាត់ដំបង ឧត្តរមានជ័យ មន្ទាយមានជ័យ ព្រះវិហារ និងខេត្តកំពង់ធំចំនួន ៦០នាក់ មានស្ត្រីចំនួន ២១រូប។សិក្ខាសាលាបានពិភាក្សាផ្តោតលើគោលនយោបាយ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការអភិវឌ្ឍន៍ដោយចីរភាព ចំណេះដឹងវិទ្យាសាស្ត្រនៃការប្រែប្រួលអាកាសធាតុ សេដ្ឋកិច្ចចក្រា ការអភិវឌ្ឍន៍ទីក្រុង ទីក្រុងនីរន្តរភាព ការអភិរក្សជីវៈចម្រុះ វិទ្យាសាស្ត្រ និងនុវានុវត្តន៍ជាដើម។



*រូបភាពទី 3 ៖ វគ្គបណ្តុះបណ្តាលស្តីពីការអភិវឌ្ឍដោយចីរភាព សម្រាប់មន្ត្រីរាជការថ្នាក់ក្រោមជាតិ*



*រូបភាពទី 4 ៖ កិច្ចប្រជុំពិនិត្យនិងផ្តល់យោបល់លើសេចក្តីព្រាងផែនទីបង្ហាញផ្លូវរវាង ក.ជ.អ.ច. និងសាជីវកម្មថាមពលបរមាណូរដ្ឋនៃសហព័ន្ធរុស្ស៊ី (Rosatom)*

## ចង្កោមសកម្មភាពទី៣៖ ការអភិវឌ្ឍផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

- បានប្រជុំពិភាក្សាជាមួយថ្នាក់ដឹកនាំរបស់ក្រសួងរ៉ែនិងថាមពល និងរៀបចំកិច្ចប្រជុំជាមួយក្រុមការងារថ្នាក់ជាតិ ០២លើក ដើម្បីកំណត់គោលជំហររបស់កម្ពុជាចំពោះពង្រាងផែនទីបង្ហាញផ្លូវរវាងក.ជ.អ.ច និងសាជីវកម្មថាមពលបរមាណូរដ្ឋនៃសហព័ន្ធរុស្ស៊ី (Rosatom) ដើម្បីរៀបចំកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការក្នុងការសាងសង់មជ្ឈមណ្ឌលវិទ្យាសាស្ត្រ និងបច្ចេកវិទ្យានុយក្លេអ៊ែរ នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា
- បានប្រជុំតាមប្រព័ន្ធវីដេអូ (Video Conference) ជាមួយភាគីរុស្ស៊ី ដើម្បីពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងផែនទីបង្ហាញផ្លូវរវាង ក.ជ.អ.ច. និងសាជីវកម្មថាមពលបរមាណូរដ្ឋនៃសហព័ន្ធរុស្ស៊ី (Rosatom) ដើម្បីរៀបចំកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការក្នុងការសាងសង់មជ្ឈមណ្ឌលវិទ្យាសាស្ត្រ និងបច្ចេកវិទ្យានុយក្លេអ៊ែរ នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា
- បានប្រជុំតាមប្រព័ន្ធវីដេអូ ជាមួយតំណាងសាជីវកម្ម ថាមពលបរមាណូរដ្ឋនៃសហព័ន្ធរុស្ស៊ីតាមរយៈប្រព័ន្ធអនឡាញ ដើម្បីពិភាក្សាពីការរៀបចំ សេចក្តីព្រាងផែនការកម្មភាព និងផ្សព្វផ្សាយព័ត៌មានក្នុងការលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីការប្រើប្រាស់ថាមពលនុយក្លេអ៊ែរបម្រើឱ្យគោលបំណងសន្តិភាព
- បានស្នើសុំជនបង្គោល ដើម្បីសហការត្រួតពិនិត្យ និងផ្សព្វផ្សាយអត្ថបទព័ត៌មានឱ្យស្របតាមបរិបទសារព័ត៌មានជាតិនិងអន្តរជាតិ និងត្រៀមរៀបចំសិក្ខាសាលា/ វគ្គបណ្តុះបណ្តាលជូនសិស្សនិស្សិត អ្នកជំនាញ និងអ្នកសារព័ត៌មានជាតិ ស្តីពីការប្រើប្រាស់ថាមពលនុយ ក្លេអ៊ែរសម្រាប់បម្រើឱ្យគោលបំណងសន្តិភាព
- បានស្នើសុំមន្ត្រីបង្គោលសម្រាប់ទទួលបន្ទុកអាហាររូបករណ៍សិក្សាជំនាញវិទ្យាសាស្ត្រនុយក្លេអ៊ែរ នៅសហព័ន្ធរុស្ស៊ី ពីក្រសួងអប់រំ យុវជន និង កីឡា
- បានបកប្រែសេចក្តីព្រាងអនុស្សរណៈនៃការយោគយល់រវាង ក.ជ.អ.ច. និង CNNC ស្តីពីការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យថាមពលនុយក្លេអ៊ែរ
- បានរៀបចំសេចក្តីព្រាងអនុស្សរណៈនៃការយោគយល់រវាងក.ជ.អ.ច.និងវិទ្យាស្ថានថាមពលបរមាណូនៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម

- សម្របសម្រួលជាមួយសាលាជាតិកសិកម្មព្រែកលៀបក្នុងការអនុវត្តគម្រោងសិក្សាពីវត្តមាននិងការបំបាត់បាក់តេរីក្នុងការចិញ្ចឹមគោយកសាច់នៅក្នុងប្រទេសកម្ពុជា
- កំពុងរៀបចំឯកសារគោលគំនិតស្តីពីការចុះប្រមូលព័ត៌មាន និងទិន្នន័យស្តីពីវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា នៅក្នុងវិស័យឧស្សាហកម្ម
- បន្តអនុវត្តអនុស្សរណៈនៃការយោគយល់ស្តីពីកិច្ចសហប្រតិបត្តិការក្នុងវិស័យបរិស្ថាននិងធនធានធម្មជាតិរវាងក.ជ.អ.ច./ក្រសួងបរិស្ថានជាមួយអង្គការពិព័រណ៍វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាកម្ពុជា (STEM) និងអង្គការស្ទីមកម្ពុជា (STEAM) លើការកសាងសមត្ថភាព
- បានបញ្ចប់សេចក្តីព្រាងនៃកម្មវិធីសិក្សាស្រាវជ្រាវថ្នាក់ជាតិ និងក្រមសីលធម៌ស្រាវជ្រាវ
- បានរៀបចំសម្របសម្រួលអនុវត្តគម្រោង«ការជំរុញមធ្យោបាយដឹកជញ្ជូនបៃតងតាមរយៈការប្រើប្រាស់យានយន្តអគ្គិសនីនៅកម្ពុជា» ដោយសហប្រតិបត្តិការជាមួយវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកលប្រមូលព័ត៌មានទាក់ទងនឹងការប្រើប្រាស់យានយន្តអគ្គិសនីពីក្រសួងស្ថាប័នពាក់ព័ន្ធ និងវិស័យឯកជន និងត្រៀមរៀបចំសិក្ខាសាលាផ្សព្វផ្សាយក្នុងខែសីហា
- បានសហការ និងសម្របសម្រួលជាមួយមជ្ឈមណ្ឌល បច្ចេកវិទ្យាបៃតងសាធារណៈរដ្ឋកូរ៉េលើការបចំសិក្ខាសាលាចាប់ផ្តើមគម្រោង«ការដឹកជញ្ជូនបៃតង នៅកម្ពុជា»
- ជំរុញអង្គការអភិវឌ្ឍន៍ឧស្សាហកម្មសហប្រជាជាតិ UNIDOឱ្យចាប់ផ្តើមអនុវត្តគម្រោង «ការវាយតម្លៃតម្រូវ ការបច្ចេកវិទ្យាសម្រាប់តំបន់សេដ្ឋកិច្ចពិសេសក្នុងខេត្តព្រះសីហនុ»ដែលទទួលបានមូលនិធិពីមូល និធិអាកាសធាតុបៃតង (GCF)
- បានសហការជាមួយកម្មវិធីភាពធន់នឹងអាកាសធាតុ (SPCR) និងកម្មវិធីសម្ព័ន្ធភាព ប្រែប្រួលអាកាសធាតុ កម្ពុជា (CCCA)
- បានពិភាក្សាជាមួយលោក Kim Yong Beum ប្រធាន សមាគមធុរកិច្ចកូរ៉េ-កម្ពុជា ដើម្បីស្វែងរកការគាំទ្រពីកូរ៉េ លើការអនុវត្តការងារអាទិភាពរបស់នាយកដ្ឋាន
- បានរៀបចំសំណើគម្រោងកសាងភាពធន់ក្នុងសហគមន៍ជនបទ ដើម្បីជីវភាពរស់នៅកាន់តែប្រសើរឡើង តាមរយៈការប្រើប្រាស់ប្រព័ន្ធបូមទឹកសូឡា សម្រាប់ ស្នើសុំពីមូលនិធិកិច្ចសហប្រតិបត្តិការមេគង្គសា ធារណរដ្ឋកូរ៉េជុំទី៤ និងមូលនិធិមេគង្គឡាងឆាង(Langcang-Mekong Cooperation Special Fund)
- បន្តកៀរគរដៃគូអភិវឌ្ឍន៍និងមូលនិធិនានា សម្រាប់អនុវត្តគម្រោងដើម្បីរៀបចំកម្មវិធីសិក្សា ស្រាវជ្រាវ
- បានរៀបចំ បង្កើតគណៈកម្មាធិការ និងក្រុមការងារបច្ចេកទេសសម្រាប់សម្របសម្រួល គម្រោងស្រាវជ្រាវ ដោយមជ្ឈមណ្ឌលគោលនយោបាយយុទ្ធសាស្ត្រនិង នវានុវត្តន៍ (CSIP) សហការជាមួយក្រសួងបរិស្ថាន
- បានចុះហត្ថលេខាលើកិច្ចព្រមព្រាងលើគម្រោងសិក្សាស្រាវជ្រាវចំនួន ០២ជាមួយ មជ្ឈមណ្ឌលគោល នយោបាយយុទ្ធសាស្ត្រ និងនវានុវត្តន៍ (CSIP)និង កំពុងប្រមូលព័ត៌មានពាក់ព័ន្ធ ដើម្បីគាំទ្រដល់ការស្រាវជ្រាវសម្រាប់គម្រោងខាងលើ។



*រូបភាពទី 5 ៖ ចុះហត្ថលេខាលើកិច្ចព្រមព្រៀងរវាងក.ជ.អ.ច. និងមជ្ឈមណ្ឌលគោលនយោបាយយុទ្ធសាស្ត្រ និងនវានុវត្តន៍*

ទំព័រ ៧

## ចង្កោមសកម្មភាពទី៤ ៖ ការអភិវឌ្ឍសេដ្ឋកិច្ចបៃតង

- ថ្នាក់ដឹកនាំក្រសួងបរិស្ថានបានសម្រេចធ្វើការផ្លាស់ប្តូរទីតាំងដំឡើងបន្ទះថាមពលពន្លឺព្រះអាទិត្យពីលើដំបូលអគារមេរតកតេជោនាទីស្តីការក្រសួងបរិស្ថានទៅកាន់ទីតាំងទី(១)មជ្ឈមណ្ឌលស្រាវជ្រាវ និងអភិរក្សកេសរកុល សុខ អាន ភ្នំគូលែន នៅខេត្តសៀមរាប និងទីតាំងទី(២) សហគមន៍ស្រែអំពិល ឃុំក្តុលស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង។ សម្រាប់ការផ្លាស់ប្តូរទៅកាន់ទីតាំងទី១គឺមានការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសពីអង្គការកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP)
- បានសម្របសម្រួលបញ្ចប់ការសិក្សាបុរេសមិទ្ធិលទ្ធភាពស្តីពី ការទាញយកឥន្ទនៈចំហេះពីសំណល់ (Refuse Derived Fuel - RDF)និងបន្តសហការជាមួយវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល(GGGI) ដើម្បីធ្វើការសិក្សាបុរេសមិទ្ធិលទ្ធភាពពេញលេញលើគម្រោងRDF ក្រោយពីមានការឯកភាពពីថ្នាក់ដឹកនាំក្រសួងបរិស្ថាន



*រូបភាពទី 6 ៖ កិច្ចប្រជុំក្រុមការងារបច្ចេកទេសទីក្រុងនីរន្តរភាព*

- បានទទួលគម្រោងស្តីពីការត្រួតពិនិត្យគុណភាពទឹកដោយនិរន្តរភាពនៅខេត្តក្រចេះ (Sustainable Water Quality Monitoring in Kratie province) ក្នុងឆ្នាំ២០២០ ប៉ុន្តែគម្រោង នេះត្រូវបានពន្យាពេលអនុវត្តដោយសារបញ្ហារីករាលដាលជាសកលនូវជំងឺកូវីត១៩
- បានសហការជាមួយអង្គការ UNDP រៀបចំកិច្ចប្រជុំចំនួន២លើក នៃក្រុមការងារបច្ចេកទេសវាយតម្លៃសក្តានុពលថាមពលពន្លឺព្រះអាទិត្យក្នុងឆ្នាំ២០២០។ ក្រុមការងារបច្ចេកទេសបានបានរៀបចំសេចក្តីព្រាងចុងក្រោយលើឯកសារស្តីពីការវាយតម្លៃសេដ្ឋកិច្ចលើសក្តានុពលថាមពលពន្លឺព្រះអាទិត្យនៅកម្ពុជាដោយមានការគាំទ្រពីអង្គការ UNDP ដែលគ្រោងនិងបញ្ចប់នាបំណាច់ឆ្នាំ២០២០
- បានប្រជុំពិនិត្យ ទៅលើខ្លឹមសារកែសម្រួលលើសេចក្តីព្រាងនៃកិច្ចព្រមព្រៀងគម្រោងស្តីពីការលើកកម្ពស់ការអនុវត្តថាមពលនិរន្តរភាពនៅក្នុងវិស័យវាយនភ័ណ្ឌនៅកម្ពុជា (Project Agreement on Promotion of Sustainable Energy Practice in the garment sector in Cambodia) ដើម្បីធ្វើការពិភាក្សាជាមួយតំណាង GGGI
- បានដាក់បញ្ចូល និងមានការឆ្លងយោបល់ជាមួយក្រុមប្រឹក្សាជាតិភាសាខ្មែរ នូវពាក្យចំនួន ២ រួមមាន ១)ការប្រើប្រាស់ និងផលិតកម្មដោយនិរន្តរភាព និង ២)ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រទៅក្នុងបច្ចេកសព្ទនៃសេចក្តីព្រាងក្រមបរិស្ថាន និងធនធានធម្មជាតិ
- បានប្រជុំ និងពិនិត្យលើចំណុចមួយចំនួន ដើម្បីត្រៀមពិភាក្សាពីលទ្ធភាពក្នុងការចុះអនុស្សរណៈនៃការយោគយល់គ្នា(MoU) ជាមួយអង្គការអនុផលព្រៃឈើ(NTFP-EP) វគ្គបណ្តុះបណ្តាលកៀរគរថវិកាសម្រាប់សកម្មភាពបន្ត ផែនការសកម្ម ភាពក្នុងការរៀបចំបង្កើតគណៈកម្មការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ (SEA) ការកសាងសមត្ថភាពវគ្គបណ្តុះបណ្តាល និងការប្រើប្រាស់ធនធានដោយ

ទំព័រ ៨

ប្រសិទ្ធិភាព (Resource Efficiency) បានសម្របសម្រួលរៀបចំកិច្ចប្រជុំលើកទី៣ របស់ក្រុមការងារបច្ចេកទេសទីក្រុងនិរន្តរភាព

- បានសម្របសម្រួលរៀបចំសេចក្តីព្រាងចុងក្រោយលើឯកសារផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុងនិរន្តរភាព ឆ្នាំ២០២០-២០៣០ សម្រាប់ក្រុងគោលដៅទាំងប្រាំពីររួមមាន៖ ក្រុងកែប ព្រះសីហនុ បាត់ដំបង សៀមរាប កំពង់ចាម សួង និងក្រុងបាវិត
- បានសម្របសម្រួលរៀបចំសេចក្តីព្រាងសំណើសុំគម្រោងមូលនិធិកម្មវិធីប្រសិទ្ធភាពនៃប្រព័ន្ធត្រជាក់គីហ្គាលី(Kigali Cooling Efficiency Program: K-CEP)



*រូបភាពទី 7 ៖ កម្មវិធីបញ្ជ្រាបសារសេដ្ឋកិច្ចចក្រា*

- បានសម្របសម្រួលរៀបចំសេចក្តីព្រាងសៀវភៅណែនាំការបណ្តុះបណ្តាលសម្រាប់កម្មវិធីកសាងសមត្ថភាព/បណ្តុះបណ្តាលមន្ត្រីបង្គោល ស្តីពីការអភិវឌ្ឍទីក្រុងនិរន្តរភាពនៅកម្ពុជា
- បានរៀបចំសេចក្តីសម្រេចស្តីពី ការបង្កើតក្រុមការងារបច្ចេកទេសគម្រោងរៀបចំគោលការណ៍ណែនាំ និងវិញ្ញាបនបត្រកម្មអគារបៃតងនៅកម្ពុជា
- បានរៀបចំជាសេចក្តីព្រាងចុងក្រោយគោលការណ៍ណែនាំបច្ចេកទេសស្តីពីការិយាល័យបៃតង និងព្រឹត្តិការណ៍បៃតង (Green Event)ជាភាសាខ្មែរ និងជាភាសាអង់គ្លេស និងបានដាក់ឆ្លងកិច្ចប្រជុំក្រុមការងារទីក្រុងនិរន្តរភាពលើកទី៣



រូបភាពទី ៨ ៖ កិច្ចប្រជុំជាមួយក្រសួងមហាផ្ទៃ និង GGGI ដើម្បីពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពសម្រាប់ក្រុងគោលដៅទាំង៧

### អនុកម្មវិធីទី២៖ជំរុញការអនុវត្តឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ

### ចង្កោមសកម្មភាពទី៥ ៖ អប់រំ ផ្សព្វផ្សាយព័ត៌មាន លើកកម្ពស់ការយល់ដឹង និងបញ្ជ្រាបការងារប្រែប្រួលអាកាសធាតុ

- បានរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសប្រែប្រួលអាកាសធាតុនិងដៃគូអភិវឌ្ឍន៍ស្តីពីបច្ចុប្បន្នភាពនៃដំណើរការការចូលរួមចំណែករបស់ជាតិ ដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ»កិច្ចប្រជុំនេះរៀបចំឡើងក្នុងគោលបំណងដើម្បី៖១) ធ្វើបច្ចុប្បន្នភាពដល់ក្រសួងស្ថាប័នពាក់ព័ន្ធនិងដៃគូអភិវឌ្ឍន៍ និងឯកភាពលើដំណើរការរៀបចំឯកសារ ស្តីពីការចូលរួមចំណែករបស់ជាតិ ដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (Nationally Determined Contribution-NDC) ២) ពង្រឹងការចូលរួមរបស់អ្នកពាក់ព័ន្ធ និង ទាក់ទាញចំណាប់អារម្មណ៍របស់អ្នកពាក់ព័ន្ធ

ក្នុងដំណើរការរៀបចំរបាយការណ៍បច្ចុប្បន្នភាព NDC និង៣) ស្វែងយល់ពីតួនាទី និងទំនួលខុសត្រូវរបស់ភាគីពាក់ព័ន្ធ សំខាន់ៗ។ កិច្ចប្រជុំនេះបានធ្វើបច្ចុប្បន្នភាពនៃដំណើរការរៀបចំឯកសារ ស្តីពី ការចូលរួមចំណែករបស់ជាតិ ដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ និងបានផ្ញើទម្រង់បំពេញព័ត៌មានដល់ក្រសួងស្ថាប័នពាក់ព័ន្ធនិងដៃគូអភិវឌ្ឍន៍ចំនួន ១៥ ដើម្បីផ្តល់ធាតុចូលនៃផែនការសកម្មភាព អាទិភាពតាមវិស័យរបស់ខ្លួន។



*រូបភាពទី ១ ៖ កិច្ចប្រជុំក្រុមការងារបច្ចេកទេសប្រែប្រួលអាកាសធាតុនិងដៃគូអភិវឌ្ឍន៍*

- បានរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសប្រែប្រួលអាកាសធាតុនិងដៃគូអភិវឌ្ឍន៍ស្តីពី«ការផ្តល់សុពលភាពលើរបាយការណ៍ការចូលរួមចំណែករបស់ជាតិដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ» កិច្ចប្រជុំនេះដឹកនាំដោយ **ឯកឧត្តម ទិន ពន្លក** រដ្ឋលេខាធិការក្រសួងបរិស្ថាន អនុប្រធានទី២ ក.ជ.អ.ច. និងជាប្រធានក្រុមការងារបច្ចេកទេសប្រែប្រួលអាកាសធាតុ ដោយមានការចូល រួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាសមាជិកក្រុមការងារបច្ចេកទេសប្រែប្រួលអាកាសធាតុ តំណាងស្ថានទូត ដៃគូអភិវឌ្ឍន៍ វិស័យឯកជន គ្រឹះស្ថានឧត្តមសិក្សា និងអ្នកពាក់ព័ន្ធផ្សេងៗទៀត សរុបចំនួនប្រមាណ ៧០នាក់។

- ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញបានចូលរួមវគ្គបណ្តុះបណ្តាល កិច្ចប្រជុំ សន្និសីទអន្តរជាតិនានាចំនួន ០៧ លើក កិច្ចប្រជុំបានផ្តោតសំខាន់លើការងារពង្រឹងកិច្ចសហប្រតិបត្តិការក្នុងតំបន់ និងអន្តរជាតិលើការអនុវត្តអនុសញ្ញាពិធីសារនិងកិច្ចព្រមព្រៀងនានាពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ។ ជាលទ្ធផល មន្ត្រីនាយកដ្ឋានបានទទួលនូវចំណេះដឹងតម្លាភាព ក្រោមមាត្រា៦ក្នុងការអនុវត្តកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីអាកាសធាតុ ការស្វែងយល់តួនាទីនិង ភារកិច្ចរបស់ក្រុមអ្នកជំនាញនៃប្រទេសអភិវឌ្ឍន៍តិចតួច (LEG) ការពង្រឹងការអនុវត្តការចូលរួមចំណែកថ្នាក់ជាតិដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពី ការប្រែប្រួលអាកាសធាតុប្រព័ន្ធសារពើភណ្ឌឧស្ម័នផ្ទះកញ្ចក់ និងហិរញ្ញប្បទានអាកាសធាតុ ការពង្រឹងអំណាចស្ត្រីសម្រាប់សង្គមដែលធន់ នឹង អាកាសធាតុ។
- ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញបានចូលរួមកិច្ចប្រជុំក្រុម ការងារក្នុងក្របខ័ណ្ឌអាស៊ានបានចំនួន ០១ លើក ដោយកិច្ចប្រជុំនេះបានផ្តោតសំខាន់លើការងារ ពង្រឹងកិច្ចសហប្រតិបត្តិការក្នុងចំណោមសមាជិកអាស៊ានលើការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ កិច្ចប្រជុំនេះបានចែករំលែកបទពិសោធន៍របស់ក្រុមការងារគាំទ្រដោយកម្មវិធីការលើកកម្ពស់បរិធានច្បាប់អឺរ៉ុប-អាស៊ាន បច្ចុប្បន្នភាពលើគម្រោងហិរញ្ញប្បទានអាកាស ធាតុដែលមានប្រទេសប្រុយណេ និងប្រទេស ហ្វីលីពីនជាប្រទេសនាំមុខអនុវត្តគម្រោងMRVនិងគម្រោង Strengthening Science and Policy Interface in Climate Change related

ទំព័រ ១០

Decision-Making Process/ Long Term Strategies

- បានចូលរួមកិច្ចប្រជុំតាមប្រព័ន្ធអនឡាញសម្រាប់កិច្ចប្រជុំក្រុមការងារប្រែប្រួលអាកាសធាតុអាស៊ាន (ASEAN Working Group on Climate Change- AWGCC) លើកទី១១
- ដោយសារស្ថានភាពជំងឺ Covid-19 បានផ្ទុះឡើងពាសពេញពិភពលោក កិច្ចប្រជុំសន្និសីទបណ្តារដ្ឋភាគីជាសមាជិកនៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ ដែលគ្រោងរៀបចំឡើងនៅប្រទេសអង់គ្លេស នៅចុងឆ្នាំ២០២០ ត្រូវបានពន្យារពេលទៅចុងឆ្នាំ២០២១។ការលើកពេលនៃកិច្ចប្រជុំនេះ កម្ពុជានឹងមិនតម្រូវឱ្យរៀបចំគោលជំហររបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់សន្និសីទនេះទេ ប៉ុន្តែថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាននៅតែបន្តទំនាក់ទំនងដោយផ្ទាល់ជាមួយលេខាធិការដ្ឋាន UNFCCC និងស្ថានទូតចក្រភពអង់គ្លេសដើម្បីបង្ហាញអំពីជំហររបស់រាជរដ្ឋាភិបាលកម្ពុជា ចំពោះសន្និសីទនេះ។ នាយកដ្ឋានបានធ្វើកំណត់ បង្ហាញករណីស្ថានទូតចក្រភពអង់គ្លេសប្រចាំ នៅកម្ពុជាជូនដំណឹងស្តីពីការយល់ព្រមរបស់ការិយាល័យសន្និសីទកំពូលសហប្រជាជាតិលើកទី២៦ នៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (COP to the UNFCCC) ក្នុងការលើកពេលសន្និសីទកំពូល សហប្រជាជាតិលើកទី២៦ (COP26) ចាប់ពីថ្ងៃ ទី១ ដល់១២ ខែវិច្ឆិកា ឆ្នាំ២០២១ តាមសំណើ កាលបរិច្ឆេទថ្មីរបស់ចក្រភពអង់គ្លេស និងបាន រៀបចំលិខិតឆ្លើយតបគាំទ្រចក្រភពអង់គ្លេស
- បានចូលរួមសិក្ខាសាលាថ្នាក់តំបន់តាមអនឡាញលើកទី៨ ស្តីពីការសន្ទនាអំពីសកម្មភាពសម្រាប់រួមចំណែកលើក កម្ពស់ដល់អាកាសធាតុ។ ដោយសិក្ខាសាលាថ្នាក់តំបន់លើកទី៨នេះរៀបចំដោយលេខាធិការដ្ឋាននៃអនុសញ្ញាក្របខ័ណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ(UNFCCC) រួមសហការជាមួយអង្គការយូណេស្កូ ក្នុងគោលបំណងផ្តល់នូវវេទិកាពិភាក្សាមួយសម្រាប់ភាគីទាំងអស់ និង ភាគីមិនពាក់ព័ន្ធដទៃ ទៀតដើម្បីជំរុញការពិភាក្សាលើអនុសាសន៍ និងទស្សនៈស្តីពីការងារនាពេលអនាគត ដើម្បីលើកកម្ពស់ការអនុវត្តសកម្មភាពសម្រាប់ការផ្តល់ អំណាចលើការងារទាក់ទងនឹងអាកាសធាតុ។ វេទិកានេះក៏ផ្តល់នូវសារៈតានិងធ្វើការចែករំលែក ចំណេះដឹងក្នុងចំណោមភាគីទាំងអស់និងភាគីមិនពាក់ព័ន្ធដទៃទៀតអំពីប្រទេសនីមួយៗដែលត្រូវដាក់បញ្ចូលរួមគ្នាតែមួយទាក់ទងនឹងដំណើរការការងារ NDC នៅក្នុងស្ថានភាពបច្ចុប្បន្ននៃការអនុវត្ត ACE
- បានចូលរួមកិច្ចប្រជុំតាមវេទិកាអនឡាញស្តីពីការស្តារឡើងវិញពីស្ថានភាពកូវីត១៩ នូវភាពធន់និងចីរភាព ថ្នាក់រដ្ឋមន្ត្រីក្រសួងបរិស្ថានពីបណ្តាប្រទេសជាសមាជិកអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ។គោលបំណងនៃកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីបរិស្ថាននេះមាន គោលបំណង៖ ១. ផ្លាស់ប្តូរបទពិសោធន៍ និង វិធានការកម្រិតខ្ពស់ដើម្បីកសាងប្រព័ន្ធសេដ្ឋកិច្ចសង្គមឱ្យមានភាពធន់និងចីរភាពក្នុងដំណើរការបន្ទាប់ពីការស្តារស្ថានភាពកូវីត១៩រួចមក២.បង្កើតជម្រើសគោលនយោបាយកម្រិតខ្ពស់ដើម្បីគ្រប់គ្រងហានិភ័យចម្រុះ និង៣.រក្សាកិច្ចសហ ប្រតិបត្តិការអន្តរជាតិ រួមទាំងតាមរយៈវេទិកាសប្តាហ៍

ទំព័រ ១១

អាកាសធាតុថ្នាក់តំបន់នៅឆ្នាំ ២០២១ និងសន្និសីទកំពូលសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុលើកទី២៦ (CoP26)។ លើសពីនេះទៀតចំណុចសំខាន់ ហិរញ្ញវត្ថុ និងផែនការសកម្មភាពបន្តក្នុងការធ្វើដំណើរការនៃការរៀបចំរបាយការណ៍បច្ចុប្បន្នភាព NDC រួមទាំង ផលប៉ះពាល់សេដ្ឋកិច្ចសង្គមនៅបណ្តាប្រទេសនៅអាហ្វ្រិកផងដែរ។



*រូបភាពទី 10 ៖ កិច្ចប្រជុំរៀបចំរបាយការណ៍បច្ចុប្បន្នភាព NDC*

- បានសម្របសម្រួលជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបង់វិភាគទានសមាជិកអនុសញ្ញា UNFCCC ពិធីសារក្យូតូ និងកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីអាកាសធាតុ រួចរាល់ហើយ។

**ចង្កោមសកម្មភាពទី៦៖ រៀបចំក្របខ័ណ្ឌគតិយុត្តតាមដានការអនុវត្តផែនការយុទ្ធសាស្ត្រ និងសិក្សាស្រាវជ្រាវវាយតម្លៃលើកកម្ពស់ការកសាងសមត្ថ ភាពសម្របសម្រួលនិងសហការជាមួយស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ តំបន់អាស៊ាន និងអន្តរជាតិ ព្រមទាំងកៀរគរការគាំទ្រទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ**

- បានរៀបចំនិងបោះពុម្ពសទ្ទានុក្រមការប្រែប្រួលអាកាសធាតុ
- ឯកសារស្តីពីការសិក្សាស្វែងយល់លើទស្សនសាធារណជនចំពោះការប្រែប្រួលអាកាសធាតុនៅកម្ពុជា «ចំណេះដឹង ឥរិយាបថ និងការអនុវត្តរបស់ សាធារណជនចំពោះការប្រែប្រួលអាកាសធាតុ»
- ឯកសារអប់រំស្តីពីការប្រែប្រួលអាកាសធាតុសម្រាប់មធ្យមសិក្សាទុតិយភូមិ
- ឯកសារជំនួយស្មារតីស្តីពីការប្រែប្រួលអាកាសធាតុសម្រាប់មធ្យមសិក្សា
- ផែនការសកម្មភាពការប្រែប្រួលអាកាសធាតុ ២០១៦-២០១៨
- ខិត្តប័ណ្ណព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុ
- ឯកសាររបាយការណ៍បច្ចុប្បន្នភាពពីរឆ្នាំម្តងលើកទី១ របស់កម្ពុជាក្រោមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពី ការប្រែប្រួលអាកាសធាតុ។
- បានសហការរៀបចំសិក្ខាសាលាជាមួយមន្ទីរបរិស្ថានខេត្តសៀមរាបដើម្បី៖ ១- ផ្សព្វផ្សាយ និងចែករំលែកព័ត៌មានផ្សេងៗ ពាក់ព័ន្ធនឹងច្បាប់ គោលនយោបាយ កម្មវិធី និងយន្តការសំខាន់ៗក្នុងការលើកកម្ពស់សមភាពយេនឌ័រ ការពង្រឹងអំណាចរបស់ស្ត្រី និងការចូលរួមរបស់កុមារ និងយុវជន និង ២- បង្កើនការយល់ដឹង និងលើកកម្ពស់ការចំណាយថវិកានិងជម្រុញការរៀបចំផែនការថវិកាឆ្លើយតបនឹងយេនឌ័រដើម្បីធានាថាគ្រប់អ្នកពាក់ព័ន្ធទាំងបុរស ស្ត្រី កុមារា កុមារី និងក្រុមងាយរងគ្រោះដទៃទៀតទទួលបានផលប្រយោជន៍
- បានចូលរួមកម្មវិធីបោះតង់បរិស្ថានក្រោមប្រធានបទ« ថ្ងៃនៃក្តីស្រឡាញ់៖ យើងស្រឡាញ់បរិស្ថាន និងធម្មជាតិ» Valentine's Prey Lang ត្រូវបានរៀបចំឡើងនៅក្នុងតំបន់ដែនជម្រកសត្វព្រៃព្រៃឡង់ ភូមិសាស្ត្រខេត្តកំពង់ធំ ក្រោមការដឹកនាំ

របស់ ឯកឧត្តម សៅ សុភាព រដ្ឋលេខាធិការក្រសួងបរិស្ថាន និងមានការចូលរួមពីឯកឧត្តមតំណាងរាស្ត្រខេត្តកំពង់ធំ គណៈអភិបាលខេត្តកំពង់ធំ អភិបាលស្រុក មន្ទីរបរិស្ថានខេត្តកំពង់ធំ ក្រចេះ ស្ទឹងត្រែង ព្រះវិហារ សៀមរាប ឧត្តរមានជ័យ បន្ទាយមានជ័យ កែប តាកែវ ស្វាយរៀង កោះកុង និងមានការចូលរួមពីបណ្តាដៃគូអភិវឌ្ឍន៍ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល សហគមន៍មូលដ្ឋាននានាផងដែរ។ គោលបំណងបណ្តុះស្មារតី មន្ត្រីរាជការ អាជ្ញាធរ ប្រជាជន សហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធនានា ជាពិសេសយុវជនឱ្យចេះស្រឡាញ់ និងជំរុញឱ្យមានការចូលរួមកាន់តែសកម្មក្នុងការការពារ អភិរក្សធនធានធម្មជាតិ ជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី ដើម្បីជាប្រយោជន៍ដល់សង្គមជាតិ

- បានសម្របសម្រួល និងសហការជាមួយ BBC Media Action ដើម្បីសិក្សាស្រាវជ្រាវស្វែងយល់ទស្សនៈសាធារណជនចំពោះការប្រែប្រួលអាកាសធាតុនៅកម្ពុជា «ចំណេះដឹង ឥរិយាបថ និងការអនុវត្តរបស់សាធារណជនចំពោះការប្រែប្រួលអាកាសធាតុ» លើកទី៣។ ការសិក្សាស្វែងយល់នេះធ្វើឡើងក្នុងគោលបំណងដើម្បី៖(១) បញ្ជាក់ពីសុពលភាពនៃការសិក្សាលើកទី១ និងលើកទី២ (២) វាយតម្លៃពីការប្រែប្រួលចំណេះដឹង ឥរិយាបថ និងការអនុវត្តនៅទូទាំងប្រទេសកម្ពុជាដោយយោងតាមវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុថ្នាក់ជាតិលើកទី១ និងលើកទី២ និង (៣) វាយតម្លៃពីផលប៉ះពាល់ និងប្រសិទ្ធភាពនៃសកម្មភាពលើកកម្ពស់ការយល់ដឹងជាសាធារណៈដែលបានធ្វើឡើងទាំងពីរលើក។ ការត្រៀមរៀបចំបទសម្ភាសន៍ និងសង្កេតមើលបទសម្ភាសន៍ Pilot Test របស់ BBC Media Action នៃការសិក្សាស្វែងយល់លើទស្សនសាធារណជនចំពោះការប្រែប្រួលអាកាសធាតុនៅកម្ពុជា «ចំណេះដឹង ឥរិយាបថ និងការអនុវត្តរបស់សាធារណជនចំពោះការប្រែប្រួលអាកាសធាតុ» នៅAsia Euro University (AEU) រាជធានីភ្នំពេញ។
- បានចូលរួមជាគណៈកម្មការ ជ្រើសរើសអ្នកជំនាញការក្នុងការរៀបចំសំណើគម្រោងពេញលេញសម្រាប់ក្រសួងអភិវឌ្ឍន៍ជនបទ ក្រោមជំនួយរបស់CCCA
- បានចូលរួម និងសម្របសម្រួលក្នុងកិច្ចប្រជុំស្តីពី CCAPsនិងNDCនៅទីស្តីការក្រសួងសាធារណៈការនិងដឹកជញ្ជូន
- បានចូលរួម និងសម្របសម្រួលទស្សនកិច្ចសិក្សាលើទីតាំងស្ថានីយទឹកស្អាតO-weនៅសាលាបឋមសិក្សាកំពង់ស្វាយ ដែលស្ថិតនៅឃុំកំពង់ស្វាយ ស្រុកកៀនស្វាយ ខេត្តកណ្តាល
- បានចូលរួម និងសម្របសម្រួលក្នុងសិក្ខាសាលាចាប់ផ្តើមផែនការសកម្មភាពការប្រែប្រួលអាកាសធាតុកម្ពុជា ក្នុងវិស័យថាមពល ឆ្នាំ២០២០-២០២៣ ត្រូវបានសហការរៀបចំដោយក្រសួងរ៉ែ និងថាមពល និងកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា
- បានចូលរួម និងសម្របសម្រួលក្នុងកិច្ចប្រជុំក្រុមការងារលេខាធិការដ្ឋាន JCM និងពិនិត្យសំណើគម្រោង CORSIA ដឹកនាំដោយលោកបណ្ឌិត ហាក់ ម៉ៅ ប្រធាននាយកដ្ឋានប្រែប្រួលអាកាស
- បានចូលរួម និងសម្របសម្រួលក្នុងកិច្ចប្រជុំពិនិត្យសំណើគម្រោងនវានុវត្តន៍ការប្រែប្រួលអាកាសធាតុចំនួន៦ និងផ្តល់អនុសាសន៍ក្នុងការកែ

លម្អមុននឹងផ្តល់មូលនិធិឱ្យ។
- បានចូលរួម និងសម្របសម្រួលក្នុងកិច្ចប្រជុំពិនិត្យវឌ្ឍនភាព នៃដំណើរការរៀបចំផែនការសកម្មភាពការប្រែប្រួលអាកាសធាតុក្នុងវិស័យអភិវឌ្ឍន៍ជនបទ វិស័យរ៉ែ និងថាមពល
- បានចូលរួម និងសម្របសម្រួលក្នុងកិច្ចប្រជុំពិគ្រោះយោបល់ដើម្បីពិនិត្យលើរបាយការណ៍វាយតម្លៃ សេដ្ឋកិច្ចសង្គម ជីវៈចម្រុះ និងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុក្រោមគម្រោង «ការកសាងភាពធន់នឹងអាកាសធាតុនៃប្រព័ន្ធទីក្រុងតាមរយៈការបន្សាំដោយផ្អែកលើប្រព័ន្ធអេកូឡូស៊ីនៅតំបន់អាស៊ីប៉ាស៊ីហ្វិក»
- បានចូលរួម និងសម្របសម្រួលក្នុងសិក្ខាសាលាវិបស្សនារបស់កម្មវិធី និងគម្រោងដែលអនុវត្តដោយនាយកដ្ឋានប្រែប្រួលអាកាសធាតុ
- បានធ្វើការសម្របសម្រួលពិនិត្យឡើងវិញនូវទិន្នន័យ និងព័ត៌មានដែលបានប្រមូលពីស្ថាប័នពាក់ព័ន្ធដើម្បីរៀបចំរបាយការណ៍ការរួមចំណែករបស់ថ្នាក់ជាតិ ដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ដោយពិនិត្យទៅលើទិន្នន័យខ្វះចន្លោះ សកម្មភាពដូចគ្នា និងផ្តល់ជាអនុសាសន៍
- បានចូលរួមសម្របសម្រួលក្នុងប្រជុំធ្វើបច្ចុប្បន្នភាពការងាររយៈពេល ៣ខែទៀត របស់CCCA និង DCC ត្រូវបានពិនិត្យឡើងវិញដោយមានការបញ្ចូលផែនការនាយកដ្ឋានប្រែប្រួលអាកាសធាតុ ដើម្បី ធានាថាផែនការការងាររបស់CCCA និង DCCត្រូវបានធ្វើរួមគ្នា
- បានចូលរួមសម្របសម្រួលក្នុងកិច្ចប្រជុំ ដើម្បីពិនិត្យមើល និងកែសម្រួលខ្លឹមសារ ពាក្យពេចន៍រចនា សម្ព័ន្ធដឹកនាំ សម្របសម្រួល និងតួនាទីរបស់លេខាធិការដ្ឋានក្នុងការសម្របសម្រួលអនុវត្តសេចក្តីព្រៀងអនុក្រឹត្យស្តីពី យន្តការកាត់បន្ថយ ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់
- បានចូលរួមក្នុងកិច្ចប្រជុំ ដើម្បីពិនិត្យផែនការសកម្មភាព ឆ្នាំ២០២០ ក្រោមការសម្របសម្រួល និងដឹកនាំដោយលោកបណ្ឌិត ហេង ចាន់ធឿន ដោយមានការចូលរួមពីសហការីជាប្រធានការិយាល័យ អនុប្រធានការិយាល័យ និងមន្ត្រីជំនាញដែលនាយកដ្ឋានបានអនុវត្តផែនការសកម្មភាពធៀបនឹងលទ្ធផលរំពឹងទុកសម្រាប់ធមាសទី១ ឆ្នាំ ២០២០ និងលទ្ធផលសម្រេចបាននេះ នឹងដាក់ជូន នាយកដ្ឋានរដ្ឋបាល ផែនការនិង ហិរញ្ញវត្ថុ
- បានចូលរួមសម្របសម្រួលក្នុងកិច្ចប្រជុំពិភាក្សាស្តីពី ការស្នើលើកសកម្មភាពបន្សាំនិងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ទៅក្នុងផែនការសកម្មភាពប្រែប្រួលអាកាសធាតុកម្ពុជា នៅក្រសួងសាធារណការ និងដឹកជញ្ជូន
- បានចូលរួមសម្របសម្រួលក្នុងសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការរៀបចំប្រព័ន្ធវាស់វែងរាយការណ៍ និងការផ្ទៀងផ្ទាត់សម្រាប់គោលនយោបាយថាមពលកកើតឡើងវិញ
- បានចូលរួមសម្របសម្រួលនិងចែករំលែកបទពិសោធន៍ក្នុងកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិស្តីពីរបាយការណ៍វាយតម្លៃថ្នាក់ជាតិនៅកម្ពុជាៈស្ថានភាពសមភាពយេនឌ័រ និងការប្រែប្រួលអាកាសធាតុនៅវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា( CDRI )
- បានចូលរួមសម្របសម្រួលសិក្ខាសាលាពិគ្រោះយោបល់ស្តីពី ការរៀបចំប្រព័ន្ធវាស់វែងរាយការណ៍ និងការផ្ទៀងផ្ទាត់សម្រាប់គោលនយោ បាយថាម

ទំព័រ ១៤

ពលកកើតឡើងវិញ សិក្ខាសាលានេះមានគោលបំណងដើម្បីពិនិត្យ ផ្ទៀងផ្ទាត់ និងប្រមូលនូវធាតុចូលបន្ថែមដើម្បី រៀបចំប្រព័ន្ធវាស់វែង រាយការណ៍ និងការផ្ទៀង ផ្ទាត់សម្រាប់គោលនយោបាយថាមពលកកើតឡើងវិញ

- បានចូលរួមសម្របសម្រួលក្នុងកិច្ចប្រជុំពិភាក្សាលើសំណើគម្រោង CORSIA ជាមួយលោក Kenichi Bessho លេខាទី១ នៃស្ថានទូត ជប៉ុនប្រចាំប្រទេសកម្ពុជា និងជាសហប្រធានគណៈកម្មាធិការចម្រុះ JCM និងសហការី
- បានចូលរួមកិច្ចប្រជុំពិនិត្យផែនការការងារក្នុងការរៀបចំ leaflets និង factsheet និងរៀបចំផែនការចុះតាមរោងចក្រ និងសហគ្រាសដែល បានជ្រើសរើសតាមរយៈអង្គការ UNIDO ដើម្បីពិនិត្យស្ថានភាពជាក់ស្តែង ការប្រើប្រាស់បច្ចេកវិទ្យាដែលបាននិងកំពុងដំណើរការនៅទីស្តីការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានចូលរួមសម្របសម្រួលក្នុងកិច្ចប្រជុំជាមួយក្រុមការងារបច្ចេកទេសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីគ្រោងការពន្ធដែលស្នើឡើងសម្រាប់កាបូននៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឡើងវិញនៅក្នុងប្រទេសកម្ពុជា
- បានចូលរួមសម្របសម្រួលក្នុងកិច្ចប្រជុំជាមួយមន្ត្រីកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជាស្តីពីការរៀបចំវគ្គបណ្តុះបណ្តាលសារពើភ័ណ្ឌកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដល់មន្ត្រីក្រសួងរ៉ែ និងថាមពល
- បានចូលរួមសម្របសម្រួលក្នុងក្នុងកិច្ចប្រជុំជាមួយគម្រោងការបញ្ជ្រាបភាពធន់នឹងអាកាសធាតុ ទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ ដើម្បីពិភាក្សាអំពីការងារដែលត្រូវបន្តអនុវត្តក្នុងរយៈពេល១៨ខែ និងចូលរួមជាអ្នកសម្របសម្រួលគម្រោងដែលតំណាងនាយកដ្ឋានប្រែប្រួលអាកាសធាតុ ដើម្បីពិនិត្យមើល ឯកសារគោលការណ៍ណែនាំបញ្ជ្រាប ភាពធន់នឹងអាកាសធាតុទៅនឹងការប្រែប្រួលអាកាសធាតុ
- បានចូលរួមសម្របសម្រួលក្នុងប្រជុំ ដើម្បីផ្តល់យោបល់លើគោលការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានស្តីពីឧស្សាហកម្មធុនធ្ងន់ និងតំបន់សេដ្ឋកិច្ចពិសេស បានពិនិត្យ និងផ្តល់យោបល់ជាធាតុចូលសម្រាប់កែលម្អជំពូក និងចំណុចនីមួយៗ យ៉ាងច្បាស់លាស់ពាក់ព័ន្ធនិងការប្រែប្រួលអាកាសធាតុជាមូលដ្ឋាន និងដាក់ជូនអគ្គលេខាធិការដ្ឋាន
- បានចូលរួមសម្របសម្រួលក្នុងកិច្ចពិភាក្សាអំពីការផ្តល់វគ្គបណ្តុះបណ្តាលស្តីពីការធ្វើសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ក្នុងវិស័យថាមពលដល់សិក្ខាកាមនៃក្រសួងរ៉ែ និងថាមពល នៅបន្ទប់ប្រជុំCCCA
- បានចូលរួមសម្របសម្រួលក្នុងកិច្ចប្រជុំស្តីពី ការបញ្ចូលទិន្នន័យឧស្ម័នផ្ទះកញ្ចក់ទៅក្នុងគេហទំព័រនាយកដ្ឋានប្រែប្រួលអាកាសធាតុ
- បានចូលរួមកិច្ចពិភាក្សាលើឯកសារសម្រាប់ការអនុវត្តការគណនាឧស្ម័នផ្ទះកញ្ចក់ក្នុងវិស័យថាមពលដល់សិក្ខាកាមនៃក្រសួងរ៉ែ និងថាមពល
- បានចូលរួមសម្របសម្រួល និងជាវាគ្មិនកិត្តិយសក្នុងសន្និសីទសារព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់មកលើប្រទេសកម្ពុជា បានដឹកនាំប្រតិភូក្រសួងបរិស្ថានដោយ **ឯកឧត្តម នេត្រ ភក្ត្រា** រដ្ឋលេខាធិការក្រសួងបរិស្ថាននៅទីស្តីការគណៈរដ្ឋមន្ត្រី

ទំព័រ ១៥



*រូបភាពទី 11 ៖ វាគ្មិនក្រសួងបរិស្ថានធ្វើសន្និសីទសារព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុ*

- បានចូលរួមសម្របសម្រួល និងធ្វើបទបង្ហាញសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការកែសម្រួលប្រព័ន្ធទិន្នន័យហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា និងការកត់ត្រាហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ ដែលរៀបចំដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CRDB/CDC) នៅខេត្តកែប
- បានចូលរួមសម្របសម្រួល និងធ្វើបទបង្ហាញចែករំលែកចំណេះដឹងក្នុងកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិស្តីពីការរៀបចំគម្រោងឆ្លងដែននៃគណៈកម្មការជាតិទន្លេមេគង្គ នៅខេត្តកំពង់ធំ
- បានចូលរួមសិក្ខាសាលាបញ្ចប់គម្រោង ស្តីពីការបញ្ជ្រាបភាពធន់នឹងការប្រែប្រួលអាកាសធាតុក្នុងផែនការអភិវឌ្ឍន៍កញ្ចប់ការបញ្ជ្រាបយេនឌ័រក្នុងការវិនិយោគបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងសិក្ខាសាលាផ្សព្វផ្សាយសៀវភៅផែនការមេរបស់គម្រោង «ស្តីពីការបញ្ជ្រាបយេនឌ័រក្នុងការវិនិយោគបន្សាំនឹងការប្រែប្រួលអាកាសធាតុ»
- បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយស្តីពី លទ្ធផលនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅសមុទ្រអាស៊ីបូព៌ា (SDS-SEA)។ សិក្ខាសាលានេះមានគោលបំណង បង្ហាញពីលទ្ធផល និងចែករំលែកបទពិសោធន៍នៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅតំបន់សមុទ្រអាស៊ីបូព៌ាឆ្នាំ២០១៧-២០២០ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលឆ្លើយតបនឹងយន្តការស្ថាប័ន ការគ្រប់គ្រងបរិស្ថានការកាត់បន្ថយការបំពុលបរិស្ថានការ គ្រប់គ្រងសំណល់លំនៅឋាននិងសំណល់ សមុទ្រ
- បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ ស្តីពី "សេចក្តីព្រាងក្របខណ្ឌការងារជាតិស្តីពីការប្រើប្រាស់ និងការបែងចែកផលប្រយោជន៍ពីការប្រើប្រាស់ធនធានពន្ធុដោយស្មើរភាពនិងសមធម៌ (ABS)" មានគោលបំណង ដើម្បីពិនិត្យ ពិភាក្សា និងផ្តល់ធាតុចូលលើសេចក្តីព្រាងក្របខ័ណ្ឌការងារជាតិស្តីពី ABS
- បានចូលរួមកិច្ចប្រជុំជាមួយតំណាងអង្គការ IUCN នៅទីស្តីការក្រសួងបរិស្ថាន ដើម្បីភាក្សាទៅលើ៖ ១) ការសិក្សាដែលពិនិត្យលើគោលនយោបាយនិងស្ថានប័នគ្រប់គ្រងតំបន់ឆ្នេរសមុទ្រកម្ពុជាតាមបែបសមាហរណកម្ម ដើម្បីកំណត់កាលានុវត្តន៍ភាពក្នុងគោលបំណងអភិវឌ្ឍន៍ដោយនិរន្តរភាព២) ពង្រឹងកិច្ចសហការជាយុទ្ធសាស្ត្ររវាងអគ្គលេខាធិការដ្ឋាន និងអង្គការ IUCN ដែល

ឆ្លើយតបនឹងយុទ្ធសាស្ត្រ និងផែនការអាទិភាព របស់អគ្គលេខាធិការដ្ឋាន និងក្រសួងបរិស្ថាន

- បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ដំណើរការរៀបចំសំណើសុំមូលនិធិសម្រាប់អនុវត្តគម្រោងពីមូលនិធិអាកាសធាតុបៃតង នៅរាជធានីភ្នំពេញ
- បានចូលរួមកិច្ចពិភាក្សាទៅលើការសិក្សាផលប៉ះពាល់នៃភាពតានតឹងកម្រិតកម្តៅចំពោះផលិតភាពមនុស្ស និងសេដ្ឋកិច្ចនៅកម្ពុជា
- បានចូលរួមប្រជុំស្តីពី ការវាយតម្លៃសេដ្ឋកិច្ចលើការប្រើប្រាស់ដីនៅកម្ពុជា នៅរាជធានីភ្នំពេញ
- បានចូលរួមក្នុងកិច្ចប្រជុំស្តីពីយុទ្ធសាស្ត្រ និងផែនការសកម្មភាពនៃសេដ្ឋកិច្ចចក្រា នៅទីស្តីការក្រសួងបរិស្ថាន
- បានចូលរួមក្នុងកិច្ចប្រជុំលើកទី២ នៃក្រុមការងារបច្ចេកទេសស្តីពីការប្រើប្រាស់និងផលិតកម្មដោយនិរន្តរភាព និងសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការរៀបចំយុទ្ធសាស្ត្រ និងផែនការសកម្មភាពនៃសេដ្ឋកិច្ចចក្រានៅខេត្តសៀមរាប
- បានចូលរួមសិក្ខាសាលាថ្នាក់ជាតិនៃគម្រោងស្តីពីការលើកកម្ពស់និរន្តរភាពនៃការគ្រប់គ្រងទឹកក្រោមដីឆ្លងដែនរវាងតំបន់ទំនាបទន្លេមេគង្គនៃប្រទេសកម្ពុជា និងដែនដីសណ្តនៃតំបន់មេគង្គវៀតណាម រាជធានីភ្នំពេញ និង

### ក. រៀបចំរបាយការណ៍បច្ចុប្បន្នភាពពីរឆ្នាំម្តង

- បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិលើសេចក្តីព្រាងចុងក្រោយនៃរបាយការណ៍បច្ចុប្បន្នភាពពីរឆ្នាំម្តង ជាលទ្ធផលសម្រេចបាន ក្រុមការងារជំនាញបានបញ្ចប់ការរៀបចំរបាយការណ៍បច្ចុប្បន្នភាពពីរឆ្នាំម្តងដោយមានការអនុម័តពីឯកឧត្តមប្រធាន ក.ជ.អ.ច. និងជារដ្ឋមន្ត្រីក្រសួងបរិស្ថាន និងបានដាក់ជូនលេខាធិការដ្ឋានអនុសញ្ញា UNFCCC និងរៀបចំធ្វើការបោះពុម្ពផ្សព្វ ផ្សាយដល់អ្នកពាក់ព័ន្ធ
- ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពក្រសួងបរិស្ថានបានអនុម័តឯកសាររបាយការណ៍ BUR ជាផ្លូវការនៅខែឧសភា ឆ្នាំ២០២០ និងបានដាក់ជូនរបាយការណ៍នេះទៅលេខាធិការដ្ឋាន UNFCCC កាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ ប្រកបដោយជោគជ័យ
- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយឯកសាររបាយការណ៍បច្ចុប្បន្នភាពពីរឆ្នាំម្តងលើកទី១របស់កម្ពុជាក្រោមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុក្រោមអធិបតីភាព **ឯកឧត្តម ទិន ពន្លក** អនុប្រធានទី២ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងជារដ្ឋលេខាធិការក្រសួងបរិស្ថានតំណាង **ឯកឧត្តម សាយ សំអាល់** ប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងជារដ្ឋមន្ត្រីក្រសួងបរិស្ថាដោយមានការចូលរួម **ឯកឧត្តម ជា សំអាង** រដ្ឋលេខាធិការ ក្រសួងបរិស្ថាន **ឯកឧត្តម ហ៊ាន វណ្ណហ៊ាន** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងជាអនុប្រធានទី១នៃគណៈកម្មាធិការប្រតិបត្តិនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព **ឯកឧត្តម ឈឹម កាន** អភិបាលរងខេត្ត មណ្ឌលគិរី **ឯកឧត្តម ប៊ុន ណារិទ្ធិ** រដ្ឋលេខាធិការ ក្រសួងរ៉ែ និងថាមពល **ឯកឧត្តម វ័ន្ត វីរៈ** និង**លោកជំទាវ ចាន់ សុម៉ាលី** អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន និងមានការចូលរួមពីសមាជិកក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព តំណាងក្រសួងបរិស្ថានសមាជិកក្រុមការងារបច្ចេកទេសប្រែប្រួលអាកាសធាតុ តំណាងសាកលវិទ្យាល័យ មន្ទីរពាក់ព័ន្ធនានាខេត្តមណ្ឌលគិរី តំណាងកម្មវិធីអភិវឌ្ឍន៍សហ

ប្រជាជាតិ តំណាងលេខាធិការដ្ឋានរេដបូក វិស័យឯកជនសរុបចំនួនប្រមាណ៧០នាក់។



*រូបភាពទី 12 ៖ សិក្ខាសាលាផ្សព្វផ្សាយឯកសាររបាយការណ៍បច្ចុប្បន្នភាពពីរឆ្នាំម្តងលើកទី១របស់កម្ពុជា*

## ខ. របាយការណ៍ជាតិលើកទី៣ស្តីពីការប្រែប្រួលអាកាសធាតុ

- បានសម្របសម្រួលពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងរបាយការណ៍ជាតិលើកទី៣ ទាក់ទងនឹងផ្នែកសារពើភណ្ឌ និងកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់
- បានសម្របសម្រួលពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍បច្ចេកទេសផ្នែកការវាយតម្លៃភាពងាយរងគ្រោះ និងបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុក្នុងរបាយការណ៍ជាតិលើកទី៣ទៅកាន់លេខាធិការដ្ឋានអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ និងស្នើសុំឱ្យធ្វើការពិនិត្យលម្អិតតាមយោបល់ និងអនុសាសន៍របស់មន្ត្រីជំនាញលើរបាយការណ៍បច្ចេកទេសអំពីការវាយតម្លៃភាពងាយរងគ្រោះ និងបន្សុាំតាមវិស័យអាទិភាពជាក់លាក់ ដូចជា វិស័យកសិកម្ម ធនធានទឹក ប្រព័ន្ធអេកូស៊ីព្រៃឈើ សុខភាពមនុស្ស និងតំបន់ឆ្នេរ។

## គ. រៀបចំផែនការស្តីពីការចូលរួមចំណែករបស់ជាតិដើម្បីអនុវត្តអនុសញ្ញា UNFCCC

- បានធ្វើបច្ចុប្បន្នភាពនៃដំណើរការរៀបចំឯកសារស្តីពីការចូលរួមចំណែករបស់ជាតិដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុដល់ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ចំនួន១៥ ក្នុងការផ្តល់ជាតុចូលនៃផែនការសកម្មភាពអាទិភាពតាមវិស័យរបស់ខ្លួនលើផ្នែកបន្សុាំ ការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ ហិរញ្ញវត្ថុ អភិបាលកិច្ច និងតម្លាភាពពីឆ្នាំ២០២០ ដល់២០៣០ ដែលបានផ្ញើរបាយការណ៍តាមវិស័យមកក្រុមការងារ ដើម្បីរៀបចំចងក្រងរបាយការណ៍ពេញលេញដាក់ជូនលេខាធិការដ្ឋានអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ដោយបានផ្ញើរបាយការណ៍មកក្រុមការងារ ដើម្បីពិនិត្យ ពិភាក្សា និងចងក្រងសម្រាប់ធ្វើការពិគ្រោះយោបល់ពីអ្នកពាក់ព័ន្ធទាំងអស់
- បានរៀបចំក្នុងការផ្តល់សុពលភាពលើរបាយការណ៍ការចូលរួមចំណែករបស់ជាតិ ដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ពីក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ចំនួន១៦ ក្នុងការផ្តល់ជាតុចូលនៃផែនការសកម្មភាពអាទិភាពតាមវិស័យរបស់ខ្លួនលើផ្នែកបន្សុាំ ការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ហិរញ្ញវត្ថុ អភិបាលកិច្ច និងតម្លាភាព ពីឆ្នាំ២០២០ ដល់២០៣០ ក្នុងការពិនិត្យ ផ្ទៀងផ្ទាត់ចុងក្រោយមុនដាក់ជូនលេខាធិការដ្ឋានអនុសញ្ញា UNFCCC។
- បានសម្រេចលើសេចក្តីព្រាងខិត្តប័ណ្ណព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុដែលនឹងផ្សព្វផ្សាយតាមបណ្តាញសង្គមនិងគេហទំព័រក.ជ.អ.ច. ព្រមទាំងបោះពុម្ពផ្សាយ។

ទំព័រ ១៨

- ក្រុមការងារតំណាងនាយកដ្ឋានប្រែប្រួលអាកាសធាតុ បានចូលរួមការងារជាមួយកម្មវិធីវ៉េដបូក។
- បានបង្ហាញពីរបៀបកែលំអគេហទំព័រ និងការទទួលខុសត្រូវនិងសហការការងាររវាងមន្ត្រីរបស់នាយកដ្ឋាន និងមន្ត្រីកម្មវិធីCCCA3។

## អនុកម្មវិធីពាះអភិរក្សជីវៈចម្រុះ និងជីវសុវត្ថិភាព

### ចង្កោមសកម្មភាពទី១: សេវាគាំទ្រ កិច្ចសហប្រតិបត្តិការអន្តរជាតិ-អាស៊ាន និងការសិក្សាស្រាវជ្រាវពាក់ព័ន្ធនឹងជីវៈចម្រុះ និងជីវសុវត្ថិភាព

- បានចុះពិនិត្យសួនគ្រឿងទេសដែលអាជ្ញាធរជាតិអប្សរាបានសម្រេចប្រគល់ឱ្យអគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. ដើម្បីរៀបចំស្តារថែទាំ និងដាក់ឱ្យដំណើរការឡើងវិញនៅខេត្តសៀមរាប និងបានចុះពិនិត្យវឌ្ឍនភាពមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិរក្សកេសរកូល សុខ អាន ភ្នំគូលែន និងដំណើរការកសាងសួនបង្កាត់ពូជកេសរកូល សួនមេអំបៅការរៀបចំប្រព័ន្ធស្រោចស្រពថ្នាលបណ្តុះកូនកេសរកូល កែសម្រួល និងថែទាំហេដ្ឋារចនាសម្ព័ន្ធ នៅក្នុងសួនកេសរកូលព្រៃ ពិនិត្យដំណើរការផ្លាស់ប្តូរទីស្នាក់ការឧទ្យានុរក្ស កសាងហាងកាហ្វេ និងចំណតរថយន្ត ជាដើម
- បានសម្របសម្រួលក្រុមអ្នកជំនាញពីសារមន្ទីរប្រវត្តិសាស្ត្រធម្មជាតិទីក្រុងប៉ារីស នៃប្រទេសបារាំងមកធ្វើទស្សនកិច្ចនៅមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិរក្សកេសរកូល សុខ អាន ភ្នំគូលែន ខេត្តសៀមរាប។ លទ្ធផលនៃទស្សនកិច្ច ក្រុមអ្នកជំនាញការបច្ចេកទេសបានផ្តល់អនុសាសន៍លើការចងក្រងទិន្នន័យ និងលេខកូដសម្គាល់ក្នុងសួនកេសរកូលព្រៃ និងថ្នាលបណ្តុះកូនរុក្ខជាតិ វិធីសាស្ត្រនៃការប្រមូលសំណាករស់ វិធីសាស្ត្រនៃការដាំ ការបែងចែក និងកំណត់ត្រាទិន្នន័យសំខាន់ៗ នាពេលអនាគត



រូបភាពទី 13 ៖ ពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់ស្តីពីកិច្ចសហប្រតិបត្តិការរវាងក.ជ.អ.ច. និងសារមន្ទីរប្រវត្តិសាស្ត្រធម្មជាតិទីក្រុងប៉ារីស

- បានពិភាក្សាជាមួយសាកលវិទ្យាធិការនៃសាកលវិទ្យាល័យខេត្តបាត់ដំបង ដើម្បីពិភាក្សានិងស្វែងយល់ពីវិធីបណ្តុះកូនរុក្ខជាតិ និងកូនកេសរកូលក្នុងមន្ទីរពិសោធន៍ដំណាំ នៃសាកលវិទ្យាល័យបាត់ដំបង
- បានចាត់មន្ត្រីចំនួន៣រូប ចុះពិនិត្យវឌ្ឍនភាពនៃការសាងសង់មជ្ឈមណ្ឌលសិក្សាស្រាវជ្រាវ និងអភិរក្សកេសរកូល សុខ អាន ភ្នំគូលែន (ព្រំប្រទល់មជ្ឈមណ្ឌល ទីតាំងប្រភពទឹកសំខាន់ៗ ដើម្បីរៀបចំប្រព័ន្ធស្រោចស្រព ការសាងសង់សួនបង្កាត់ពូជកេសរកូល និងសួនមេអំបៅ ចំណតរថយន្ត និងហាងកាហ្វេ)
- បាននាំយកកេសរកូលចំនួន ៦ប្រភេទ ពីសួនកេសរកូលព្រៃដើម្បីបណ្តុះសាកល្បង នៅបន្ទប់ពិសោធន៍ជាលិការុក្ខវប្បកម្មរុក្ខជាតិ នៅវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃ
- ទទួលបានការឯកភាពពីឯកឧត្តមប្រធាន ក.ជ.អ.ច. និងជារដ្ឋមន្ត្រីក្រសួងបរិស្ថាន លើសំណើសុំអនុញ្ញាតជាគោលការណ៍ ដើម្បីជួលហាងកាហ្វេរបស់មជ្ឈមណ្ឌលកេសរកូល សុខ អាន ភ្នំគូលែន

ទំព័រ ១៩

ជូនក្រុមហ៊ុន Cambodia Amazing Trip Planner Co.,ltd.

- បានទទួលថវិកាពីកញ្ចប់មូលនិធិបរិស្ថាន និងសង្គម ដើម្បីសិក្សាប្លង់មេរបស់មជ្ឈមណ្ឌលស្រាវជ្រាវ និងអភិរក្សកេសរកូល សុខ អាន ភ្នំគូលែន



រូបភាពទី 14 ៖ ការណែនាំពីប្រភេទផ្កាអូគីដេ

- បានចាត់មន្ត្រីចំនួន២រូបចូលរួមក្នុង "យុទ្ធនាការកូនឈើនៅក្នុងមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិរក្សកេសរកូល សុខ អាន ភ្នំគូលែន" នៅខេត្តសៀមរាប
- បានចាត់បុគ្គលិកស្ម័គ្រចិត្ត ១រូប ឱ្យចូលរួមសិក្សាបច្ចេកទេសពិសោធន៍កោសិកា និងជាលិការបស់រុក្ខជាតិ នៅវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង៤ រូបទៀតមកសិក្សាស្វែងយល់ និងរៀនសូត្របទពិសោធន៍ការងារនៅនាយកដ្ឋានផងដែរ។
- បានចូលរួមសម្របសម្រួលដំណើរទស្សនកិច្ចរបស់ក្រុមការងាររបស់អង្គការ UNDP ដើម្បីពិនិត្យវឌ្ឍនភាពនៃការរៀបចំមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិរក្សកេសរកូល សុខ អាន ភ្នំគូលែន និងស្ថានភាពជីវភាពការប្រើប្រាស់ដីនិងទឹករបស់សហគមន៍តំបន់ការពារធម្មជាតិ(CPA)ទាំង៥នៅលើខ្នងភ្នំគូលែន ដើម្បីរៀបចំផែនការអនុវត្តការសម្រាប់ការបង់ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី
- បានចូលរួមសន្និបាតរដ្ឋភាគីលើកទី១៣ (COP13) នៃអនុសញ្ញាស្តីពី ការអភិរក្សប្រភេទសត្វសន្តរប្រវេសន៍(CMS) ២០២០ នៅទីក្រុង Gandhinagar ប្រទេសឥណ្ឌា ។
- បានចូលរួមសិក្ខាសាលាប្រមូលទិន្នន័យរៀបចំគម្រោងជីវសុវត្ថិភាពក្រោយឆ្នាំ២០២០ និងវគ្គបណ្តុះបណ្តាលស្តីពីការប្រើប្រាស់យន្តការសម្របសម្រួល និងបែងចែកព័ត៌មានជីវសុវត្ថិភាព (BCH) ថ្នាក់តំបន់ នៅទីក្រុងញ៉ូវដេលី ប្រទេសឥណ្ឌា។
- បានទទួលចំណារឯកភាពពីឯកឧត្តមរដ្ឋមន្ត្រីលើសំណើអញ្ជើញកម្ពុជាចូលជាសមាជិកនៃគណៈកម្មាធិការដឹកនាំថ្នាក់តំបន់អាស៊ីខាងត្បូងសម្រាប់ការអភិរក្សសត្វត្មាត (The South Asia Regional Streering Committee for Vulture Conservation)
- បានចូលរួមកិច្ចប្រជុំក្រុមការងារបច្ចេកទេសលើកទី២ស្តីពីក្របខណ្ឌការងារជីវៈចម្រុះសកលក្រោយឆ្នាំ២០២០ (OEWG-2) នៅទីក្រុងរ៉ូម ប្រទេសអ៊ីតាលី
- ចូលរួមកិច្ចប្រជុំតាមប្រព័ន្ធ Online ស្តីពី "Extraordinary Meeting of the Governing Board on the Comprehensive Institutional Review of the ASEAN Centre for Biodiversity" ជាលទ្ធផលកិច្ចប្រជុំបានពិភាក្សាផ្តល់យោបល់លើការវាយតម្លៃតួនាទី និងរចនាសម្ព័ន្ធរបស់ ACB ប្រសិទ្ធិភាពនៃការអនុវត្តរបស់ស្ថាប័ន ការកំណត់តំរូវការហិរញ្ញវត្ថុ ការកៀរគរថវិកាការកែសម្រួលរចនាសម្ព័ន្ធស្ថាប័ន សំណើកែសម្រួលកិច្ចព្រមព្រៀងបង្កើត ACB ឆ្នាំ២០០៥

និងសេចក្តីព្រាងអនុសាសន៍ដែលស្នើដោយទីប្រឹក្សាអន្តរជាតិ។នៅទីបញ្ចប់កិច្ចប្រជុំ សមាជិកបានឯកភាពគ្នាឱ្យទីប្រឹក្សាកែសម្រួលសេចក្តីព្រាងរបាយការណ៍ផ្អែកទៅលើធាតុចូលដែលបានផ្តល់ក្នុងកិច្ចប្រជុំ ជាពិសេសសេចក្តីព្រាងអនុសាសន៍ដើម្បីដាក់ជូន ACB Governing Board ពិនិត្យ និងសម្រេច។

- បានរៀបចំបញ្ចប់សេចក្តីព្រាងស្តីពីសៀវភៅមគ្គុទេសន៍គ្រឿងទេសនៅកម្ពុជា
- បានធ្វើការផ្លាស់ប្តូរ Domain របស់គេហទំព័រ CHMមកក្រោមក្រសួងបរិស្ថានដែលមានអាសយដ្ឋាន http://chm-ncsd.moe.gov.kh/ និងធ្វើបច្ចុប្បន្នភាពទិន្នន័យជីវៈចម្រុះក្នុងគេហទំព័រ

## ចង្កោមសកម្មភាពទី២៖ការរៀបចំយុទ្ធសាស្ត្រ ក្របខណ្ឌការងារ និងគោលនយោបាយស្តីពីជីវៈចម្រុះ ជីវសុវត្ថិភាព ប្រព័ន្ធអេកូឡូស៊ី និងអនុវត្តអនុសញ្ញាពិធីសារ និងកិច្ចព្រមព្រៀងពាក់ព័ន្ធ

- បានរៀបចំវេទិកាកេសរកូលលើកទី១នៅកម្ពុជា និងពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់ស្តីពីកិច្ចសហប្រតិបត្តិការរវាងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពនៃក្រសួងបរិស្ថាន ជាមួយសារមន្ទីរប្រវត្តិសាស្ត្រធម្មជាតិទីក្រុងប៉ារីស ដោយមានការអញ្ជើញចូលរួមពីតំណាងក្រសួងស្ថាប័ន ស្ថានទូត អង្គការដៃគូវិស័យឯកជន អ្នកជំនាញជាតិ និងអន្តរជាតិ សាធារណជន សិស្ស និស្សិត និងអ្នកពាក់ព័ន្ធ ប្រមាណ ៥០០រូប ក្នុងនោះមានស្ត្រីចំនួន ២២១រូប



រូបភាពទី 15 ៖ វេទិកាកេសរកូលលើកទី១នៅកម្ពុជា

- **ឯកឧត្តម សាយ សំអាល់** ប្រធាន ក.ជ.អ.ច. និងជារដ្ឋមន្ត្រីក្រសួងបរិស្ថាន បានដឹកនាំថ្នាក់ដឹកនាំក្រសួងបរិស្ថាននិងអគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. ជួបប្រជុំជាមួយលោក**ជំទាវ អានី សុខអាន** ដើម្បីពិភាក្សាពីដំណើរការរៀបចំមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិរក្សកេសរកូល សុខ អាន ភ្នំគូលែន
- បានរៀបចំសិក្ខាសាលាស្តីពីបច្ចេកទេសនៃការប្រមូលដឹកជញ្ជូន និងការរក្សាសំណាករុក្ខជាតិរស់ ដល់មន្ត្រីឧទ្យាននុរក្ស និងប្រជាសហគមន៍ក្នុងឧទ្យានជាតិក្រវាញកណ្តាល ខេត្តកោះកុង ដែលមានអ្នកចូលរួមចំនួនដែលមានសិក្ខាកាមចូលរួមសរុបចំនួន៥០រូប
- បានរៀបចំកិច្ចប្រជុំចំនួន៥លើកសម្រាប់ក្រុមការងារបច្ចេកទេសពិគ្រោះយោបល់លើការរៀបចំប្លង់ និងផែនការមេនៅក្នុងមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិរក្សកេសរកូល សុខ អាន ភ្នំគូលែន និងកិច្ចប្រជុំជាមួយលោក ស្រ៊ាន ពៅ ព្រឹទ្ធបុរសមហាវិទ្យាល័យកសិកម្ម និងកែច្នៃអាហារ នៃសាកលវិទ្យាល័យបាត់ដំបង ដើម្បីស្វែងរកកិច្ចសហការអភិរក្ស និងបង្កាត់ពូជកេសរកូល ក្នុងការផ្តល់ជំនួយបច្ចេកទេស និងទីតាំងសម្រាប់ធ្វើ

ការបង្កាត់ពូជកេសរកូលរបស់មជ្ឈមណ្ឌលស្រាវជ្រាវ និងអភិរក្សកេសរកូល សុខ អាន ភ្នំគូលែន។

- បានរៀបចំកិច្ចប្រជុំស្តីពីការប្រមូលទិន្នន័យពាក់ព័ន្ធនឹងស្ថានភាពជីវៈចម្រុះ នៅតំបន់ការពារធម្មជាតិក្នុងខេត្តមណ្ឌលគិរី ដែលមានសមាជិកចូលរួមសរុបចំនួន ៣០រូប (ស្ត្រី៥រូប) ។ជាលទ្ធផលកិច្ចប្រជុំ បានពិភាក្សា និងចែករំលែកមេរៀនជាបទពិសោធន៍ទាក់ទងនឹងការបង្ក្រាបការជួញដូរសត្វ និងរុក្ខជាតិព្រៃ ដែលមន្ទីរបរិស្ថានខេត្តមានក្រុមការងារចល័តបាន និងកំពុងអនុវត្តសកម្មភាពក្នុងខេត្ត។ ទាក់ទងនឹងការដោះស្រាយវិវាទដីធ្លី សាលាខេត្តមណ្ឌលគិរីមានគណៈកម្មការដែលកំពុងទទួលខុសត្រូវលើការដោះស្រាយ និងផ្សព្វផ្សាយពីបញ្ហានេះ។ ដោយឡែកចំពោះព័ត៌មានទាក់ទងនឹងជីវៈចម្រុះនៅក្នុងដែនជម្រកទាំង៥ មានដែនជម្រកចំនួន៤ មានទិន្នន័យលើកលែងតែដែនជម្រកភ្នំណាមលៀរនៅមិនទាន់មានអ្នកទៅសិក្សាស្រាវជ្រាវនៅឡើយទេ ដោយសារខ្វះថវិកាឧបត្ថម្ភ
- បានសម្របសម្រួលរៀបចំកិច្ចប្រជុំ ស្តីពីការបង់ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ីនៅតំបន់ប្រើប្រាស់ច្រើនយ៉ាងព្រែកទឹកសាបក្បាលឆាយ និងឧទ្យានជាតិព្រះជ័យវរ្ម័ននរោត្តម ភ្នំគូលែន ដោយមានការចូលរួមពីថ្នាក់ដឹកនាំក្រសួងបរិស្ថាន តំណាងអគ្គនាយកដ្ឋាន និងនាយកដ្ឋានពាក់ព័ន្ធសរុបចំនួន ៣៤រូប។ ជាលទ្ធផលកិច្ចប្រជុំនេះ បានទទួលការគាំទ្រពីសមាជិកទាំងអស់ និងព្រមទាំងជំរុញឱ្យដំណើរការរៀបចំអនុវត្តគម្រោងសាកល្បង PES នៅតំបន់ទាំងពីរឱ្យបានឆាប់។
- បានរៀបចំជំនួបជាមួយមន្ត្រីពិសោធន៍ចំនួន ២ លើក ដើម្បីពិភាក្សានិងស្វែងរកវិធីដោះស្រាយសម្រាប់ដំណើរការការិយាល័យជីវសុវត្ថិភាព។ ជាលទ្ធផលនៃកិច្ចប្រជុំខាងមន្ទីរពិសោធន៍ នឹងសិក្សាពីតម្លៃជួសជុល និងតម្លៃទិញថ្មីនៃបញ្ជីឧបករណ៍និងសម្ភារមួយទាំងតម្លៃនៃការបណ្តុះបណ្តាលក្នុងប្រើប្រាស់ឧបករណ៍ និងសម្ភារមន្ទីរពិសោធន៍ផ្នែកជីវសុវត្ថិភាព និងផ្ញើជូននាយកដ្ឋានជីវៈចម្រុះជាព័ត៌មានសម្រាប់ត្រៀមរៀបចំដំណើរការមន្ទីរពិសោធន៍ និងបន្តការងារពាក់ព័ន្ធនឹងជីវសុវត្ថិភាពឡើងវិញ
- បានរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសជីវៈចម្រុះ និង អនុក្រុមការងារបច្ចេកទេសជីវសុវត្ថិភាព ដោយមានអ្នកចូលរួមពីសមាជិកសរុបចំនួន ៤៣ រូប។ ជាលទ្ធផលកិច្ចប្រជុំបានពិនិត្យសម្រេច និងឯកភាពលើ៖ (១)របាយការណ៍កំណត់វិសាលភាពនៃការវាយតម្លៃប្រព័ន្ធអេកូឡូស៊ីថ្នាក់ជាតិ (២)ផែនទីបង្ហាញផ្លូវសម្រាប់ការងារជីវសុវត្ថិភាព និង(៣)កិច្ចសហការ និងជំហានបន្ទាប់ដើម្បីជំរុញប្រសិទ្ធភាពនៃការអនុវត្តការងារជីវៈចម្រុះ និងជីវសុវត្ថិភាព ។
- បានរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសលើកទី២ សម្រាប់ពិភាក្សា និងផ្តល់អនុសាសន៍ លើបញ្ហាប្រឈមនានាក្នុងការគ្រប់គ្រងធនធានធម្មជាតិ និងអភិរក្សជីវៈចម្រុះ ដែលមានសមាជិកចូលរួមចំនួន ៤០រូប
- បានរៀបចំសិក្ខាសាលាស្តីពី ការត្រួតពិនិត្យស្ថាប័ន និងគោលនយោបាយនិងគោលនយោបាយ ហិរញ្ញវត្ថុជីវៈចម្រុះ ការត្រួតពិនិត្យការចំណាយលើផ្នែកជីវៈចម្រុះ និងការវាយតម្លៃតម្រូវការ ហិរញ្ញវត្ថុ ដោយមានការចូលរួមពីថ្នាក់ដឹកនាំ អ.ក.អ.ច. ក្រសួងបរិស្ថាន តំណាងក្រសួង ស្ថាប័ន អង្គការ និងអ្នកពាក់ព័ន្ធចំនួនប្រមាណ ៥០រូប

- បានរៀបចំកិច្ចប្រជុំស្តីពី ការអភិរក្សជីវៈចម្រុះ នៅក្នុងតំបន់ដែលស្ថិតនៅក្រៅយុត្តាធិការថ្នាក់ជាតិ ក្រោមអធិបតីភាព **ឯកឧត្តម សាយ សំអាល់** ប្រធាន ក.ជ.អ.ច. និងជារដ្ឋមន្ត្រីក្រសួងបរិស្ថាន ដែលមានចូលរួមពីថ្នាក់ដឹកនាំក្រសួងបរិស្ថាន ដែលជាជនបង្គោលនៃអនុសញ្ញាពាក់ព័ន្ធ និងតំណាងថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអ្នកពាក់ព័ន្ធសរុបចំនួន២៥នាក់។ អង្គប្រជុំនេះ បានពិភាក្សាស្វែងរកជំហររួមសម្រាប់ប្រទេសកម្ពុជាលើការបង្កើតតំបន់ការពារធម្មជាតិសមុទ្រ ក្នុងតំបន់ដែលស្ថិតនៅក្រៅយុត្តាធិការរបស់ប្រទេសណាមួយ (Areas Beyond National Jurisdiction – ABNJ) ដោយផ្អែកលើកត្តាបរិស្ថាន សន្តិសុខ សមត្ថកិច្ច សេដ្ឋកិច្ច និងផ្លូវច្បាប់ ដើម្បីត្រៀមដាក់ជូន**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ពិនិត្យ និងសម្រេចដ៏ខ្ពង់ខ្ពស់មុនដាក់ជូនកិច្ចប្រជុំកំពូលលើកទី ១៥ (COP-15) នៃបណ្តាប្រទេសជាសមាជិករបស់អនុសញ្ញាសហប្រជាជាតិសហប្រជាជាតិស្តីពីជីវៈចម្រុះនៅសាធារណរដ្ឋប្រជាមានិតចិននាដំណាច់ឆ្នាំ២០២០។
- បានរៀបចំសិក្ខាសាលា ស្តីពីសេចក្តីព្រាងក្របខណ្ឌការងារជាតិស្តីពីការប្រើប្រាស់ និងការបែងចែកផលប្រយោជន៍ពីការប្រើប្រាស់ធនធានពន្ធុដោយស្មើភាព និងសមធម៌(ABS)មានការចូលរួមពីតំណាងមកពីបណ្តា ក្រសួងស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អង្គការដៃគូ និងសហគមន៍មូលដ្ឋានប្រមាណជាង៧០រូប ។ ក្នុងគោលបំណងដើម្បីពិនិត្យពិភាក្សា និងផ្តល់ធាតុចូលលើសេចក្តីព្រាងក្របខណ្ឌការងារជាតិស្តីពី ABS ពិសេសគោលបំណងជាយុទ្ធសាស្ត្រទាំង៣ រួមមាន ការកសាងសមត្ថភាពចំណេះដឹង និងទំនាក់ទំនង (ABS-CEPA) ការរៀបចំបង្កើត និងអនុវត្តគោលនយោបាយ នីតិវិធី និងវិធានរដ្ឋបាលស្តីពី ABS និងកម្មវិធីការងារដើម្បីគាំទ្រដល់ការអនុវត្តការងារពាក់ព័ន្ធនឹង ABS
- បានរៀបចំកិច្ចប្រជុំលើកទី១នៃអនុក្រុមការងារបច្ចេកទេសអន្តរក្រសួងស្តីពីការប្រើប្រាស់និងការបែងចែកផលប្រយោជន៍ពីធនធានពន្ធុ (ABS-Sub-TWG) ដែលមានអ្នកចូលរួមចំនួន ៣០រូប
- លោកជំទាវ ចាន់ សុម៉ាលី បានដឹកនាំក្រុមការងារនាយកដ្ឋានជួបប្រជុំជាមួយតំណាងមន្ទីរពាក់ព័ន្ធក្នុងខេត្តមណ្ឌលគិរី និងតំណាងសហគមន៍តំបន់ការពារធម្មជាតិដែនជម្រកសត្វព្រៃកែវសីមា ពិគ្រោះយោបល់អំពីចំណេះដឹងជាប្រពៃណីរបស់ប្រជាសហគមន៍នៅតំបន់ភូមិភាគឥសានកម្ពុជាពាក់ព័ន្ធនឹងការប្រើប្រាស់ធនធានពន្ធុ ជាពិសេសគឺឱសថបុរាណ និង ពង្រឹងទំនាក់ទំនង និងការចូលរួមរបស់ប្រជាសហគមន៍ដើម្បីបន្តចងក្រងចំណេះដឹងទាំងនេះជាពិសេសគឺ ដើម្បីស្វែងយល់លំអិតទាំងវិធីសាស្ត្រនៃការព្យាបាល និងប្រភេទឱសថ ការដកហូត និងប្រើប្រាស់ធនធានពន្ធុសម្រាប់ការព្យាបាលនិងតម្រូវការទីផ្សារឱសថបុរាណ។លទ្ធផលនៃកិច្ចពិភាក្សានេះ នឹងផ្តល់ជាធាតុចូលសម្រាប់រៀបចំចងក្រងទិន្នន័យគោល និងសេចក្តីព្រាងយន្តការការពារនិងអភិរក្សចំណេះដឹងជាប្រពៃណីពាក់ព័ន្ធនឹងការប្រើប្រាស់ធនធានពន្ធុនៅកម្ពុជា

- បានផ្តល់លិខិតគាំទ្រក្នុងការនាំចេញសំណាក ចំនួន ១២ករណី ក្នុងគោលបំណងមិនធ្វើពាណិជ្ជកម្ម គឺសម្រាប់ ការសិក្សាស្រាវជ្រាវ និងការកំណត់ប្រភេទ (Taxonomy) ទៅប្រទេសមួយចំនួនដូចជា អាឡឺម៉ង់ អង់គ្លេស បារាំង កូរ៉េ និងជប៉ុន។
- លោកជំទាវ ចាន់ សុម៉ាលី បានចូលរួមផ្តល់បទសម្ភាសន៍ស្តីពីការអភិរក្សកេសរកូលនៅកម្ពុជា ក្នុងការលើកកម្ពស់ការអភិរក្ស ការសិក្សាស្រាវជ្រាវ ការអប់រំ ផ្សព្វផ្សាយ និងការកំសាន្ត នៅក្នុងកម្មវិធីបរិស្ថានដើម្បីអនាគតយើង នៅស្ថានីយ៍ទូរទស្សន៍អប្សរា
- បានសហការជាមួយអគ្គនាយកដ្ឋានចំណេះដឹង និង ព័ត៌មានបរិស្ថានក្នុងការរៀបចំផ្សព្វផ្សាយតាមរយៈបណ្តាញសង្គមនិងទូរទស្សន៍ ដើម្បីអបអរសាទរទិវាជីវៈចម្រុះអន្តរជាតិ ២២ ឧសភា ឆ្នាំ ២០២០ ក្រោមប្រធានបទ"ធម្មជាតិគឺជាដំណោះស្រាយនៃបញ្ហារបស់យើង"



រូបភាពទី 16 ៖ យុទ្ធនាការអបអរសាទរទិវាជីវៈចម្រុះអន្តរជាតិ ២២ ឧសភា ឆ្នាំ ២០២០ ក្រោមប្រធានបទ "**ធម្មជាតិគឺជាដំណោះស្រាយនៃបញ្ហារបស់យើង**"

## ៤.វឌ្ឍនភាពនៃការអនុវត្តគម្រោងនៅក្រោមអគ្គលេខាធិការដ្ឋានគ.ជ.អ.ច.

### ៤.១. គម្រោងBESD(នាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ)

- បានធ្វើការសិក្សាពីសក្តានុពលនៃតំបន់ក្បាលឆាយ ខេត្តព្រះសីហនុ និង ភ្នំគូលែនដើម្បីវាយតម្លៃនូវសេវាកម្មប្រព័ន្ធអេកូឡូស៊ី
- ពង្រាងយន្តការនៃការគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់សេវាកម្មប្រព័ន្ធអេកូឡូស៊ីត្រូវបានរៀបចំឡើងព្រមទាំងបានធ្វើសិក្ខាសាលាជាមួយថ្នាក់ដឹកនាំ នៃក្រសួងបរិស្ថាន
- ផែនការគ្រប់គ្រងតំបន់ការពារត្រូវបានព្រាង និងរៀបចំប្រជុំពិគ្រោះយោបល់ជាមួយ គណៈកម្មការ និងសមាជិកសហគមន៍ ក្នុងសហគមន៍ពពេល
- បានផ្តល់វគ្គបណ្តុះបណ្តាលស្តីពីការធ្វើសារពើភ័ណ្ឌត្រូវបានផ្តល់ជូនដល់សមាជិកសហគមន៍ ព្រមទាំងបានចុះធ្វើសារពើភ័ណ្ឌព្រៃឈើនៅក្នុងសហគមន៍ពេល។
- គោលនយោបាយសេដ្ឋកិច្ចចក្រា និងផែនការសកម្មភាពក្នុងការគ្រប់គ្រងប្លាស្ទិក ត្រូវបានរៀបចំឡើង (៥០%)
- ផែនការយុទ្ធសាស្ត្រទំនាក់ទំនង និងសារសំខាន់ៗក្នុងការគ្រប់គ្រងប្លាស្ទិកបានផលិតឡើង

ទំព័រ ២៤

- បានផ្សព្វផ្សាយ ពីការគ្រប់គ្រងប្លាស្ទិកដល់សិស្សានុសិស្ស និងសាធារណៈជននៅខេត្តកំពង់ចាម និងខេត្តកែប
- បានលើកបដា ផ្សព្វផ្សាយពី ការគ្រប់គ្រងប្លាស្ទិច នៅខេត្តកំពង់ចាម និងខេត្ត កែប
- បានពង្រាងអនុក្រិតស្តីពីការគ្រប់គ្រងប្លាស្ទិច ព្រមទាំងគោលការណ៍ណែនាំនៃទឡដុតសំរាម
- បានចុះចែកចាយធុងសំរាម ចំនួន៦០ ធុង នៅខេត្តកែប

**៤.២. គម្រោងរៀបចំគោលការណ៍ណែនាំ និងវិញ្ញាបនបត្រកម្មអគារបៃតងនៅកម្ពុជា**

- បាននឹងកំពុងសម្របសម្រួលឱ្យតំណាងគម្រោង Build4People ចូលរួមជាអ្នកសង្កេត
- ការណ៍ក្នុងកិច្ចប្រជុំក្រុមការងារបច្ចេកទេសទីក្រុងនិរន្តរភាព និងក្រុមការងារបច្ចេកទេសរៀបចំគោលការណ៍ណែនាំ និងការផ្តល់វិញ្ញាបនបត្រអគារបៃតងនៅកម្ពុជា។
- បានកំណត់សូចនាករ និងលក្ខណៈវិនិច្ឆ័យ អគារបៃតងសម្រាប់កម្ពុជា ដោយផ្អែកលើប្រព័ន្ធអគារបៃតងនៅតាមបណ្តាប្រទេសនានា នៅក្នុងតំបន់ ក៏ដូចជាសកលលោករួមមាន DGNB របស់អាឡឺម៉ង់ LEED របស់សហរដ្ឋអាមេរិក TREES របស់ប្រទេសថៃ LOTUS របស់ប្រទេសវៀតណាម G-SEED របស់សាធារណរដ្ឋកូរ៉េ EDGE របស់ធនាគារពិភពលោក ដើម្បីផ្ទៀងផ្ទាត់ជាមួយនឹងទិដ្ឋភាពច្បាប់ លក្ខខណ្ឌអាកាសធាតុ និងបរិបទប្រទេសកម្ពុជា

**៤.២.ការិយាល័យស្តង់ដារបៃតង និងការប្រើប្រាស់ និងការផលិតដោយចីរភាព**

- បានរៀបចំសេចក្តីសម្រេចបង្កើត និង រៀបចំកិច្ចប្រជុំលើកទី២ក្រុមការងារបច្ចេកទេសស្តីពី ការប្រើប្រាស់ និងផលិតកម្មដោយនិរន្តរភាព
- បាននឹងកំពុងសហការរៀបចំផែនទីបង្ហាញផ្លូវ និងគម្រោងសាកល្បងការប្រើប្រាស់ និងផលិតកម្មនិរន្តរភាព ជាមួយ UNEP
- បានសហការរៀបចំបោះពុម្ព និងផ្សព្វផ្សាយលើរបាយការណ៍សិក្សាវិសាលភាពស្តីពីការគ្រប់គ្រងសំណល់រឹងនៅខេត្តកែប ជាមួយ The Asia Foundation
- បានដាក់សំណើគម្រោងសេដ្ឋកិច្ចចក្រា និងគោលនយោបាយ ដើម្បីកាត់បន្ថយសំណល់ ប្លាស្ទិកនៅរាជធានីភ្នំពេញ (Circular Economy and Economic Policy Approaches to Curb Plastic Waste in Phnom Penh) សម្រាប់គម្រោង 4th MKCF របស់សាធារណៈរដ្ឋកូរ៉េ

**៤.៤. គម្រោងBESD (នាយកដ្ឋានសេដ្ឋកិច្ចបៃតង)**

- បានសម្របសម្រួលរៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រ និងផែនការសកម្មភាពសេដ្ឋកិច្ចចក្រា
- បានធ្វើការបណ្តុះបណ្តាល និងការផ្សព្វផ្សាយពីការគ្រប់គ្រង និងការកែច្នៃសំណល់ផ្សេងៗ ជាពិសេសសំណល់ប្លាស្ទិក ដល់សិស្សានុសិស្ស និងសាធារណជន នៅខេត្តកែប និងខេត្តកំពង់ចាម
- បានរៀបចំកិច្ចប្រជុំ និងប្រមូលទិន្នន័យស្តីពីផែនការយុទ្ធសាស្ត្រការប្រាស្រ័យទាក់ទង ដើម្បីបញ្ជ្រាបសារសេដ្ឋកិច្ចចក្រា

- កំពុងសហការរៀបចំប្រមូលទិន្នន័យស្តីពីការវាយតម្លៃឆាប់រហ័ស ការបង់ថ្លៃបន្ថែមទៅលើការប្រើប្រាស់ថង់ប្លាស្ទិកសម្រាប់ផ្សារទំនើប (Rapid Assessment on Plastic surcharge at the Super market)
- កំពុងសហការសូចនាករ និងស្តង់ដារសម្រាប់ជំរុញសណ្ឋាគារនិង ភោជនីយដ្ឋាន ក្នុងការកាត់បន្ថយជាពិសេសសំណល់ប្លាស្ទិក

**៤.៥. កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា ដំណាក់កាលទី៣ (CCCA3)**

- បានពិនិត្យលើសំណើគម្រោងនវានុវត្តន៍ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុចំនួន ៤២ ដែលបានដាក់ស្នើសុំហិរញ្ញប្បទានពីកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា។ យ៉ាងហោចណាស់គម្រោងចំនួន ៦ ត្រូវបានជ្រើសរើសឱ្យរៀបចំសំណើពេញលេញ ដើម្បីទទួលបានការគាំទ្រពីមូលនិធិកម្មវិធី CCCA ដែលមានទំហំទឹកប្រាក់សរុបប្រមាណ ៦០ម៉ឺនដុល្លារអាមេរិក សម្រាប់៣ឆ្នាំ (២០២០ដល់២០២២)
- ផ្តល់មូលនិធិខ្នាតតូចដល់ក្រសួង ស្ថាប័នចំនួន៥ មានទឹកប្រាក់ចំនួន២៥ម៉ឺនដុល្លារអាមេរិកសម្រាប់៣ឆ្នាំដើម្បីអនុវត្តគម្រោងសាកល្បងពាក់ព័ន្ធនឹងការចូលរួមចំណែករបស់ជាតិដើម្បីអនុវត្តអនុសញ្ញា UNFCCC ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងកម្មវិធីវិនិយោគហេដ្ឋារចនាសម្ព័ន្ធបង្កើតកម្មវិធីសិក្សាស្តីពីការប្រែប្រួលអាកាសធាតុសម្រាប់បឋមសិក្សាការរៀបចំ CCAPs តាមវិស័យ និងការបណ្តុះបណ្តាលនានា
- បាន និងកំពុងប្រមូលធាតុចូលពីអន្តរក្រសួងដើម្បីរៀបចំរបាយការណ៍ NDC update។ រហូតមកដល់ពេលនេះ កម្មវិធី CCCA បានទទួលធាតុចូលពីក្រសួង ស្ថាប័នសរុបចំនួន១៥។ ទីប្រឹក្សាជាតិ និងអន្តរជាតិសរុប ៤រូបបានចុះកិច្ចសន្យាដើម្បីរៀបចំរបាយការណ៍ NDC ដែលគ្រោងនឹងបញ្ចប់នៅចុងខែតុលា ឆ្នាំ២០២០
- បានគាំទ្រ និងរៀបចំកិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាង នីតិវិធី និងវិធានក្នុងយន្តការចូលរួមកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដឹកនាំដោយ ឯកឧត្តម ទិន ពន្លក អគ្គលេខាធិការ និងដោយមានការចូលរួមពីអ្នកពាក់ព័ន្ធនានារួមមានដៃគូអភិវឌ្ឍន៍ ក្រសួងស្ថាប័នពាក់ព័ន្ធ ជំនាញការជាតិនិងអន្តរជាតិ សរុប ៣០នាក់។

**៤.៦. គម្រោង «ការកាត់បន្ថយភាពងាយរងគ្រោះនៃជីវភាពរបស់ប្រជាជនកម្ពុជានៅជនបទតាមរយៈការពង្រឹងផែនការប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិ និងអនុវត្តសកម្មភាពអាទិភាព(SRL)»**

- បានចូលរួម និងសម្របសម្រួលក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលគម្រោងពីលទ្ធផលដែលបានអនុវត្ត និងទិសដៅបន្តសម្រាប់ឆ្នាំ២០២០ របស់គម្រោង «ការកាត់បន្ថយភាពងាយរងគ្រោះនៃជីវភាពរបស់ប្រជាជនកម្ពុជានៅជនបទ តាមរយៈការពង្រឹងផែនការប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិ និងអនុវត្តសកម្មភាពអាទិភាព» និង

- បានចូលរួម និងសម្របសម្រួលក្នុងកិច្ចប្រជុំផ្សព្វផ្សាយពីលទ្ធផលនៃការវាស់ស្ទង់សមត្ថភាពនៃគម្រោងកែលម្អជីវភាពរបស់ក្រុមកសិករ នៅភូមិឃុំស្រុកគោលដៅ ខេត្តកំពង់ធំ និងខេត្តសៀមរាប និងបានជួយសម្របសម្រួលរៀបចំការចុះធ្វើទស្សនកិច្ចសិក្សារបស់ក្រុមការងារយេនឌ័រ និងស្ត្រីរបស់ក្រសួងបរិស្ថានដឹកនាំដោយលោក ជំទាវ ម៉ុម ថានី រដ្ឋលេខាធិការ នៅទីតាំងអនុវត្តន៍គម្រោង SRL មួយចំនួនក្នុងខេត្តកំពង់ធំ និងសៀមរាបផងដែរ។

### ៤.៧. គម្រោង «ការកសាងភាពធន់នឹងអាកាសធាតុនៃប្រព័ន្ធទីក្រុងតាមរយៈការបន្សាំដោយផ្អែកលើប្រព័ន្ធអេកូឡូស៊ីនៅតំបន់អាស៊ីប៉ាស៊ីហ្វិក Ecosystem Based Adaptation (EbA)»

- បានចូលរួមកិច្ចប្រជុំសិក្សាស្រាវជ្រាវសម្រាប់ការអនុវត្តគម្រោងការបន្សាំទីក្រុងដោយផ្អែកលើប្រព័ន្ធអេកូឡូស៊ី(EbA project) នៅទីក្រុងកែប ខេត្តកែប
- បានចូលរួមសិក្ខាសាលាអនុវត្តន៍គម្រោងរបស់អង្គការ UNEPនៅអាស៊ីតាមរយៈបណ្តាញអិនធឺណេតស្តីពីការព្យាករណ៍ការប្រែប្រួលអាកាសធាតុ វិធីសាស្ត្រ និងឧបករណ៍ វាយតម្លៃ ហានិភ័យដើម្បីរៀបចំផែនការបន្សាំដែលផ្តោតលើតំបន់អាស៊ី ប៉ាស៊ីហ្វិក នាថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២០ នៅទីស្តីការក្រសួងបរិស្ថាន និង
- បានចូលរួម និងសម្របសម្រួលក្នុងកិច្ចប្រជុំពិគ្រោះយោបល់ដើម្បីពិនិត្យលើរបាយការណ៍វាយតម្លៃសេដ្ឋកិច្ចសង្គម ជីវៈចម្រុះ និងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ក្រោមគម្រោង «ការកសាងភាពធន់នឹងអាកាសធាតុ នៃប្រព័ន្ធទីក្រុងតាមរយៈការបន្សាំដោយផ្អែកលើប្រព័ន្ធអេកូឡូស៊ីនៅតំបន់អាស៊ីប៉ាស៊ីហ្វិក» នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ នៅខេត្តកែប។

### ៤.៨. គម្រោងការពង្រឹងសមត្ថភាពដើម្បីបង្កើនតម្លាភាពក្នុងការអនុវត្ត និងតាមដានការរួមចំណែករបស់ថ្នាក់ជាតិដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុក្នុងវិស័យកសិកម្ម និងការប្រើប្រាស់ដី (NDC implementation)

- បានរៀបចំកិច្ចប្រជុំជាមួយអង្គការស្បៀង និងកសិកម្ម (FAO)ដើម្បីពិភាក្សាត្រៀមសម្រាប់ពិធីបើកអង្គសិក្ខាសាលាចាប់ផ្តើមអនុវត្តគម្រោង«ការពង្រឹងសមត្ថភាពដើម្បីបង្កើនតម្លាភាពក្នុងការអនុវត្ត និងតាមដានការរួមចំណែករបស់ថ្នាក់ជាតិដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុក្នុងវិស័យកសិកម្ម និងការប្រើប្រាស់ដី» នាថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០ នៅបន្ទប់ប្រជុំនាយកដ្ឋានប្រែប្រួលអាកាសធាតុ
- បានសហការរៀបចំសិក្ខាសាលាចាប់ផ្តើមគម្រោង «ការពង្រឹងសមត្ថភាពដើម្បីបង្កើនតម្លាភាពក្នុងការអនុវត្តនិងតាមដានការរួមចំណែករបស់ថ្នាក់ជាតិដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ក្នុងវិស័យកសិកម្ម និងការប្រើប្រាស់ដី» នៅថ្ងៃទី១២ ខែមីនា ឆ្នាំ ២០២០ នៅសណ្ឋាគារភ្នំពេញ រាជធានីភ្នំពេញ
- បានពិនិត្យ និងកំណត់សមាសភាពគណៈកម្មាធិការដឹកនាំ និងភារកិច្ចការទទួលខុសត្រូវក្នុងការអនុវត្តគម្រោង Strengthening Capacity in the Agriculture and Land-Use Sectors for

Enhanced Transparency in Implementation and Monitoring of Cambodia's Nationally Determined Contribution (NDC)

- បានរៀបចំលិខិតសំណើសុំអនុញ្ញាតជាគោលការណ៍ បង្កើតគណៈកម្មាធិការដឹកនាំគម្រោង និងរៀបចំលិខិតស្នើសុំទៅក្រសួងពាក់ព័ន្ធចូលរួមជាសមាជិកក្នុងការពង្រឹងសមត្ថភាព ដើម្បីបង្កើតតម្លាភាពក្នុងការអនុវត្ត និងតាមដានការរួមចំណែករបស់ថ្នាក់ជាតិក្នុងការអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពី ការប្រែប្រួលអាកាសធាតុ(NDC)ក្នុងវិស័យកសិកម្មនិងការប្រើប្រាស់ដី និង
- បានសម្របសម្រួល និងពិភាក្សាជាមួយតំណាងអង្គការស្បៀង និងកសិកម្ម (FAO) ដើម្បី ពិនិត្យលើសេចក្តីព្រាងលក្ខខណ្ឌការងារសម្រាប់សមាសភាព គណៈកម្មាធិការក្រុមប្រឹក្សាភិបាលគម្រោង (PSC) និងក្រុមការងារគ្រប់គ្រងគម្រោង (PMU) ការទទួលខុសត្រូវ និងតួនាទីភារកិច្ច និងការរៀបចំលិខិតស្នើសុំសមាសភាពជាប្រធាន អនុប្រធាន និងសមាជិក PSC នាព្រឹកថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០។

### ៤.៩. គម្រោងការរៀបចំរបាយការណ៍ជាតិលើកទី៣ ស្តីពីការប្រែប្រួលអាកាសធាតុ (TNC)

- បានសម្របសម្រួលពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងរបាយការណ៍ជាតិលើកទី៣ ទាក់ទងនឹងផ្នែកសារពើភណ្ឌ និងកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ ការវាយតម្លៃភាពងាយរងគ្រោះនិងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ
- បានស្នើសុំឱ្យធ្វើការពិនិត្យលម្អិតតាមរយៈការផ្តល់យោបល់ និងអនុសាសន៍របស់មន្ត្រីជំនាញលើរបាយការណ៍បច្ចេកទេសតាមផ្នែកនីមួយៗ មុនដាក់ជូនទៅកាន់លេខាធិការដ្ឋានអនុសញ្ញាក្របខ័ណ្ឌសហប្រជាតិស្តីពីការប្រែប្រួលអាកាសធាតុ។

### ៤.១០. គម្រោង/កម្មវិធីត្រៀមរបស់មូលនិធិអាកាសធាតុបៃតង GCF Readiness Programme

- បានរៀបចំសិក្ខាសាលាថ្នាក់ជាតិស្តីពីការលើកកម្ពស់មូលដ្ឋានវិទ្យាសាស្រ្តអាកាសធាតុសម្រាប់សកម្មភាពផ្តល់មូលនិធិដោយមូលនិធិអាកាសធាតុបៃតង (GCF) នៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២០
- បានរៀបចំសម្របសម្រួលកិច្ចប្រជុំពិភាក្សាជាមួយតំណាងUNDP ប្រចាំនៅទីក្រុងបាងកក ប្រទេសថៃ និងអ្នកជំនាញការអន្តរជាតិតាមរយៈ Skype ដើម្បីពិនិត្យមើលលើវឌ្ឍនភាព ក្នុងការរៀបចំសំណើគម្រោងត្រៀមផែនការជាតិបន្សាំឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងចំណុចខ្វះចន្លោះ និងធ្វើការកែសម្រួល ដើម្បីបញ្ចប់និងត្រូវដាក់ស្នើសុំមូលនិធិអាកាសធាតុបៃតង (GCF) នាពេលខាងមុខនៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២០
- បានសម្របសម្រួលពិនិត្យ និងរៀបចំកំណត់បង្ហាញករណីសំណើសុំការគាំទ្រលើសំណើគម្រោង ស្តីពី «ការគាំទ្រដល់ស្ថាប័នទទួលហិរញ្ញប្បទានផ្ទាល់នៅកម្ពុជា ដើម្បីបំពេញលក្ខខណ្ឌទទួលស្គាល់» ក្រោមកម្មវិធីត្រៀម (Readiness Programme) របស់មូលនិធិអាកាសធាតុបៃតង របស់គណៈកម្មាធិការជាតិ សម្រាប់អភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) និងរៀបចំលិខិតគាំទ្រ

- បាននឹងកំពុងពិនិត្យ និងផ្តល់យោបល់លើសំណើគម្រោង GCF Readiness របស់អង្គការ UN-HABITAT ស្តីពីការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុតាមរយៈការគ្រប់គ្រងសំណល់រឹងនិងរាវដោយចីរភាព នៅទីក្រុងតំបន់ឆ្នេរក្នុងប្រទេសកម្ពុជា
- បានចូលរួមសម្របសម្រួលក្នុងកិច្ចប្រជុំជាមួយតំណាងអង្គការ IUCN ពិភាក្សាអំពីករណីសំណើសុំលិខិតមិនជំទាស់ជូនទៅមូលនិធិអាកាសធាតុបៃតងសម្រាប់មូលនិធិអាកាសធាតុ ថ្នាក់ក្រោមជាតិសកលរបស់អង្គការ Region of Climate Change (R20) ក្រុមហ៊ុន Pegasus Capital និងអង្គការ Gold Standard នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២០ នៅទីស្តីការក្រសួងបរិស្ថាន
- កំណត់បង្ហាញអំពី ករណីសំណើសុំលិខិតមិនជំទាស់ជូនទៅមូលនិធិអាកាសធាតុបៃតងសម្រាប់សំណើគម្រោងសម្រួលដល់ការរៀបចំគម្រោង នៃគម្រោងភាពជាដៃគូនៃសាធារណៈសង្គមឯកជនសម្រាប់កសិកម្មចម្រុះ និងជីវភាពរស់នៅដែលធន់នៅក្នុងតំបន់ភាគខាងជើងអាងបឹងទន្លេសាប ដែលស្នើដោយអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិប្រចាំកម្ពុជា
- គម្រោងផែនការជាតិបន្សាំឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា ត្រូវបានបញ្ចប់ និងស្នើសុំជាគោលការណ៍ដើម្បីដាក់ជូនទៅមូលនិធិអាកាសធាតុបៃតង។
- សម្រាប់ព័ត៌មានលម្អិតឈ្មោះគម្រោង/កម្មវិធី ដែលអនុវត្តដោយនាយកដ្ឋានជំនាញឆ្នាំ២០២០ មានភ្ជាប់នៅក្នុងឧបសម្ព័ន្ធទី២។
- សហការជាមួយគម្រោងយន្តការអភិវឌ្ឍន៍ស្អាត (CDM, JCM)
- បានបន្តធ្វើលិខិតឆ្លើយតបទៅក្រុមហ៊ុន Water & life ដើម្បីស្វាគមន៍ក្នុងការអនុវត្តគម្រោងនេះជាគម្រោងCDM នៅកម្ពុជា
- ឯកឧត្តមប្រធាន ក.ជ.អ.ច. និងជារដ្ឋមន្ត្រីក្រសួងបរិស្ថានអនុញ្ញាតឱ្យឯកឧត្តម សាបូ អូហ្សាណូ រដ្ឋលេខាធិការ និងជាប្រធានស្ថាប័នជាតិទទួលបន្ទុកយន្តការអភិវឌ្ឍន៍ស្អាត ចុះហត្ថលេខាលើលិខិតឆ្លើយតបទៅក្រុមហ៊ុន Water & Life ដែលមានបំណងអនុវត្តជាគម្រោងយន្តការអភិវឌ្ឍន៍ស្អាត (CDM PoA) នៅកម្ពុជា
- បានរៀបចំរបាយការណ៍កិច្ចប្រជុំគណៈកម្មាធិការចម្រុះយន្តការឥណទានកាបូនរួមគ្នាលើកទី៥
- បានរៀបចំគោលការណ៍ស្នើសុំរៀបចំឡើងវិញ សមាសភាពសមាជិកគណៈកម្មាធិការចម្រុះ JCM និងក្រុមការងារលេខាធិការដ្ឋានគណៈកម្មាធិការចម្រុះ JCM
- បានពិនិត្យលើឯកសារគម្រោងរបស់ផ្សារទំនើប AEON Mall 2 ផ្តោតសំខាន់លើវិធីសាស្ត្រដែលបានស្នើ និងជ្រើសរើស និងបានជូនដំណឹងទៅឯកឧត្តមសហប្រធាន និងទៅកាន់ភាគីជប៉ុនសម្រាប់ដំណើរការជំហានបន្ទាប់
- បានរៀបចំសំណើសុំអនុញ្ញាតជាគោលការណ៍ពិនិត្យបញ្ចូលសមាជិកថ្មី ក្នុងគណៈកម្មាធិការចម្រុះ និងកែសម្រួលសមាសភាពក្រុមការងារលេខាធិការដ្ឋានគណៈកម្មាធិការចម្រុះ(JCM)និងបាន

ផ្ញើលិខិតប្រកាសជាផ្លូវការសមាសភាពសមាជិកគណៈកម្មាធិការចម្រុះ (JCM) និងសមាសភាពសមាជិកលេខាធិការដ្ឋានគណៈកម្មាធិការចម្រុះ JCM ថ្មី

- បានពិនិត្យមើលលទ្ធភាពក្នុងការគាំទ្រសំណើគម្រោងរបស់ អង្គការអភិវឌ្ឍន៍ឧស្សាហកម្មសហប្រជាជាតិ (UNIDO) ស្តីពីកម្មវិធីនវានុវត្តន៍បច្ចេកវិទ្យាស្អាតសកលដើម្បីពន្លឿននវានុវត្តន៍បច្ចេកវិទ្យាស្អាត និង សហគ្រិនភាព ខ្នាតតូច និងមធ្យម (SMEs) នៅកម្ពុជា និងលិខិតសំណើសុំអនុញ្ញាតជាគោលការណ៍គាំទ្រសំណើគម្រោងរបស់អង្គការ UNIDO ស្តីពីកម្មវិធីនវានុវត្តន៍បច្ចេកវិទ្យាស្អាតសកល ដើម្បីពន្លឿននវានុវត្តន៍បច្ចេកវិទ្យាស្អាត និងសហគ្រិនភាព ខ្នាតតូច និងមធ្យម (SMEs) នៅកម្ពុជានិងគាំទ្រការដាក់មជ្ឈមណ្ឌលបណ្តុះថ្មី «តេជោ» ជាស្ថាប័នប្រតិបត្តិគម្រោងរបស់អង្គការ UNIDO។

## ៤.១១.គម្រោង CAMPAS

- ឯកឧត្តម ទិន ពន្លក អគ្គលេខាធិការនៃ ក.ជ.អ.ច. និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងគម្រោងកាំប៉ាស់(CAMPAS) បានដឹកនាំកិច្ចប្រជុំ"គណៈកម្មាធិការគ្រប់គ្រងគម្រោងលើកទី៤" តាមប្រព័ន្ធ Online (ClickMeeting) នៅទីស្តីការក្រសួងបរិស្ថាន ដែលមានការចូលរួមពីសមាជិកគណៈកម្មាធិការគ្រប់គ្រងគម្រោង តំណាងកម្មវិធីបរិស្ថានសហប្រជាជាតិ ទីប្រឹក្សាឯករាជ្យអន្តរជាតិ តំណាងនាយកដ្ឋានជីវៈចម្រុះនៃ អ.ក.អ.ច. អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន រដ្ឋបាលខេត្តមណ្ឌលគិរី មន្ទីរបរិស្ថានខេត្ត អង្គការដៃគូរួមមានអង្គការ WWF, WCS, BirdLife, ERECON និងអង្គការ Live & Learn ដែលមានសមាជិកចូលរួមសរុបប្រមាណ ៣១រូប
- លោកជំទាវ ចាន់ សុម៉ាលី បានដឹកនាំកិច្ចប្រជុំចំនួន ៤លើកស្តីពី "ការពង្រឹងការងារអភិរក្ស ជីវៈចម្រុះ និងព្រៃស្តុកកាបូននៃប្រព័ន្ធតំបន់ការពារធម្មជាតិកម្ពុជាតាមរយៈកិច្ចសហការគ្រប់គ្រងតំបន់ទេសភាពខាងកើតទន្លេមេគង្គ" ដោយមានការ ចូលរួមពីតំណាងអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន និងតំណាងអង្គការដៃគូ រួមមានតំណាងរដ្ឋបាលខេត្តមណ្ឌលគិរី មន្ទីរបរិស្ថាន និងមន្ទីរកិច្ចការនារី អង្គការ WCS, BirdLife WWF ERECON និងអង្គការ Live and Learn ដែលមានសមាជិកចូលរួមសរុប ចំនួន ៥៥រូប
- បានសហការជាមួយអង្គការកម្ពុជាអភិវឌ្ឍន៍សហគមន៍ និងបរិស្ថាន (Live & Learn Cambodia) ដើម្បីរៀបចំកិច្ចប្រជុំពិគ្រោះយោបល់លើយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទងសម្រាប់តំបន់ការពារធម្មជាតិ នៅទីស្តីការក្រសួងបរិស្ថាន ដោយមានការចូលរួមពីតំណាងអគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន និងអង្គការដៃគូរួមមាន អង្គការ WCS, BirdLife, និងERECON សរុបចំនួន ១៥រូប
- បានពិនិត្យ និងកែលម្អរបាយការណ៍ប្រចាំឆ្នាំ២០២០ (PIR 2020) យោងតាមការផ្តល់យោបល់កែលម្អរបស់កម្មវិធីបរិស្ថានសហប្រជាជាតិ (UNEP)

- បានពិនិត្យ និងកែសម្រួលផែនការសកម្មភាព និងផែនការថវិកាប្រចាំឆ្នាំ២០២០ យោងតាម ការផ្តល់យោបល់កែលម្អរបស់កម្មវិធីបរិស្ថានសហប្រជាជាតិ (UNEP)
- បានពិនិត្យនិងផ្តល់យោបល់កែលម្អលើរបាយការណ៍វាយតម្លៃពាក់កណ្តាលគម្រោងកាំប៉ាស់ (MTR) និងបានចូលរួមប្រជុំនិងតាមដានការអនុវត្តការងាររបស់ដៃអនុវត្តគម្រោងកាំប៉ាស់ថ្នាក់ជាតិនិង ថ្នាក់ខេត្ត។

### ៤.១២. គម្រោង ABS

- បានរៀបចំសេចក្តីព្រាង និងរៀបចំសិក្ខាសាលាដើម្បីពិនិត្យលើសេចក្តីព្រាងក្របខណ្ឌការងារជាតិស្តីពីការប្រើប្រាស់ និងការបែងចែកផលប្រយោជន៍ពីធនធានពន្ធុ នៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២០ នៅភោជនីយដ្ឋានទន្លេបាសាក់ ២ ដោយមានអ្នកចូលរួម ៧០រូប។

## ៥. សកម្មភាពចូលរួម កិច្ចប្រជុំ សិក្ខាសាលា បណ្តុះបណ្តាលនៅក្នុង និងក្រៅប្រទេស

តារាង ២៖ សកម្មភាពចូលរួម កិច្ចប្រជុំ សិក្ខាសាលា បណ្តុះបណ្តាលនៅក្នុងប្រទេស

| ល.រ | ឈ្មោះអង្គភាព | ចូលរួម ប្រជុំ សិក្ខាសាលា បណ្តុះបណ្តាល ក្នុងប្រទេស | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | ប្រជុំ | | | សិក្ខាសាលា | | | បណ្តុះបណ្តាល | | |
| | | លើក | អ្នកចូលរួម | | លើក | អ្នកចូលរួម | | លើក | អ្នកចូលរួម | |
| | | | សរុប | ស្រី | | សរុប | ស្រី | | សរុប | ស្រី |
| ១ | នាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ | ៤០ | ៤៧ | ១០ | ២៧ | ២៧ | ៩ | ៣ | ៥ | ៣ |
| ២ | នាយកដ្ឋានសេដ្ឋកិច្ចបៃតង | ៣១ | ៤៩ | ៩ | ១៥ | ១៥ | ៦ | ២ | ៣ | ១ |
| ៣ | នាយកដ្ឋានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា | ៤០ | ៤៧ | ១០ | ២៧ | ២៧ | ៩ | ១ | ១ | ០ |
| ៤ | នាយកដ្ឋានប្រែប្រួលអាកាសធាតុ | ១៥២ | ២៥៣ | ៥២ | ៣៩ | ៦៥ | ២១ | ១១ | ១៩ | ៥ |
| ៥ | នាយកដ្ឋានជីវចម្រុះ | ២១ | ៤០ | ១៤ | ៩ | ១១ | ១ | ១ | ១ | ០ |
| | សរុប | ២៨៤ | ៤៣៦ | ៩៥ | ១១៧ | ១៤៥ | ៦៤ | ១៨ | ២៩ | ៩ |

ប្រភព៖នាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. គិតត្រឹមខែកញ្ញា ឆ្នាំ២០២០

តារាងទី៣  សកម្មភាពចូលរួម កិច្ចប្រជុំ សិក្ខាសាលា បណ្តុះបណ្តាលនៅក្រៅប្រទេស

| ល.រ | ឈ្មោះអង្គភាព | ចូលរួម ប្រជុំ សិក្ខាសាលា បណ្តុះបណ្តាល ក្រៅប្រទេស | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | ប្រជុំ | | | សិក្ខាសាលា | | | បណ្តុះបណ្តាល | | |
| | | លើក | អ្នកចូលរួម | | លើក | អ្នកចូលរួម | | លើក | អ្នកចូលរួម | |
| | | | សរុប | ស្រី | | សរុប | ស្រី | | សរុប | ស្រី |
| ១ | នាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ | ០ | ០ | ០ | ០ | ០ | ០ | ៣ | ៣ | ០ |
| ២ | នាយកដ្ឋានសេដ្ឋកិច្ចបៃតង | ០ | ០ | ០ | ០ | ០ | ០ | ១ | ១ | ១ |
| ៣ | នាយកដ្ឋានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា | ០ | ០ | ០ | ០ | ០ | ០ | ១ | ១ | ១ |
| ៤ | នាយកដ្ឋានប្រែប្រួលអាកាសធាតុ | ២ | ២ | ១ | ៥ | ៦ | ១ | ០ | ០ | ០ |
| ៥ | នាយកដ្ឋានជីវៈចម្រុះ | ២ | ២ | ០ | ២ | ២ | ០ | ០ | ០ | ០ |
| | សរុប | ៤ | ៤ | ១ | ៧ | ៨ | ១ | ៣ | ៥ | ២ |

ប្រភព៖នាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. គិតត្រឹមខែកញ្ញា ឆ្នាំ២០២០

## ៦. ការគ្រប់គ្រងហិរញ្ញវត្ថុ

ចំណាយដែលបានស្នើសុំជំពូក៦០ លើការទិញអស់១១៥ ៩៤៧ ៨០០៛ ស្មើនឹង៨៩,៦៤% នៃឥណទានវិចារណកម្ម ១៣២ ៨៥០ ០០០រៀល។ ចំណាយដែលបានស្នើសុំជំពូក៦១ លើសេវាខាងក្រៅអស់ ៥០០ ២៨៥ ២៨៥៛ ស្មើនឹង ៤៦,១៥%នៃឥណទានវិចារណកម្ម ១ ០៨ ៤ ១០០ ០០០ រៀល និង ចំណាយដែលបានស្នើសុំជំពូក៦៥ លើឧបត្ថម្ភធនអស់ ១០ ៧២៤ ១៩៨៛ ស្មើនឹង២៣,៣៦%នៃឥណទានវិចារណកម្ម ៤៦ ០០០ ០០០ រៀល។ សរុបជារួមចំណាយដែលបានស្នើសុំសរុបរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍ដោយចីរភាពគឺ ៦២៦ ៩៧៩ ២៨៣៛ ស្មើនឹង៤៩,៦៤% នៃឥណទានវិចារណកម្ម ៦២៦ ៩៧៩ ២៨៣ រៀល។

## ៧. ការរៀនសូត្រនិងបទពិសោធន៍ដែលទទួលបាន

- ការគាំទ្រ និងការណែនាំតម្រង់ទិសកម្រិតគោលនយោបាយរបស់ថ្នាក់ដឹកនាំមានភាពច្បាស់លាស់ ប្រាកដនិយម និងឆ្លើយតបទៅនឹងអាទិភាពរបស់ជាតិ
- រក្សាបានជារួមនូវភាពជាម្ចាស់ និងភាពជាអ្នកដឹកនាំនៅគ្រប់លំដាប់ថ្នាក់
- កំណត់បញ្ហាច្បាស់លាស់ និងលើកសំណើសិក្សាស្រាវជ្រាវដែលស្របទៅនឹងអាទិភាពរបស់ជាតិ
- ប្រើវិធីសាស្ត្រសិក្សាស្រាវជ្រាវបែបវិទ្យាសាស្ត្រ ដែលធានាបាននូវសត្យានុម័ត និងភាពជាក់លាក់នៃអនុសាសន៍គោលនយោបាយដែលស្នើឡើង
- ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញភាគច្រើនមានវិន័យ ការទទួលខុសត្រូវខ្ពស់ក្នុងការអនុវត្តភារកិច្ច សាមគ្គីភាពផ្ទៃក្នុង និងមានសមត្ថភាពជំនាញច្បាស់លាស់
- រក្សាបាន និងលើកកម្ពស់ជាលំដាប់ ការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការអន្តរក្រសួង ដោយឈរលើមូលដ្ឋានគោរពគ្នាទៅវិញទៅមក និងផលប្រយោជន៍ជាតិជារួម
- រក្សាបាន និងលើកកម្ពស់ជាលំដាប់នូវ ភាពជាដៃគូ ទំនុកទុកចិត្ត និងសមត្ថភាពកៀរគរធនធានក្នុងចំណោមដៃគូអន្តរជាតិនានា
- មាននីតិវិធីច្បាស់លាស់និងសមត្ថភាពសមរម្យ ក្នុងការគ្រប់គ្រងគម្រោង ការគ្រប់គ្រងហិរញ្ញវត្ថុ និងការតាមដានត្រួតពិនិត្យ។

## ៨. បញ្ហាប្រឈម

- បរិមាណ សមត្ថភាពជំនាញ បទពិសោធន៍ និងចំណេះដឹងរបស់មន្ត្រីក្នុងការិយាល័យនីមួយៗ មិនទាន់ឆ្លើយតបនឹងទំហំការងារដែលចេះតែកើនឡើងជាលំដាប់
- ការងារស្នូល និងគម្រោងមួយចំនួនត្រូវបានពន្យាពេលដោយសារវិការលដាលជាសកលនៃជំងឺកូវីត១៩
- វិបត្តិជំងឺឆ្លង កូវីត-១៩ ដែលធ្វើឱ្យសកម្មភាពមួយចំនួន មិនអាចសម្រេចបាន
- កង្វះខាតធនធានមនុស្ស ចំនួនមន្ត្រីបន្ថែម និងសម្ភារប្រើប្រាស់
- កង្វះខាតថវិកាក្នុងការគាំទ្រការសិក្សាស្រាវជ្រាវ និងការអនុវត្តបច្ចេកវិទ្យាបញ្ចេញកាបូនតិច និងភាពធន់នឹងការប្រែប្រួលអាកាសធាតុ
- កិច្ចសហការពីដៃគូអភិវឌ្ឍន៍ និងប្រទេសផ្តល់ជំនួយផ្សេងៗនៅមានកម្រិត
- មន្ត្រីជំនាញបច្ចេកទេសត្រូវការបំពេញចំណេះដឹងបន្ថែមលើការសិក្សាស្រាវជ្រាវ ចំណេះដឹងនិងភាសាបរទេស ពិសេសភាសាអង់គ្លេស

- ថវិកាមានកំណត់សម្រាប់ផែនការសកម្មភាពប្រចាំឆ្នាំ និងស្ថានភាពជម្ងឺរាតត្បាត Covid19 កំពុងនិងបន្តដែលបណ្តាលឱ្យការអនុវត្តការងារមួយចំនួនត្រូវអាក់ខាន។
- មិនមានថវិកាគ្រប់គ្រាន់សម្រាប់មន្ត្រីជំនាញក្នុងការចុះបំពេញការងារនៅមូលដ្ឋាន និងនៅតាមតំបន់ការពារធម្មជាតិជាពិសេសការសិក្សាស្រាវជ្រាវ និងការចុះប្រមូលព័ត៌មាន និងទិន្នន័យ ពីសំណាកសត្វ និងរុក្ខជាតិខ្វះបុគ្គលិកដែលមានជំនាញកំណត់អត្តសញ្ញាណប្រភេទសត្វ និងរុក្ខជាតិ(Taxonomy) និងច្បាប់។

## ៩. ទិសដៅអនុវត្តបន្តឆ្នាំ២០២១

### ៩.១ នាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ

- បន្តសម្របសម្រួលការងារប្រតិបត្តិការរដ្ឋបាលរបស់អគ្គលេខាធិការដ្ឋានក.ជ.អ.ច.
- សម្របសម្រួលបេសកកម្មទាំងក្នុងនិងក្រៅប្រទេសជូនដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្នុងអគ្គលេខាធិការដ្ឋាន
- រៀបចំ និងសម្របសម្រួលរៀបចំប្រជុំគណៈកម្មការប្រតិបត្តិក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
- រៀបចំ និងសម្របសម្រួលកិច្ចប្រជុំប្រចាំឆ្នាំក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
- រៀបចំ និងសម្របសម្រួលវគ្គបណ្តុះបណ្តាលស្តីពីការអភិវឌ្ឍន៍ដោយចីរភាពដល់មន្ត្រីរាជការថ្នាក់ក្រោមជាតិ ចំនួន២លើក
- សម្របសម្រួល និងរៀបចំរបាយការណ៍ជាតិស្ម័គ្រចិត្តឆ្នាំ២០២០(VNR) និងរបាយការណ៍វឌ្ឍនភាពស្តីពីសូចនាករគោលដៅអភិវឌ្ឍន៍ដោយចីរភាពវិស័យបរិស្ថាន
- សម្របសម្រួល និងរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិវិស័យបរិស្ថាន និងគោលនយោបាយប្រជាជន

### ៩.២ នាយកដ្ឋានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

- បន្តរៀបចំសិក្ខាសាលាលើកកម្ពស់ចំណេះដឹងវិទ្យាសាស្ត្របច្ចេកវិទ្យានវានុវត្តន៍ និងបោះពុម្ព ឯកសារផ្សព្វផ្សាយពាក់ព័ន្ធ
- ត្រៀមរៀបចំសិក្ខាសាលាលើកកម្ពស់ចំណេះដឹងស្តីពីការប្រើប្រាស់ថាមពលនុយក្លេអ៊ែរ សម្រាប់បម្រើឱ្យគោលបំណងសន្តិភាពដល់និស្សិតដោយសហការជាមួយសាកល វិទ្យាល័យ
- ត្រៀមបន្តចូលរួមរៀបចំពិព័រណ៍វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
- បន្តចូលរួមសន្និសីទសិក្ខាសាលាវគ្គបណ្តុះបណ្តាលកិច្ចប្រជុំ និងវេទិកាពាក់ព័ន្ធនានា
- ត្រៀមបញ្ចប់ លើសេចក្តីព្រាងក្រមសីលធម៌សិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
- បន្តពង្រឹងសមត្ថភាពមន្ត្រីតាមរយៈការចាត់បញ្ជូនឱ្យចូលរួមវគ្គបណ្តុះបណ្តាលទាំងរយៈ ពេលខ្លី និងវែងក្នុង/ក្រៅប្រទេស
- នឹងបន្តរៀបចំពង្រាងផែនទីបង្ហាញផ្លូវ សម្រាប់នាយកដ្ឋាន
- នាយកដ្ឋានបន្តសហការជាមួយអង្គការអភិវឌ្ឍន៍ឧស្សាហកម្មសហប្រជាជាតិUNIDOក្នុងការអនុវត្តគម្រោង«ការវាយតម្លៃតម្រូវការបច្ចេកវិទ្យាសម្រាប់តំបន់សេដ្ឋកិច្ចពិសេស ក្នុងខេត្តព្រះសីហនុ»
- នាយកដ្ឋានបន្តសហការជាមួយមជ្ឈមណ្ឌល និងបណ្តាញបច្ចេកវិទ្យាអាកាសធាតុក្នុង ការរៀបចំសំណើគម្រោងកសាងភាពធន់នឹងអាកាសធាតុសម្រាប់គ្រោះទឹកជំនន់ និង គ្រោះរាំងស្ងួតនៅក្នុងខេត្តកំពង់ធំ និងខេត្តព្រៃវែង តាមរយៈប្រព័ន្ធជូនដំណឹងជាមុន ការពង្រឹងសមត្ថភាពការបន្សាំផ្នែក កសិកម្ម និងការកែលម្អជីវភាពរស់នៅដើម្បីរៀបចំសំណើគម្រោងស្នើសុំការគាំទ្រពីមូលនិធិអាកាសធាតុបៃតង (GCF)
- នាយកដ្ឋានបន្តសហការជាមួយភាគីកូរ៉េ ក្នុងការសរសេរសំណើរគម្រោងថ្នាក់តំបន់ «ការបំលែងសំណល់ទៅជាថាមពល»ដើម្បីទទួលការគាំទ្រពីមូលនិធិ សហប្រតិបត្តិការ អាស៊ាន-កូរ៉េ

ទំព័រ ៣៣

- នាយកដ្ឋានបន្តកៀរគរការគាំទ្រពីប្រទេសម្ចាស់ជំនួយ ដៃគូអភិវឌ្ឍន៍ និងស្ថាប័នពាក់ព័ន្ធនានា ដើម្បីជំរុញការអនុវត្តការងារវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
- បន្តអនុវត្តអនុស្សរណៈនៃការយោគយល់លើកិច្ចសហប្រតិបត្តិការក្នុងការប្រើប្រាស់ ថាមពលនុយក្លេអ៊ែរសម្រាប់បម្រើឱ្យគោលបំណងសន្តិភាពជាមួយភាគីរុស្ស៊ី និងភាគីចិន
- ត្រៀមរៀបចំសន្និសិទសារព័ត៌មានដើម្បីធ្វើការផ្សព្វផ្សាយអំពីអត្ថប្រយោជន៍ នៃបច្ចេកវិទ្យានុយក្លេអ៊ែរក្នុងជីវិតរស់នៅប្រចាំថ្ងៃ និងបណ្តុះបណ្តាល អ្នកសារព័ត៌មានអំពីការសរសេរ អត្ថបទសារព័ត៌មានទាក់ទងនឹង បច្ចេកវិទ្យានុយក្លេអ៊ែរ។
- រៀបចំសម្របសម្រួលកិច្ចប្រជុំក្រុមការងាររួមកម្ពុជា-រុស្ស៊ីលើកទី៤
- បន្តរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ក្រុមការងារថ្នាក់ជាតិ ដើម្បីបញ្ចប់លើសេចក្តីព្រាងកិច្ច ព្រមព្រៀងបង្កើតមជ្ឈមណ្ឌលវិទ្យាសាស្ត្រនិងបច្ចេកវិទ្យានុយក្លេអ៊ែរនៅកម្ពុជា និងដាក់ជូនរាជរដ្ឋាភិបាលពិនិត្យនិងសម្រេច
- បន្តសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធជាតិលើការងារវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
- បន្តសហការជាមួយគ្រឹះស្ថានអប់រំដូចជា សាកលវិទ្យាល័យភូមិន្ទភ្នំពេញ សាកល វិទ្យាល័យភូមិន្ទកសិកម្ម សាលាជាតិកសិកម្មព្រែកលៀប សាកលវិទ្យាល័យមានជ័យ សាកលវិទ្យាល័យ ត្បូងឃ្មុំ និងវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជាលើការលើកម្ពស់ការយល់ដឹងពីវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
- បន្តសហការនិងសម្របសម្រួលជាមួយមជ្ឈមណ្ឌលបច្ចេកវិទ្យាបៃតងសាធារណៈរដ្ឋកូរ៉េ លើការរៀបចំគម្រោង «ការដឹកជញ្ជូនបៃតងនៅកម្ពុជា»
- បន្តសហការជាមួយអង្គការស្ទីមកម្ពុជាអង្គការពិព័រណ៍វិទ្យាសាស្ត្រកម្ពុជា
- ស្នើសុំគោលការណ៍ពីរាជរដ្ឋាភិបាលដើម្បីពិនិត្យលទ្ធភាពចុះហត្ថលេខាលើ អនុស្សរណៈនៃការយោគយល់ រវាងក.ជ.អ.ច.និង CNNC ស្តីពីការអភិវឌ្ឍធនធាន មនុស្សក្នុងវិស័យ ថាមពលនុយក្លេអ៊ែរ
- បន្តរៀបចំសេចក្តីព្រាងអនុស្សរណៈនៃការយោគយល់រវាង ក.ជ.អ.ច. និងវិទ្យាស្ថានថាមពលបរមាណូនៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម (Vinatom)
- បន្តសហការជាមួយកម្មវិធីភាពធន់នឹងអាកាសធាតុ (SPCR) និងកម្មវិធីសម្ព័ន្ធភាព ប្រែប្រួលអាកាសធាតុកម្ពុជា (CCCA)
- បន្តពិភាក្សាលើក្របខណ្ឌសហប្រតិបត្តិការជាមួយភាគីកូរ៉េ ដើម្បីស្វែងរកការគាំទ្រលើ ការរៀបចំផែនទីចង្អុលផ្លូវវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ការរៀបចំយន្តការវាយតម្លៃការសិក្សាស្រាវជ្រាវ និងលទ្ធផលនៃការសិក្សាស្រាវជ្រាវ ការចងក្រងទិន្នន័យស្តីពីបច្ចេកវិទ្យាដែលសមស្របសម្រាប់ការអនុវត្តនៅកម្ពុជា និងការកសាងធនធានមនុស្ស

## ៩.៣ នាយកដ្ឋានសេដ្ឋកិច្ចបៃតង

- ធ្វើការសហការជាមួយដៃគូ ដើម្បីរៀបចំបង្កើតគ្រូបង្គោលថ្នាក់ជាតិ និងរៀបចំសៀវភៅណែនាំការបណ្តុះបណ្តាល (Training Manual) សម្រាប់កម្មវិធីកសាងសមត្ថភាព/បណ្តុះបណ្តាលមន្ត្រីបង្គោល ស្តីពីការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្របង្កើតគណៈកម្មាធិការនិងក្របខណ្ឌការងាររបស់គណៈកម្មាធិការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ គោលការណ៍ណែនាំក្នុងការអនុវត្តវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ និងអនុវត្តន៍គម្រោងសាកល្បងវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ
- កែសម្រួល និងធ្វើបច្ចុប្បន្នភាពក្រុមការងារបច្ចេកទេសថាមពលនិរន្តរភាព
- បន្តកិច្ចសហការជាមួយUNDP ដើម្បីរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការថែទាំ និងគ្រប់គ្រងប្រព័ន្ធបន្ទះថាមពលពន្លឺព្រះអាទិត្យនៅ មជ្ឈមណ្ឌលស្រាវជ្រាវនិងអភិរក្សកេសរកូល សុខ អាន ភ្នំគូលែន នៅខេត្តសៀមរាប។សហការជាមួយដៃគូរពាក់ព័ន្ធ ដើម្បី

ទំព័រ៣៤

ដំឡើងបន្ទះថាមពលពន្លឺព្រះអាទិត្យនៅទីតាំងទី២ សហគមន៍ស្រែអំពិល ឃុំក្តុលស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង។

- បន្តសហការសម្របសម្រួលជាមួយ GGGI ក្នុងការស្វែងរកដៃគូ ដើម្បីធ្វើការសិក្សាបុរេសមិទ្ធិលទ្ធភាពពេញលេញស្តីពី ការទាញយកឥន្ទនៈចំហេះពីសំណល់ (Refuse Derived Fuel) និងសហការសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ វិស័យឯកជន ដើម្បីធ្វើការវិនិយោគលើគម្រោងនេះ ដែលជាផ្នែកមួយសំខាន់ក្នុងការគ្រប់គ្រងសំណល់រឹង នៅរាជធានីភ្នំពេញ
- ផ្សព្វផ្សាយលើឯកសារស្តីពី ១) ការវាយតម្លៃសេដ្ឋកិច្ចលើសក្តានុពលថាមពលពន្លឺព្រះអាទិត្យនៅកម្ពុជា ២)ការវាយតម្លៃសក្តានុពលនៃការអភិវឌ្ឍបៃតងនៅកម្ពុជា និង៣) ឯកសារផលប៉ះពាល់សេដ្ឋកិច្ច សង្គម និងបរិស្ថាន នៃការអភិវឌ្ឍឧស្សាហកម្មបៃតងនៅកម្ពុជា
- បន្តសហការអនុវត្តគម្រោង ស្តីពីការគ្រប់គ្រងប្រកបដោយនិរន្តរភាព នៃគុណភាពទឹកទន្លេមេគង្គកម្ពុជា ដែលជាសំណើរគម្រោង "The 2020 Seoul Initiative Network on Green Growth (SINGG) Pilot Project Proposal"
- រៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសថាមពលនិរន្តរភាព
- សហការអនុវត្តលើគម្រោងស្តីពីការលើកកម្ពស់ការអនុវត្តថាមពលនិរន្តរភាពនៅក្នុងវិស័យវាយនភ័ណ្ឌនៅកម្ពុជា (Project Agreement on Promotion of Sustainable Energy Practice in the garment sector in Cambodia) ជាមួយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ វិទ្យាស្ថានអភិវឌ្ឍន៍សកល (GGGI) GERES និង GMAC
- បន្តការពារក្នុងការដាក់បញ្ចូលពាក្យបច្ចេកសព្ទដែលនៅសល់ទៅក្នុងសទ្ទានុក្រមរបស់សេចក្តីព្រាងក្រមបរិស្ថាន និងធនធានធម្មជាតិ
- ការិយាល័យរចនាបថការរស់នៅដោយចីរភាព
- រៀបចំកិច្ចប្រជុំលើកទី៤ របស់ក្រុមការងារបច្ចេកទេសទីក្រុងនិរន្តរភាព
- សម្របសម្រួលរៀបចំសេចក្តីព្រាង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុងនិរន្តរភាព សម្រាប់ក្រុងគោលដៅចំនួន២ នៅក្រុមខេត្តគោលដៅទី៣ (ខេត្តមណ្ឌលគិរី រតនគិរី ក្រចេះ និងស្ទឹងត្រែង)
- រៀបចំសិក្ខាសាលាបណ្តុះបណ្តាលចែករំលែកចំណេះដឹង ការស្វែងយល់ កសាងសមត្ថភាព បណ្តុះបណ្តាលមន្ត្រីបង្គោលស្តីពី ការអភិវឌ្ឍទីក្រុងនិរន្តរភាពនៅកម្ពុជា សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ
- គម្រោងរៀបចំគោលការណ៍ណែនាំ និងវិញ្ញាបនបត្រកម្មអគារបៃតងនៅកម្ពុជា
- រៀបចំសេចក្តីព្រាងគោលការណ៍ណែនាំ ស្តីពីអគារបៃតងនៅកម្ពុជា ដោយផ្អែកលើប្រព័ន្ធអគារបៃតងនៅតាមបណ្តាប្រទេសនានា នៅក្នុងតំបន់ក៏ដូចជាសកលលោក
- ផ្តល់យោបល់លើប្រព័ន្ធវិញ្ញាបនបត្រកម្មអគារបៃតង ឬយន្តការសមសម្របសម្រាប់ប្រព័ន្ធវិញ្ញាបនបត្រកម្មអគារបៃតងនៅកម្ពុជា
- ការិយាល័យស្តង់ដារបៃតង និងការប្រើប្រាស់ និងការផលិតដោយចីរភាព
- រៀបចំកិច្ចប្រជុំលើកទី៣ ក្រុមការងារបច្ចេកទេសស្តីពី ការប្រើប្រាស់ និងផលិតកម្មនិរន្តរភាព
- អនុវត្តគម្រោង SCP ដែលផ្តោតទៅលើលទ្ធកម្មសាធារណៈបៃតងនិងស្លាកសញ្ញាបៃតង (GPP and Eco-Labeling) ដែលសហការជាមួយ GIZ
- ផ្សព្វផ្សាយ និងអនុវត្តសាកល្បងផែនការយុទ្ធសាស្ត្រ និងសកម្មភាពសេដ្ឋកិច្ចចក្រាគម្រោងBESD
- បន្តអនុវត្តគម្រោងBESD នូវការគ្រប់គ្រង និងការកែច្នៃសំណល់

ទំព័រ៣៩

- ការិយាល័យជំរុញស្លាកសញ្ញាបៃតង និងវិញ្ញាបនបត្របៃតង
- ផ្សព្វផ្សាយ និងអនុវត្តសាកល្បងលើគោលការណ៍ណែនាំបច្ចេកទេស ស្តីពីការិយាល័យបៃតង (Green Office) និងព្រឹត្តិការណ៍បៃតង (Green Event)

## ៩.៤ នាយកដ្ឋានប្រែប្រួលអាកាសធាតុ

- បន្តសម្របសម្រួល និងអនុវត្តចង្កោមសកម្មភាពទី៥ ផ្នែកអប់រំ ផ្សព្វផ្សាយព័ត៌មាន លើកកម្ពស់ការយល់ដឹង និងបញ្ជ្រាបការងារប្រែប្រួលអាកាសធាតុ និងចង្កោមសកម្មភាពទី៦ ក្នុងការរៀបចំក្របខ័ណ្ឌគតិយុត្ត តាមដានការអនុវត្តផែនការយុទ្ធសាស្ត្រ និងសិក្សាស្រាវជ្រាវ វាយតម្លៃលើកកម្ពស់ការកសាងសមត្ថភាព សម្របសម្រួលនិងសហការជាមួយស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ តំបន់អាស៊ាន និងអន្តរជាតិ ព្រមទាំងកៀរគរការគាំទ្រទាំងផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុ
- បន្តសម្របសម្រួលក្នុងការអនុវត្តគម្រោង/កម្មវិធីរបស់នាយកដ្ឋាន៖
  ១)កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជាដំណាក់កាលទី៣ (CCCA3)
  ២)គម្រោង «ការកាត់បន្ថយភាពងាយរងគ្រោះនៃជីវភាពរបស់ប្រជាជនកម្ពុជានៅជនបទតាមរយៈការពង្រឹងផែនការប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិនិងអនុវត្តសកម្មភាពអាទិភាព(SRL)»
  ៣)គម្រោង «ការកសាងភាពធន់នឹងអាកាសធាតុនៃប្រព័ន្ធទីក្រុងតាមរយៈការបន្សាំដោយផ្អែកលើប្រព័ន្ធអេកូឡូស៊ីនៅតំបន់អាស៊ីប៉ាស៊ីហ្វិក(EbA)» និង៤)គម្រោងការពង្រឹងសមត្ថភាពដើម្បីបង្កើនតម្លាភាពក្នុងការអនុវត្ត និងតាមដានការរួមចំណែក របស់ថ្នាក់ជាតិដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុក្នុងវិស័យកសិកម្ម និងការប្រើប្រាស់ដី
- បន្តសហការនិងសម្របសម្រួលក្នុងគម្រោងស្តីពី «ការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ នៃកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ» ដោយមានតំណាងធនាគារអភិវឌ្ឍន៍អាស៊ី
- បន្តសហការជាមួយនឹងលេខាធិការដ្ឋានគណៈកម្មាធិការចម្រុះ JCM ភាគីជប៉ុនក្នុងការសម្របសម្រួលការងារ JCM និងបន្តពិនិត្យសំណើរបស់ Carbon Offsetting and Reduction Scheme for International Aviation (CORSIA) ឱ្យកាន់តែលម្អិត និងច្បាស់លាស់
- បន្តសហការជាមួយមជ្ឈមណ្ឌលសហប្រតិបត្តិការក្នុងតំបន់ Regional Collaboration Center: RCC ក្នុងការរៀបចំប្រមូលទិន្នន័យប្រព័ន្ធអគ្គិសនីនៅកម្ពុជា ដើម្បីបង្កើតស្តង់ដាគោលនៅកម្ពុជា
- បានបន្តសម្របសម្រួលការងារជាមួយ NDC Partnership ក្នុងការរៀបចំ NDC update
- បាននិងកំពុងពិនិត្យលើអនុក្រឹត្យ ស្តីពីវិធាន និងនីតិវិធីចូលរួមក្នុងយន្តការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់
- បន្តសម្របសម្រួល និងសហការជាមួយអង្គការ FAO លើគម្រោង «ការពង្រឹងសមត្ថភាពដើម្បីបង្កើនតម្លាភាពក្នុងការអនុវត្ត និងតាមដានការរួមចំណែករបស់ថ្នាក់ជាតិដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (NDC) ក្នុងវិស័យកសិកម្ម និងការប្រើប្រាស់ដី»
- បន្តសម្របសម្រួលក្នុងការដាក់របាយការណ៍ជាតិពីរឆ្នាំម្តង ទៅលេខាធិការដ្ឋានUNFCCC និងបោះពុម្ពផ្សព្វផ្សាយចែកជូនរបាយការណ៍ជូនដល់ក្រុមការងារអន្តរក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ និង
- បន្តសម្របសម្រួល និងសហការជាក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ក្នុងការផ្តល់ធាតុចូលនៃផែនការសកម្មភាពអាទិភាពតាមវិស័យរបស់ខ្លួនលើផ្នែកបន្សាំ ការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ ហិរញ្ញវត្ថុ អភិបាលកិច្ច និងតម្លាភាព ពីឆ្នាំ២០២០ ដល់២០៣០ និងរៀបចំកិច្ចប្រជុំពិគ្រោះយោបល់

លើការផ្តល់សុពលភាពការចូលរួមចំណែករបស់ជាតិ ដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ដើម្បីធ្វើបច្ចុប្បន្នភាពនៃរបាយការណ៍ដាក់ជូន ទៅលេខាធិការដ្ឋានUNFCCC។

### ៩.៨ នាយកដ្ឋានជីវៈចម្រុះ

- រៀបចំឯកសារទស្សនទាន និងឯកសារពាក់ព័ន្ធ ដើម្បីចុះផ្សព្វផ្សាយពីយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីជីវៈចម្រុះ ដល់អ្នកពាក់ព័ន្ធនានាតាមមន្ទីរបរិស្ថានខេត្ត/ក្រុង
- បន្តរៀបចំកែសម្រួលលើទម្រង់-រចនាសម្ព័ន្ធ និងខ្លឹមសារ BCHM ព្រមទាំងបញ្ចូលព័ត៌មាន និងទិន្នន័យថ្មីៗសម្រាប់ ធ្វើការផ្សព្វផ្សាយដល់សាធារណជនទូទៅ
- បន្តការសិក្សាស្រាវជ្រាវ ឯកសារ លិខិតបទដ្ឋានពាក់ព័ន្ធ សម្រាប់រៀបចំក្របខណ្ឌគោលនយោបាយជាតិនិងច្បាប់ទាក់ទងនឹងការបង់ថ្លៃសេវាកម្មប្រពន្ធ័អេកូឡូស៊ី
- បន្តការសិក្សាស្រាវជ្រាវប្រភេទសត្វ និងរុក្ខជាតិ និងប្រមូលទិន្នន័យជីវៈចម្រុះពាក់ព័ន្ធដើម្បីចងក្រងជាប្រព័ន្ធទិន្នន័យជីវៈចម្រុះថ្នាក់ជាតិ
- បន្តរៀបចំបញ្ចប់ក្របខណ្ឌការងារជាតិស្តីពីការប្រើប្រាស់ និងការបែងចែកផលប្រយោជន៍ពីការប្រើប្រាស់ធនធានពន្ធុ(ABS) និងនិតិវិធីអនុវត្តពាក់ព័ន្ធ
- ជំរុញការចុះអនុស្សរណៈយោគយល់រវាងរាជរដ្ឋាភិបាលកម្ពុជា និងប្រទេសកូស្តារីកាលើកម្មវិធី PES
- អនុវត្តន៍ PES សាកល្បងនៅតំបន់ទឹកសាបក្បាលឆាយ ខេត្តព្រះសីហនុ និងភ្នំគូលែន ខេត្តសៀមរាប
- បន្តប្រមូលពាក្យបច្ចេកទេសពាក់ព័ន្ធនឹងជីវៈចម្រុះ ដើម្បីរៀបចំចងក្រងជាសន្ទានុក្រមជីវៈចម្រុះ និងជីវសុវត្ថិភាព
- ត្រៀមរៀបចំចុះអនុស្សរណៈយោគយល់គ្នាជាមួយមជ្ឈមណ្ឌល KEW នៃប្រទេសអង់គ្លេសទាក់ទងនឹងការងារអភិរក្សក្រៅដែនធម្មជាតិ និងការរៀបចំសារមន្ទីរធម្មជាតិ និងរុក្ខឧទ្យានធម្មជាតិ
- រៀបចំប្លង់មេ និងរៀបចំអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធចាំបាច់ក្នុងមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិរក្សកេសរកូល សុខអាន ភ្នំគូលែន
- ចុះអនុស្សរណៈយោគយល់គ្នារវាងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ ដោយចីរភាព និងអង្គការសហភាពអន្តរជាតិ (IUCN) ដើម្បីការអភិរក្សធនធានធម្ម ជាតិ ស្តីពី កិច្ចសហប្រតិបត្តិការលើវិស័យទឹកស្បៀងអាហារ ថាមពល និងជីវៈចម្រុះ
- បន្តរៀបចំផែនការអនុវត្តសេចក្តីសម្រេច នៃកិច្ចប្រជុំ អ.ក.អ.ច. លើកទីពីរ ត្រង់ចំណុចពាក់ព័ន្ធនឹងGMOs/LMOs
- ជំរុញការរៀបចំដំណើរការមន្ទីរពិសោធន៍ជីវសុវត្ថិភាព និងវគ្គបណ្តុះបណ្តាលពាក់ព័ន្ធ៕

ទំព័រ១៣៧

## ១០.សន្និដ្ឋាន

ក្នុងឆ្នាំ២០២០ នេះ អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពសម្រេចបាន ដូចជាការតាក់តែងលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ និងយុទ្ធសាស្ត្រក្នុងវិស័យបរិស្ថាន និងការអភិវឌ្ឍដោយចីរភាព ដោយផ្អែកលើស្ថានភាពជាក់ស្តែង រួមជាមួយទិន្នន័យនិងព័ត៌មានវិទ្យាសាស្ត្រ ដើម្បីលើកកម្ពស់ការអភិវឌ្ឍដោយចីរភាព សំដៅរក្សាបាននូវតុល្យភាពរវាងសេដ្ឋកិច្ច បរិស្ថាន សង្គម និងវប្បធម៌ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ សមិទ្ធិផលទាំងនោះរួមមានជាអាទិ៍៖

- បានរៀបចំគោលនយោបាយស្តីពីការបង់ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី និងផែនទីបង្ហាញផ្លូវសម្រាប់ការងារជីវសុវត្ថិភាព និងសេចក្តីព្រាងក្របខណ្ឌការងារជាតិស្តីពីការប្រើប្រាស់ និងការបែងចែកផលប្រយោជន៍ពីការប្រើប្រាស់ធនធានពន្ធុដោយស្មើភាព និងសមធម៌
- បានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីវិធាន និងនីតិវិធីចូលរួមក្នុងយន្តការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់
- បានបញ្ចប់សេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពឆ្នាំ២០២០-២០៣០សម្រាប់ក្រុងកែប ព្រះសីហនុ បាត់ដំបង សៀមរាប កំពង់ចាម សួង និងក្រុងបាវិត
- បានរៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រ និងសកម្មភាពសេដ្ឋកិច្ចចក្រា និងយន្តការវាយតម្លៃការសិក្សាស្រាវជ្រាវនិងចងក្រងទិន្នន័យស្តីពីបច្ចេកវិទ្យាសមស្របសម្រាប់ការអនុវត្តនៅកម្ពុជា
- បានបញ្ចប់សេចក្តីព្រាងក្រមសីលធម៌នៃការសិក្សាស្រាវជ្រាវក្នុងកំរិតបច្ចេកទេសនិងបន្តរៀបចំផែនទីបង្ហាញផ្លូវផ្នែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា
- បានរៀបចំសេចក្តីព្រាងគោលការណ៍ណែនាំ និងបច្ចេកទេស ស្តីពីអគារបៃតង ការិយាល័យបៃតង និងព្រឹត្តិការណ៍បៃតង
- បានរៀបចំរបាយការណ៍សមិទ្ធិផលនៃការអនុវត្តគោលដៅអភិវឌ្ឍន៍ដោយចីរភាពក្នុងវិស័យបរិស្ថាននិងការអភិវឌ្ឍដោយចីរភាព
- បានអនុម័តរបាយការណ៍បច្ចុប្បន្នភាព២ឆ្នាំម្តង និងដាក់ជូនទៅលេខាធិការដ្ឋានក្របខណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ
- បានសិក្សាវាយតម្លៃសេដ្ឋកិច្ចលើសក្តានុពលថាមពលពន្លឺព្រះអាទិត្យនៅកម្ពុជាការអភិវឌ្ឍបៃតងនៅកម្ពុជា និងផលប៉ះពាល់សេដ្ឋកិច្ច សង្គម និងបរិស្ថាន នៃការអភិវឌ្ឍឧស្សាហកម្មបៃតងនៅកម្ពុជា និង
- បានបន្តរៀបចំប្លង់ និងផែនការមេនៅក្នុងមជ្ឈមណ្ឌលស្រាវជ្រាវនិងអភិរក្សកេសរកូល សុខ អានភ្នំគូលែន និងបញ្ចប់សេចក្តីព្រាងស្តីពីសៀវភៅមគ្គុទេសន៍គ្រឿងទេសនៅកម្ពុជា។

ជោគជ័យទាំងអស់នេះកើតឡើងដោយសារការដឹកនាំប្រកបដោយយុទ្ធសាស្ត្រ ជាក់លាក់ រឹងមាំ និងចក្ខុវិស័យរបស់ថ្នាក់ដឹកនាំ ក.ជ.អ.ច. ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាប្រធានកិត្តិយស និងឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន ជាប្រធាន

ទំព័រ៣៨

ដែលតែងតែយកចិត្តទុកដាក់ខ្ពស់ និងផ្តល់អាទិភាពចំពោះការងាររបស់អគ្គលេខាធិការដ្ឋានក.ជ.អ.ច. ជាពិសេសគំនិតផ្តួចផ្តើមថ្មីៗ រួមមាន ការអភិវឌ្ឍវិស័យថាមពលកកើតឡើងវិញ ការអភិរក្សជីវៈចម្រុះ ការកសាងសង្គម និងសេដ្ឋកិច្ចដែលមានភាពធន់នឹងអាកាសធាតុ ការលើកម្ពស់សេដ្ឋកិច្ចបៃតង ការសិក្សាស្រាវជ្រាវបែបវិទ្យាបច្ចេកវិទ្យានវានុវត្តន៍ និងរដ្ឋបាលទំនើប ជាដើម។

ជាមួយគ្នានេះដែរ ជោគជ័យ និងសមិទ្ធផលទាំងនេះ គឺជាការចូលរួមចំណែករបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការចំណុះអគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. ដែលបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត សមត្ថភាព ប្រាជ្ញា ស្មារតី ធនធាន និងពេលវេលា ដើម្បីអនុវត្តសកម្មភាពអាទិភាពដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា និងក្របខណ្ឌគតិយុត្តនានាដែលមានជាធរមាន។ ឆ្លងតាមបទពិសោធន៍ការងាររយៈពេលជាង៥ឆ្នាំនេះ អគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. បានរៀនសូត្រការងារជាច្រើនរួមមាន៖ ការងាររៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រ ការសិក្សាស្រាវជ្រាវ អភិបាលកិច្ចការពង្រឹងសមត្ថភាព ទំនាក់ទំនងអន្តរជាតិ ការកៀរគរធនធានមនុស្ស និងហិរញ្ញវត្ថុ។

ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. យល់ច្បាស់នូវតួនាទីគន្លឹះរបស់ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ក្នុងការរួមចំណែកគូសវាសនូវគោលនយោបាយជាតិ និងតាមវិស័យដោយផ្អែកលើមូលដ្ឋានសិក្សាស្រាវជ្រាវបែបវិទ្យាសាស្ត្រ សំដៅគាំទ្រនូវការអភិវឌ្ឍប្រកបដោយចីរភាព ហើយប្តេជ្ញាខិតខំប្រឹងប្រែងបន្តទៀត ក្នុងការកសាងសមត្ថភាពបច្ចេកទេសនិងសមត្ថភាពស្ថាប័ន ការសម្របសម្រួលកិច្ចសហការជាមួយបណ្តាក្រសួងស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល គ្រឹះស្ថានសិក្សាស្រាវជ្រាវ និងវិស័យឯកជន និងក្នុងការកៀរគរធនធាន ពីគ្រប់ប្រភព សំដៅរួមចំណែកអនុវត្តគោលនយោបាយ និងផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់អាណត្តិទី៦នៃរដ្ឋសភា ២០១៩-២០២៣ ពិសេសយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ក្រោមការដឹកនាំដោយឈ្លាសវៃប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ឆ្ពោះទៅសម្រេចឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០៕

ទំព័រ៣៩

https://ncsd.moe.gov.kh

**រួមគ្នាឆ្ពោះទៅអភិវឌ្ឍន៍ដោយចីរភាព**
**Together towards Sustainable Development**